ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

# សៀវភៅសំរាប់គ្រូបង្គោល

## ស្តីពី

## គោលគំនិតនៃការបញ្ជ្រាបយេនឌ័រ
## ជំនាញសំខាន់ៗ និងតួនាទីនិងការទទួលខុសត្រូវ
## របស់អ្នកទទួលបន្ទុកកិច្ចការនារី និង កុមារ
## នៅក្នុងឃុំ-សង្កាត់

NCDD Library
000106

# សេចក្តីផ្តើមសំរាប់គ្រូបណ្តុះបណ្តាលនិងអ្នកសំរបសំរួល

សៀវភៅបណ្តុះបណ្តាលនេះ រៀបចំឡើងដើម្បីជំនួយដល់គ្រូបង្គោលក្នុងការបណ្តុះបណ្តាលបន្តដល់អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់។ សៀវភៅបណ្តុះបណ្តាលនេះមានចែកចេញជា២ផ្នែកធំៗ។ នៅក្នុងផ្នែកទី១ ផ្តោតលើការយល់ដឹងពីគោលគំនិតយេនឌ័រសំខាន់ៗនិងការបញ្ជ្រាបយេនឌ័រ។ នៅក្នុងផ្នែកទី២ ដើម្បីជំនួយដល់អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារពីតួនាទីនិងការទទួលខុសត្រូវសំខាន់ៗរបស់ពួកគេនិងផ្តល់នូវចំណេះដឹងនិងជំនាញជាមូលដ្ឋានក្នុងការអនុវត្តន៍តួនាទីនិងការទទួលខុសត្រូវទាំងនោះឱ្យមានប្រសិទ្ធភាព។

សៀវភៅបណ្តុះបណ្តាលនេះ រៀបចំឡើងតាមវិធីសាស្ត្រនៃការចូលរួមយ៉ាងសកម្ម។ ក្នុងនេះមានន័យថា អ្នកចូលរួមទាំងអស់ចូលរួមយ៉ាងសកម្មក្នុងការរៀនសូត្រ។ អ្នកសំរបសំរួលត្រូវតែមានពេលវេលាគ្រប់គ្រាន់សំរាប់ការពិភាក្សា ហើយត្រូវព្យាយាមសួរទៅសិក្ខាកាមនៅរាល់ពេលចុងបញ្ចប់នៃមេរៀននីមួយៗ ថាតើគេរៀនបានអ្វីខ្លះ?តើគេត្រូវប្រើប្រាស់ចំណេះដឹងនិងជំនាញដែលគេបានរៀនពេលនេះទៅក្នុងការងាររបស់គេរបៀបណា?

សៀវភៅបណ្តុះបណ្តាលនេះ គឺជាឯកសារណែនាំជាមូលដ្ឋានមួយ។ អ្នកត្រូវតែអានឱ្យបានយល់ច្បាស់មុនពេលអ្នកចាប់ផ្តើមវគ្គបណ្តុះបណ្តាល។ អ្នកអាចបន្ថែមចំណុចសំខាន់ៗ ហើយអ្នកអាចផ្លាស់ប្តូរនិងសំរួលទៅតាមស្ថានភាពជាក់ស្តែងប្រសិនបើអ្នកគិតថាចាំបាច់។ អ្នកត្រូវព្យាយាមបង្រៀនគ្រប់មេរៀនទាំងអស់ ព្រោះមេរៀននីមួយៗសុទ្ធតែមានសារៈសំខាន់និងពាក់ព័ន្ធគ្នាទៅវិញទៅមក ដែលជួយឱ្យអ្នកចូលរួមទទួលបាននូវចំណេះដឹងនិងជំនាញពាក់ព័ន្ធសំខាន់ៗ។

នៅពេលបញ្ចប់វគ្គបណ្តុះបណ្តាល អ្នកត្រូវសរសេរនូវអ្វីដែលអ្នកគិតថាល្អ និងអ្វីដែលគួរផ្លាស់ប្តូរឬកែលំអ។ អ្នកអាចទាក់ទងជាមួយក្រុមការងារគាំទ្រការបញ្ជ្រាបយេនឌ័រក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន ក្នុងការផ្តល់យោបល់សំរាប់ផ្លាស់ប្តូរ និងកែលំអសៀវភៅនេះទៅអនាគត។ អ្នកអាចផ្ញើយោបល់អ្នកតាមរយៈអាស័យដ្ឋានដូចតទៅនេះ:

ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

អាគារលេខ៣ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

អ៊ីមែល : chhunhak@online.com.kh

ទូរស័ព្ទលេខ:(៨៥៥)០២៣ ២២០ ៩៦៧ ឬ ០១២ ៨៩២៩៩៧ ឬ ០១២ ៩៨៨ ៨៩១។

# សេចក្តីថ្លែងអំណរគុណ

សៀវភៅបណ្តុះបណ្តាលនេះ រៀបចំឡើងដោយក្រុមការងារគាំទ្រការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីសិលានៃក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន ក្នុងនោះមាន លោកស្រី **សុខ ចន្ទ័ធទី** អគ្គនាយករងកិច្ចការបច្ចេកទេស លោកស្រី **គីម ស៊ីផាត់** លោកស្រី **ឡុង និមល** លោកស្រី **នុំ បូផារី** លោកស្រី **យិន សារ៉ាត់** លោក **ស សុធា** លោក **ថេ ឈុនហាក់** លោក **ជិន ឌីណា** និងលោកស្រី **រិទ្ធ ស្រួស** ទីប្រឹក្សានៃគំរោងភាពជាដៃគូសំរាប់អភិបាលកិច្ចមូលដ្ឋាន។

សូមថ្លែងអំណរគុណដល់លោកស្រី **លីន លី** ទីប្រឹក្សាគំរោងស្វែងរកការគាំទ្រមតិ និងលោក **ហាន់ ទាវ៉ាន់សុខហ្គែល** ដែលបានជួយពិនិត្យនិងផ្តល់យោបល់លើសៀវភៅបណ្តុះបណ្តាលនេះ។

សូមថ្លែងអំណរគុណដល់លោកស្រី **ចូរអាន មូរីសុន** ទីប្រឹក្សាផ្នែកប្រតិបត្តិ និងលោក **ឈ ចាន់សុផល** ទីប្រឹក្សាផ្នែកគ្រប់គ្រងនៃគំរោងភាពជាដៃគូសំរាប់អភិបាលកិច្ចមូលដ្ឋាន និងគណៈកម្មាធិការដឹកនាំកម្មវិធីសិលាដែលផ្តល់ការណែនាំនិងជំនួយក្នុងការរៀបចំសៀវភៅបណ្តុះបណ្តាលនេះ។

ជាទីបញ្ចប់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកជំទាវថ្នាក់ដឹកនាំនៃក្រសួងកិច្ចការនារីនិងអតីតយុទ្ធជនដែលបានផ្តល់ការគាំទ្រនិងជួយសំរួលដល់ក្រុមការងារក្នុងការរៀបចំសៀវភៅបណ្តុះបណ្តាលនេះឡើង។

# គំរោងមេរៀនទី១ :សេចក្តីផ្តើមនិងគោលបំណងវគ្គបណ្តុះបណ្តាល

គោលបំណង : នៅចុងបញ្ចប់នៃមេរៀន អ្នកចូលរួមនឹងទទួលបាននូវ :

- ការស្គាល់គ្នាទៅវិញទៅមក ដឹងពីគោលបំណង និងលទ្ធផលរំពឹងទុកពីការបណ្តុះបណ្តាល។
- យល់ដឹងពីកម្មវិធីនៃវគ្គបណ្តុះបណ្តាល និងបង្កើតបាននូវវិន័យសមស្របមួយសំរាប់វគ្គបណ្តុះបណ្តាល។

រយៈពេល : ប្រហែល៦០នាទី

វិធីសាស្ត្រ : លំហាត់លេងល្បែង និងអធិប្បាយ។

សំភារៈ : ក្រដាសផ្ទាំងធំ និង ហ្វឺត ។ល។

ឯកសារមេរៀន : គោលបំណងនិងកម្មវិធីនៃវគ្គបណ្តុះបណ្តាល។

របៀបសំរបសំរួលៈ

ក. ល្បែងពីការណែនាំខ្លួន

១. អ្នកសំរបសំរួលសុំអោយអ្នកចូលរួមចាប់ដៃគូ។ ទុករយៈពេល៥នាទី សុំឱ្យដៃគូនីមួយៗអធិប្បាយប្រាប់ដៃគូរបស់ខ្លួនពីឈ្មោះ តួនាទីនិងចំណូលចិត្តរបស់ពួកគេ។ បន្ទាប់មកសុំឱ្យគូនីមួយៗឡើងបង្ហាញពីឈ្មោះ តួនាទីនិងចំណូលចិត្តដៃគូរបស់ពួកគេ។

(វិធីសាស្ត្រនៃមេរៀននេះអាចផ្លាស់ប្តូរអាស្រ័យ ដោយអ្នកសំរបសំរួល) ។

២. អ្នកសំរបសំរួលអាចនាំអ្នកចូលរួមលេងល្បែងណាមួយដែលបង្កើតអោយមានភាពកក់ក្តៅ មុននឹងចាប់ផ្តើមមេរៀន (អ្នកសំរបសំរួលអាចជ្រើសរើសល្បែងណាដែលពាក់ពន្ធ័នឹងប្រធានបទ) ។

ខ. ការពណ៌នាពីគោលបំណងនៃវគ្គបណ្តុះបណ្តាល

១. អ្នកសំរបសំរួលបំបែកអ្នកចូលរួមជាបីក្រុម ហើយសុំអោយអ្នកចូលរួមគិត និងសរសេរនូវអ្វីដែលពួកគេរំពឹងថានឹងទទួលបាននៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលទៅលើក្រដាសពណ៌តូចៗ ហើយយកមកបិទលើក្តារខៀន។

២. អ្នកសំរបសំរួលចាត់ការរំពឹងទុកដែលបានមកពីអ្នកចូលរួមទៅតាមផ្នែកនីមួយៗ (ចំណេះដឹង ជំនាញ ។ល។

៣. អ្នកសំរបសំរួលបង្ហាញពីគោលបំណងនៃវគ្គបណ្តុះបណ្តាលដោយឆ្លុះបញ្ចាំងនឹងទៅនឹងការរំពឹងទុកដែលអ្នកចូលរួមបានលើកឡើង។

៤. បន្ទាប់មកអ្នកសំរបសំរួលបង្ហាញពីកម្មវិធីនៃវគ្គបណ្តុះបណ្តាល (ប្រសិនបើមានពេលវេលាគ្រប់គ្រាន់)។

**គ. ការបង្កើតវិន័យ**

១. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមគិតពីការបង្កើតវិន័យសំរាប់វគ្គបណ្តុះបណ្តាល ។ សរសេរយោបល់ទាំងនោះនៅលើក្រដាសផ្ទាំងធំ ហើយសុំអោយអ្នកចូលរួមគោរពតាមវិន័យដែលពួកគេបានលើកឡើងដើម្បីធ្វើអោយដំណើរការនៃវគ្គបណ្តុះបណ្តាលប្រព្រឹត្តទៅបានល្អ។

២. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមសួរនូវអ្វីដែលគេមិនទាន់យល់ច្បាស់។ ឆ្លើយតបនូវសំណួរទាំងនោះ។

**កំណាត់សំគាល់សំរាប់អ្នកសំរបសំរួល :**

អ្នកសំរបសំរួលត្រូវមានពេលវេលាគ្រប់គ្រាន់ល្មមសំរាប់សកម្មភាពនេះ ព្រោះជាសកម្មភាពដំបូងនៃវគ្គបណ្តុះបណ្តាល។ អ្នកសំរបសំរួលត្រូវធ្វើយ៉ាងណាដើម្បីឱ្យអ្នកចូលរួមមានភាពកក់ក្តៅ មានភាព ស្និទ្ធស្នាលនិងមានជំនឿលើវគ្គបណ្តុះបណ្តាល ព្រមទាំងបង្ហាញអោយពួកគេចាប់អារម្មណ៍ថាពួកគេគឺជាតួអង្គដ៏សំខាន់នៅក្នុងវគ្គបណ្តុះបណ្តាល។ ម្យ៉ាងទៀតត្រូវយកចិត្តទុកដាក់លើសេចក្តីរំពឹងទុករបស់ពួកគេ និងបង្ហាញថា អ្នកនឹងព្យាយាមអោយអស់លទ្ធភាពដើម្បីឆ្លើយតបទៅនឹងសេចក្តីរំពឹងទុករបស់គេ។

# គោលបំណងនៃវគ្គបណ្តុះបណ្តាល

គោលបំណងនៃការបណ្តុះបណ្តាល គឺ ដើម្បីជួយអោយអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារទទួលបាននូវ :

- យល់ច្បាស់ពីស្ថានភាពរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា គោលគំនិតយេនឌ័រ និងការបញ្ជ្រាបយេនឌ័រនៅថ្នាក់មូលដ្ឋាន។
- យល់ដឹងពីតួនាទីនិងការទទួលខុសត្រូវរបស់អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ។
- ការពង្រឹងជំនាញនិងចំណេះដឹងដែលអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារត្រូវការសំរាប់ធ្វើការប្រមូលពត៌មាន ធ្វើការវិភាគពត៌មាន ការប្រស្រ័យទាក់ទងនិងធ្វើការចរចានៅថ្នាក់ឃុំ-សង្កាត់ប្រកបដោយប្រសិទ្ធភាព។
- អនុវត្តនូវការប្រើប្រាស់ចំណេះដឹង វិធីសាស្ត្រនិងជំនាញផ្សេងៗ ពាក់ពន្ធ័នឹងការបញ្ជ្រាបយេនឌ័រក្នុងមូលដ្ឋាន។

ಌಌಌಌ ☺☺☺ ಐಐಐಐ

# កម្មវិធីនៃវគ្គបណ្តុះបណ្តាល

[illegible] ☺☺ ☺ [illegible]

| ពេលវេលា | ចំណងជើងមេរៀន | វិធីសាស្ត្រ |
|---|---|---|
| **ថ្ងៃទី១** | | |
| ព្រឹក | ១. **សេចក្តីផ្តើម** :ការណែនាំខ្លួន និងការរំពឹងទុក គោលបំណងវគ្គ និងការបង្កើតវិន័យ | • ការអធិប្បាយ<br>• ពិភាក្សាក្រុមធំ |
| | ២. **គោលគំនិតយេនឌ័រ**<br>២.១ យេនឌ័រនិងភេទ | • ការអធិប្បាយ<br>• សំណួរបំផុសគំនិត |
| | ២.២ តួនាទីយេនឌ័រ | • ការអធិប្បាយ<br>• ពិភាក្សាក្រុមតូច |
| រសៀល | ២.៣ វដ្តជីវិតនៃស្ត្រី | • សំណួរបំផុសគំនិត<br>• ពិភាក្សាក្រុមតូច |
| | ២.៤ ផលប៉ះពាល់អវិជ្ជមានដែលបណ្តាលមកពីបញ្ហាវិសមភាពយេនឌ័រ | • ការអធិប្បាយ<br>• សំណួរបំផុសគំនិត |
| **ថ្ងៃទី ២** | | |
| ព្រឹក | ២.៥ គំរូវការយេនឌ័រ | |
| | ២.៦ ច្បាប់និងគោលនយោបាយគាំទ្រសមភាពយេនឌ័រ | • ការអធិប្បាយ<br>• សំណួរបំផុសគំនិត |
| រសៀល | ៣. **តួនាទីនិងការទទួលខុសត្រូវ**<br>៣.១ តួនាទីនិងការទទួលខុសត្រូវនៃអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ | • ការអធិប្បាយ<br>• សំណួរបំផុសគំនិត |
| **ថ្ងៃទី៣** | | |
| ព្រឹក | ៤. **ការប្រស្រ័យទាក់ទង**<br>៤.១ សេចក្តីផ្តើមស្តីពីការប្រស្រ័យទាក់ទង | • ការអធិប្បាយ<br>• សំណួរបំផុសគំនិត |
| | ៤.២ ការស្តាប់ ការសួរសំនួរនិងការសង្ខេប | • ការអធិប្បាយ<br>• លំហាត់សម្តែងតួ |
| រសៀល | ៤.៣ ការប្រស្រ័យទាក់ទងតែម្នាងនិងទាំងសងខាង | • ការអធិប្បាយ<br>• លំហាត់សម្តែងតួ |

| | | |
|---|---|---|
| | ៤.៤ ការប្រស្រ័យទាក់ទងដោយកាយវិការនិងពាក្យសំដី | • ការអធិប្បាយ<br>• សំណួរបំផុសគំនិត |
| | **៥. ការប្រមូលពត៏មាន**<br>៥.១ សេចក្តីផ្តើមស្តីពីការប្រមូលពត៏មាន | • ការអធិប្បាយ<br>• សំណួរបំផុសគំនិត |
| ថ្ងៃទី៤ | | |
| ព្រឹក | ៥.២ ប្រភពទិន្នន័យ | • ការអធិប្បាយ<br>• សំណួរបំផុសគំនិត |
| | ៥.៣ ការសម្ភាសន៏ជាក្រុម | • ការអធិប្បាយ<br>• ការពិភាក្សាក្រុមតូច |
| រសៀល | **៦. ការប្រជុំ**<br>៦.៤.១ ការបង្ហាញនៅក្នុងប្រជុំ ឬសិក្ខាសាលា | • ការអធិប្បាយ<br>• លំហាត់សម្តែងតួ |
| ថ្ងៃទី៥ | | |
| ព្រឹក | ៦.៤.២ ការចរចារនៅក្នុងប្រជុំ ការចរចា | • ការអធិប្បាយ<br>• លំហាត់សម្តែងតួ |
| រសៀល | សង្ខេបវគ្គបណ្តុះបណ្តាល | |
| | វាយតម្លៃបញ្ចប់វគ្គ | |

***សូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធីនេះ ក្នុងករណីចាំបាច់។

## ធំរោងមេរៀនទី ២.១: យេនឌ័រ និងភេទ

គោលបំណង : នៅចុងបញ្ចប់នៃមេរៀននេះអ្នកចូលរួមនឹងអាច :

* ពន្យល់បានពីអត្ថន័យនៃយេនឌ័រនិងភេទ។
* រកឃើញពីភាពខុសគ្នារវាងយេនឌ័រនិងភេទ។

រយៈពេល : ប្រហែល៦០នាទី។

វិធីសាស្ត្រ : ពន្យល់បកស្រាយ និងសំណួរបំផុសគំនិត។

សំភារៈ : ក្តារខៀន ក្រដាសផ្ទាំងធំ និងហ្វឹត ។ល។

ឯកសារមេរៀន : ឯកសារមេរៀនទី ២.១ យេនឌ័រនិងភេទ។

រូបភាពទី២.១ក និងរូបភាពទី២.១ខ ។

របៀបសំរបសំរួល :

ក. សេចក្តីផ្តើម

១. អ្នកសំរបសំរួលពន្យល់ដល់អ្នកចូលរួមថាមេរៀនបន្តបន្ទាប់ចាប់ពីមេរៀនទី២.២ដល់មេរៀនទី២.៦ នឹងជួយធ្វើឱ្យអ្នកចូលរួមបានយល់កាន់តែច្បាស់ពីគោលគំនិតយេនឌ័រនិងទំនាក់ទំនងពីបញ្ហាយេនឌ័រនៅក្នុងសង្គម។

ខ. យេនឌ័រនិងភេទ

១. អ្នកសំរបសំរួលបង្ហាញរូបភាពបុរសនិងស្ត្រី (រូបភាពទី២.១កនិង២.១ខ) និងសួរទៅអ្នកចូលរួមពីភាពខុសប្លែកគ្នានៃរូបភាពទាំងពីរ។ សរសេរចំលើយរបស់អ្នកចូលរួមដាក់ក្រដាសផ្ទាំងធំ ឬក្តារខៀន។ សង្ខេបយោបល់អ្នកចូលរួមពាក់ពន្ធ័នឹងភាពខុសប្លែកគ្នារវាងបុរស និងស្ត្រី។

២. អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា តើអ្នកធ្លាប់ឮពាក្យ "យេនឌ័រ" ឬទេ? តើមានន័យដូចម្តេច? និងសរសេរចំលើយអ្នកចូលរួមដាក់ក្រដាសផ្ទាំងធំ។

៣. អ្នកសំរបសំរួលកំណត់ន័យរបស់ពាក្យ "យេនឌ័រ" និងពន្យល់ដល់អ្នកចូលរួមថា យេនឌ័រពាក់ពន្ធ័ទៅនឹងភាពខុសប្លែកគ្នានៃតួនាទី ការទទួលខុសត្រូវ និងការធ្វើសេចក្តីសំរេចរបស់ស្ត្រី និងបុរស។ ភាពខុសប្លែកគ្នាយេនឌ័រជាទូទៅកំណត់ឡើងដោយសារសង្គម ហើយអាចកែប្រែបានក៏ដោយសារសង្គមដែរ។ ឧទាហរណ៍ ស្ត្រីត្រូវបានសង្គមកំណត់ឱ្យធ្វើការងារដាំស្ល និងការងារផ្ទះសំម្បែងទាំងអស់ តែបុរសមិនត្រូវឱ្យធ្វើកិច្ចការទាំងនោះឡើយ ប៉ុន្តែបុរសត្រូវបានសង្គមកំណត់ថា ជាអ្នក

ធ្វើការមានតួនាទីជាអ្នកដឹកនាំ។ អ្នកសំរបសំរួលពន្យល់ឧទាហរណ៍ទាំងនេះដោយភ្ជាប់ទៅនឹងរូបភាពដែលបានពិភាក្សាពេលមុន។

៤. អ្នកសំរបសំរួលព្យាយាមពន្យល់ពីភាពខុសប្លែកគ្នារវាងភេទ និងយេនឌ័រ ដោយកំណត់ន័យរបស់ពាក្យភេទថា ភេទពាក់ពន្ធ័ទៅនឹងភាពខុសប្លែកគ្នាខាងជីវសាស្ត្ររវាងស្ត្រីនិងបុរស។ ឧទាហរណ៍ ភាពខុសគ្នាខាងជីវសាស្ត្រ គឺស្ត្រីមានផ្ទៃពោះ សំរាលកូន និងបំបៅដោះកូន ចំណែកបុរសមិនអាចធ្វើដូចនេះបានទេ។ ភាពខុសគ្នាទាំងអស់នេះមិនអាចកែប្រែបានឡើយ។

៥. អ្នកសំរបសំរួលត្រូវបំផុសឱ្យអ្នកចូលរួមផ្តល់ឧទាហរណ៍ និងសួរសំនួរឱ្យបានច្រើនទាក់ទងទៅនឹងយេនឌ័រ និងភេទ។

៦. អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថាមានចំងល់អ្វីទាក់ទងនឹងនិយមន័យនៃពាក្យ "យេនឌ័រ" "ភេទ" និងពាក្យ "តួនាទីយេនឌ័រ និង តួនាទីភេទ" និងឆ្លើយតបទៅនឹងសំនួររបស់អ្នកចូលរួម។

៧. អ្នកសំរបសំរួលចែកឯកសារមេរៀនទី២.១ ស្តីពីយេនឌ័រ និងភេទឱ្យអ្នកចូលរួម។

៨. អ្នកសំរបសំរួលសង្ខេបមេរៀន ដោយសួរត្រឡប់ទៅអ្នកចូលរួមពីគោលបំណងនៃប្រធានបទនេះ ឬ សួរទៅអ្នកចូលរួមថា តើពួកគាត់ទទួលបានអ្វីខ្លះ?

ᔕᔕᔕᔕ ☺☺☺ ᔕᔕᔕᔕ

# ឯកសារមេរៀនទី ២.១ក: យេនឌ័រ និង ភេទ

## ១. យេនឌ័រជាអ្វី?

យើងទាំងអស់បានដឹងហើយថាស្ត្រីនិងបុរសមានភាពខុសប្លែកគ្នា។ ក្នុងចំណោមនៃភាពខុសប្លែកគ្នាទាំងអស់នេះ ខ្លះជាភាពខុសគ្នាផ្នែកជីវសាស្ត្រ ភាពខុសគ្នាខ្លះទៀតពាក់ពន្ធ័ទៅនឹងតួនាទីការទទួលខុសត្រូវនិងសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសំរេចរបស់ស្ត្រីនិងបុរស។ យេនឌ័រពាក់ពន្ធ័ទៅនឹងភាពខុសគ្នារវាងតួនាទីការទទួលខុសត្រូវ និងការធ្វើសេចក្តីសំរេចរបស់ស្ត្រីនិងបុរស។



*"យេនឌ័រគឺជាទំនាក់ទំនងរវាងស្ត្រីនិងបុរសនៅក្នុងសង្គមគ្រួសារ និងក្នុងសង្គមទាំងមូលដែលពាក់ព័ន្ធនឹងការបែងចែកសិទ្ធិអំណាច លំដាប់ថ្នាក់ ឋានៈ តួនាទី ការងារពលកម្មដែលសង្គមបានកំណត់ឡើង"។ ដោយសង្គមជាអ្នកកំណត់នូវទស្សនៈនិងកត្តាដែលបណ្តាលឱ្យមានវិសមភាពនិងបណ្តាលឱ្យមានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងច្រើនដល់សង្គម ដូច្នេះសង្គមត្រូវតែរួមគ្នាកែប្រែ កែលំអនិងកាត់បន្ថយនូវបញ្ហាវិសមភាពទាំងនេះ ដើម្បីជួយជំរុញឱ្យប្រទេសជាតិមានការអភិវឌ្ឍបានលឿនលឿននិងមាននិរន្តរភាព ។*

**ភេទនិងយេនឌ័រ**

| ភេទ | យេនឌ័រ |
|---|---|
| កត្តា/លក្ខខណ្ឌជីវសាស្ត្រពីកំណើត | កត្តា/លក្ខខណ្ឌសង្គមមិនមែនពីកំណើត |
| ដូច្នេះ | ដូច្នេះ |
| មិនអាចកែប្រែបានទេ | អាចកែប្រែបាន |
| ឧទាហរណ៍<br>១. មានតែស្ត្រីដែលអាចបង្កើតកូនបាន។<br>២. មានតែបុរសទេដែលអាចផ្តល់មេជីវិតឈ្មោល។ | ឧទាហរណ៍<br>១. ស្ត្រី និងបុរសអាចធ្វើជាគ្រូបង្រៀនវិស្វករ ឬកម្មករ។<br>២. ស្ត្រី និងបុរសអាចមើលថែទាំកូននិងមនុស្សចាស់បានដូចគ្នា |

រូបធី ២.១ ក



រូបទី ២.១ ខ



គោលបំណង : នៅចុងបញ្ចប់នៃមេរៀននេះអ្នកចូលរួមនឹងអាច :

* រកឃើញពីភាពខុសគ្នារវាងតួនាទីយេនឌ័រទាំងបីប្រភេទ។
* ពន្យល់បានពីតម្លៃតួនាទីយេនឌ័រទាំងបីប្រភេទ។
* ឆ្លុះបញ្ចាំងពីការចូលរួមយ៉ាងសកម្មរបស់ស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍។

រយៈពេល : ប្រហែល៦០នាទី។

វិធីសាស្ត្រ : សំនួរបំផុសគំនិត និង ពិភាក្សាជាក្រុម។

សំភារៈ : ក្តារខៀន ក្រដាសផ្ទាំងធំ និងហ្វឺត ។ល។

ឯកសារមេរៀន : ឯកសារមេរៀនទី២.២ក. តួនាទីយេនឌ័រ។

របៀបសំរបសំរួល :

**ក. តួនាទីយេនឌ័រនៅក្នុងសង្គមនិងសហគមន៍**

១. អ្នកសំរបសំរួលចែកអ្នកចូលរួមជា ៣ ក្រុម។ សុំឱ្យអ្នកចូលរួមពិភាក្សាអំពីសំនួរ *"តើស្ត្រី.បុរស ធ្វើអ្វីខ្លះនៅក្នុងជីវភាពប្រចាំថ្ងៃនៅក្នុងសង្គមនិងសហគមន៍របស់គេ?"* ឱ្យពួកគេព្យាយាមគិតពីការងារជាក់ស្តែងនៅក្នុងមូលដ្ឋានរបស់គេ។ សុំឱ្យក្រុមនីមួយៗ សរសេរចំលើយរបស់ពួកគេ ហើយចាត់ចំលើយទាំងនោះជា៣ផ្នែកដូចក្នុងតារាង២.២ តួនាទីយេនឌ័រ (ដែលមាននៅទំព័រក្រោយនេះ) ។

**តារាង២.២. តួនាទីយេនឌ័រទាំងបីប្រភេទ**

| ការងារមានកំរៃ | ការងារគ្មានកំរៃ | ការងារសហគមន៍ |
|---|---|---|
| - | - | - |
| - | - | - |
| - | - | - |
| - | - | - |
| - | - | - |
| - | - | - |

២. អ្នកសំរបសំរួលឱ្យឧទាហរណ៍នៃប្រភេទការងារនីមួយៗ:

- *ការងារមានកំរៃ គឺជាការងារបង្កើតផលិតផលទំនិញ (ឧ. ផលិតស្រូវ) ឬជាសេវាកម្ម (ឧ. ការងារសាងសង់) ដើម្បីបង្កើនប្រាក់ចំណូល។*
- *ការងារគ្មានកំរៃ គឺដូចជាការងារថែទាំ ចិញ្ចឹមគ្រួសារ និងចំអិនអាហារសំរាប់គ្រួសារ ។ល។*
- *ការងារសហគមន៍ អាចជាការងារស្ម័គ្រចិត្ត ដូចជាចូលរួមវិភាគទានជាកំលាំងពលកម្មដើម្បីសាងសង់ផ្លូវនៅក្នុងស្រុក ឬចូលរួមក្នុងកិច្ចការរបស់ភូមិ។*

៣. បន្ទាប់ពីក្រុមនីមួយៗបានបំពេញតារាងនោះរួចហើយ អ្នកសំរបសំរួលសុំឱ្យពួកគេបកស្រាយថា តើភារកិច្ចណាខ្លះដែលភាគច្រើនត្រូវបានបំពេញដោយស្ត្រី ហើយភារៈកិច្ចអ្វីខ្លះដែលត្រូវបំពេញដោយអ្នកទាំងពីរ (ស្ត្រីនិងបុរសរួមគ្នា)។ អ្នកសំរបសំរួលសុំឱ្យពួកគេលើកឡើងពីការងារដែលស្ត្រីមិនត្រូវធ្វើ និងការងារដែលបុរសមិនត្រូវធ្វើនិងពន្យល់ពីមូលហេតុ ។

៤. អ្នកសំរបសំរួលសុំឱ្យក្រុមនីមួយៗឡើងបង្ហាញលទ្ធផលដល់ក្រុមធំ។ អ្នកសំរបសំរួលសង្ខេបលទ្ធផលរបស់ក្រុមទាំងបី។

៥. អ្នកសំរបសំរួលពន្យល់ថា នៅក្នុងសហគមន៍មានការងារដែលបុរសនិងស្ត្រីត្រូវធ្វើ ហើយក៏មានការងារដែលត្រូវសង្គមរាំងមិនឱ្យស្ត្រីឬបុរសធ្វើដែរ។ ការកំណត់នៃការងារទាំងនេះនាំទៅរកការបែងចែកនូវតួនាទីសំរាប់ស្ត្រីនិងបុរសនៅក្នុងសង្គម ដែលគេហៅថា "**តួនាទីយេនឌ័រ**" ។ ជាក់ស្តែងភារៈកិច្ចនិងការងារជាច្រើនអាចត្រូវបានបំពេញដោយបុរសនិងស្ត្រី ប៉ុន្តែដោយសារការកំណត់របស់សង្គមទើបការងាររបស់ពួកគេត្រូវបានបែងចែកផ្សេងៗគ្នា ហើយទទួលបានតម្លៃខុសៗគ្នា ។

**ខ. តំលៃនៃការងាររបស់បុរសនិងតំលៃនៃការងាររបស់ស្ត្រី**

១. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមគិតអំពីសារៈសំខាន់នៃការងារទាំងបីប្រភេទនៅក្នុងសហគមន៍ពួកគេ "តើការងារប្រភេទណាមួយដែលមានសារៈសំខាន់ជាងគេបំផុត? ហេតុអ្វី?"

២. អ្នកសំរបសំរួលលើកឡើងថា នៅព្រះរាជាណាចក្រកម្ពុជា ការងារមានកំរៃត្រូវបានគេចាត់ទុកថាជាការងារមានសារៈសំខាន់ជាងគេបំផុត ហើយភាគច្រើនជាការងារដែលធ្វើដោយបុរស។ ការងារមិនមានកំរៃដូចជាការងារសំអាតផ្ទះ ការងារថែទាំកូនចៅ ការងារថែទាំស្រែចម្ការ ។ល។ ដែលភាគច្រើនត្រូវបានបំពេញដោយស្ត្រី ត្រូវបានគេចាត់ទុកថាជាការងារមិនសូវមានសារៈសំខាន់ ហើយមិនត្រូវបានគេឃើញថាជាការងារពិតប្រាកដទេ។ អ្នកសំរបសំរួលសួរអ្នកចូលរួមថា *តើការលើកឡើងខាងលើនេះជាការពិតដែរឬទេនៅក្នុងសហគមន៍របស់ពួកគេ?*

៣. អ្នកសំរបសំរួលសង្ខេបដោយនិយាយថា ការងារទាំងបីប្រភេទនេះមានសារសំខាន់ដូចៗគ្នាពីព្រោះវាមានទំនាក់ទំនងគ្នាទៅវិញទៅមក ហើយការងារទាំងអស់សុទ្ធតែរួមចំណែកដល់ការអភិវឌ្ឍន៍គ្រួសារនិងសង្គម។ ស្ត្រី-បុរសអាចធ្វើការងារទាំងបីប្រភេទបានដូចគ្នាដោយមិនចាំបាច់គិតពីភេទ (ស្រី-បុរស) ឡើយ។ ជាទូទៅ ស្ត្រីតែងតែជួយរំលែកបន្ទុកការងាររបស់បុរសក្នុងការបង្កើនប្រាក់ចំណូលលើសពីនេះទៀត ស្ត្រីត្រូវទទួលបន្ទុកការងារមិនបានកំរៃដោយខ្លួនឯង។ ជាលទ្ធផលស្ត្រីមានការងារហួសបន្ទុកនិងមានភាពហត់នឿយយ៉ាងខ្លាំង។ បន្ថែមពីលើនេះទៀតដោយការងាររបស់ស្ត្រីត្រូវបានសង្គមគិតថាមិនសូវមានតំលៃ ទើបស្ត្រីភាគច្រើនយល់ថា ខ្លួនមិនសូវមានសារៈសំខាន់នៅក្នុងសង្គម និងមិនសូវមានជំនឿជឿជាក់លើខ្លួនឯង។

៤. អ្នកសំរបសំរួលចែកឯកសារមេរៀនទី២.២ក និងសួរអ្នកចូលរួមថា តើពួកគេមានចំងល់ទាក់ទងទៅនឹងតួនាទីនិងតម្លៃការងារទាំងបីប្រភេទនេះឬទេ? ឆ្លើយតបទៅនឹងសំនួររបស់អ្នកចូលរួម។

៥. អ្នកសំរបសំរួលធ្វើសេចក្តីសង្ខេបមេរៀន និងពន្យល់ប្រាប់អ្នកចូលរួមថា ការពន្យល់ពីតួនាទីរបស់បុរស និងស្ត្រីមាននៅក្នុងឯកសារមេរៀនទី២.២ក ដែលទើបតែបានចែកជូន។

៦. បើមានពេលគ្រប់គ្រាន់ អ្នកសំរបសំរួលត្រូវសុំឱ្យអ្នកចូលរួមប្រាប់ពីឈ្មោះអភិបាលខេត្ត ប្រធានភូមិ ប្រធានសហគមន៍ ប្រធានអង្គការ ។ល។ អ្នកសំរបសំរួលសរសេរឈ្មោះទាំងអស់នោះលើក្តារខៀន។ សួរឈ្មោះទាំងនោះម្តងម្នាក់ថា តើជាស្ត្រី-បុរស (អ្នកទាំងនោះភាគច្រើនជាបុរស)។ លំហាត់នេះ គឺដើម្បីបង្កើនការយល់ដឹងរបស់អ្នកចូលរួមលើវិសមភាពរបស់ស្ត្រីនិងបុរសក្នុងការធ្វើសេចក្តីសំរេចនៅក្នុងសហគមន៍របស់ពួកគេ។

# ឯកសារមេរៀនទី២.២ក: គោលគំនិតយេនឌ័រ

## ១. តួនាទីយេនឌ័រ និងតួនាទីភេទ

នៅពេលដែលយើងធ្វើការពិនិត្យលើតួនាទីរបស់មនុស្សនៅក្នុងសង្គមទាំងមូល យើងអាចឃើញថា ស្ត្រីនិងបុរសមានតួនាទីខុសៗគ្នា។ ក្នុងចំណោមនៃតួនាទីទាំងនេះ តួនាទីខ្លះជាតួនាទីផ្នែកជីវសាស្ត្ររបស់ស្ត្រីនិងបុរស តួនាទីខ្លះទៀតជាតួនាទីដែលកំណត់ឡើងដោយសារច្បាប់ទម្លាប់នានានិងការរំពឹងទុករបស់សង្គម។ តួនាទីយេនឌ័រសំដៅទៅលើតួនាទីទាំងឡាយណាដែលបានរៀបចំឡើងទៅតាមការកំណត់របស់សង្គមដែលយល់ឃើញថាសមស្របសំរាប់ស្ត្រីឬបុរស។ តួនាទីយេនឌ័រជាទូទៅកំណត់ឡើងដោយសារសង្គមហើយអាចកែប្រែបានក៏ដោយសារសង្គម។ តួនាទីយេនឌ័រមានភាពខុសគ្នាពីសង្គមមួយទៅសង្គមមួយពីសម័យមួយទៅសម័យមួយ។ ផ្ទុយទៅវិញតួនាទីផ្នែកជីវសាស្ត្រ (ភេទ) របស់បុរសនិងស្ត្រីមិនអាចផ្លាស់ប្តូរបានទេ ។



ជាទូទៅនៅក្នុងសង្គម ការងារថែទាំកូនចៅត្រូវបានគេគិតថាជាការទទួលខុសត្រូវរបស់ស្ត្រី ទោះបីជាក់ស្តែងការងារទាំងអស់នេះមិនមែនជាការទទួលខុសត្រូវខាងជីវសាស្ត្ររបស់ស្ត្រីក៏ដោយ។ ការថែទាំកូនចៅ គឺជាការងារដែលស្ត្រីនិងបុរសអាចធ្វើ និងចែករំលែកនូវការទទួលខុសត្រូវនេះបាន។ ជារួមសង្គមជាអ្នកកំណត់និងបង្គាត់បង្ហាញនូវតួនាទី និងការទទួលខុសត្រូវទាំងអស់នេះទៅដល់ស្ត្រីនិងបុរស។

## ២. ការងារនិងយេនឌ័រ

តួនាទីនិងភារកិច្ចទាំងអស់ត្រូវបានចែកចេញជាប្រភេទការងារទាំងបីដូចខាងក្រោម:

### ក. ការងារមានកំរៃ

ការងារផលិតឬការងារមានកំរៃ រួមមានការងារកែច្នៃម្ហូបអាហារ ការងារផលិតកម្ម និងការងារសេវាកម្មផ្សេងៗ សំរាប់ចិញ្ចឹមជីវិតនិងដើម្បីរកប្រាក់ចំណូល។ ស្ត្រី និងបុរសអាចចូលរួមក្នុងការងារនេះបានដូចគ្នា ប៉ុន្តែតួនាទី និងការទទួលខុសត្រូវរបស់ពួកគេខុសៗគ្នា ទៅតាមការបែងចែកកំលាំងការងារតាមការកំណត់របស់សង្គម។ នៅក្នុងសង្គមភាគច្រើនការងារមានកំរៃ ដូចជា ការងារ

គ្រប់គ្រងការងារបច្ចេកទេស និងការងារដែលមានប្រាក់កំរៃច្រើន ត្រូវបានសង្គមចាត់ទុកថាជាការងាររបស់បុរស។ នៅក្នុងសង្គមនាពេលបច្ចុប្បន្ននៅតែចាត់ទុកថា បុរសគឺជាអ្នកដើរតួដ៏សំខាន់ក្នុងការងាររកកំរៃនិងជាមេគ្រួសារ ប៉ុន្តែជាក់ស្តែង ស្ត្រីក៏ជាអ្នកដើរតួដ៏សំខាន់ក្នុងការរកប្រាក់ចំណូលសំរាប់ចិញ្ចឹមគ្រួសារដូចបុរសដែរ។ ម្យ៉ាងទៀត ស្ត្រីក៏បានជួយដល់បុរសក្នុងការរកចំណូលចិញ្ចឹមគ្រួសារផងដែរ។

**ខ. ការងារដែលមិនមានកំរៃ**

ការងារមិនមានកំរៃ រួមបញ្ចូលការងារដែលធ្វើឡើងដោយស្ត្រីនិងបុរសដោយមិនបានទទួលប្រាក់ចំណូល។ ក្នុងនេះ មានការងារចាំបាច់សំរាប់គ្រួសារដែលទាក់ទងនឹងការងារសំអាតផ្ទះសម្បែង និងថែទាំគ្រួសារ។ ការងារទាំងនេះចំណាយពេលនិងកំលាំងយ៉ាងច្រើន ហើយត្រូវគេចាត់ទុកជាភារកិច្ចរបស់ស្ត្រី-ក្មេងស្រី។ ជាទូទៅការងារនេះមិនបានទទួលកំរៃទេ ហើយមិនទាន់ត្រូវបានគេឱ្យតម្លៃខ្ពស់នៅឡើយ។ ការងារទាំងអស់គឺជាឧបសគ្គរាំងដល់ការចូលរួម និងការទទួលបាននូវឱកាសរបស់ស្ត្រីក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។

**គ. ការងារសហគមន៍**

ការងារសហគមន៍ រួមមាន ការងារដែលទាក់ទងនឹងទៅការរៀបចំព្រឹត្តិការណ៍និងសកម្មភាពរួមរបស់សង្គម និងសេវាកម្មផ្សេងៗនៅក្នុងសហគមន៍។ ភាគច្រើន ស្ត្រីស្ម័គ្រចិត្តចូលរួមធ្វើសកម្មភាពទាំងនេះដោយពុំបានទទួលកំរៃ ហើយដែលជាការបន្ថែមបន្ទុកទៅលើការងារផ្ទះសម្បែង ការងារថែទាំគ្រួសាររបស់ពួកគេ។ ថ្វីត្បិតតែស្ត្រីចូលរួមច្រើនក្នុងការងារនេះ តែភាគច្រើនគ្រាន់តែជាសមាជិកឬអ្នកចូលរួមធម្មតាតែប៉ុណ្ណោះ ពុំសូវមានតួនាទីជាអ្នកគ្រប់គ្រងឬធ្វើសេចក្តីសំរេចឡើយ។

**សន្និដ្ឋាន**

ការងារដែលស្ត្រីនិងបុរសធ្វើ អាចបញ្ចូលទៅក្នុងប្រភេទការងារទាំងបីនេះ។ នៅប្រទេសកម្ពុជា ស្ត្រីចំណាយពេលវេលានិងកម្លាំងច្រើនលើការងារគ្មានកំរៃ រីឯបុរសធ្វើការងារមានកំរៃ។ ការងារគ្មានកំរៃនេះ ពុំបានទទួលតម្លៃដូចការងារមានកំរៃឡើយ។ ស្ទើរតែគ្រប់សង្គមទាំងអស់ ការងារមានកំរៃមានតម្លៃ ជាងការងារគ្មានកំរៃ។ ដូចនេះ បានជាសង្គមឱ្យតម្លៃលើការងារបុរសជាងការងារស្ត្រី។ នៅក្នុងគ្រួសារជាច្រើន ស្ត្រីធ្វើការងារគ្មានកំរៃច្រើន ព្រមទាំងធ្វើការងារមានកំរៃជាមួយស្វាមីគេទៀតផង។ ម្យ៉ាងទៀត យើងអាចនិយាយថា ការងារជាច្រើនដែលស្ត្រីធ្វើមិនទាន់មានការទទួលស្គាល់ និងអោយតម្លៃពីសង្គមទេ។

ឈឈឈ ☺☺☺ ឈឈឈ

# គំរោងមេរៀនទី ២.៣: វដ្តនៃជីវិតរបស់ស្ត្រី

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះអ្នកចូលរួមនឹងអាច :

* យល់ដឹងពីបញ្ហាដាក់លាក់ការរើសអើង និងគ្រោះថ្នាក់ដែលស្ត្រីប្រឈមមុខក្នុង វដ្តនៃជីវិតរបស់ពួកគេ តាំងពីចាប់កំណើតរហូតដល់ស្លាប់។
* កំណត់បានពីកត្តាផ្សេងដែលបណ្តាលឱ្យមានគ្រោះថ្នាក់នៅក្នុងដំណាក់កាលនីមួយៗនៃវដ្តជីវិត។

**រយៈពេល** : ប្រហែល១២០នាទី

**វិធីសាស្ត្រ** : ការអធិប្បាយ និងការពិភាក្សាជាក្រុម

**សំភារៈ** : ក្តារខៀន ក្រដាសផ្ទាំងធំ និង ហ្វឺត។

**ឯកសារមេរៀន** : ឯកសារមេរៀនទី ២.៤ វដ្តនៃជីវិតរបស់ស្ត្រី។

**របៀបសំរបសំរួល** :

១. អ្នកសំរបសំរួលចាប់ផ្តើមដោយសួរអ្នកចូលរួមថា *តើពួកគាត់ធ្លាប់ដែលបានឮពាក្យ "វដ្តជីវិត" ដែរឬទេ?* ពន្យល់ពួកគាត់ថាវដ្តជីវិតមានន័យថា ខួបរបស់មនុស្សចាប់តាំងពីរយៈពេលមានកំណើតរហូតដល់ស្លាប់។ សុំឱ្យអ្នកចូលរួមគិតពីដំណាក់កាលផ្សេងៗ ក្នុងវដ្តជីវិតរបស់ពួកគេ។ អ្នកសំរបសំរួលសរសេរចំលើយរបស់ពួកគេនៅលើក្តារខៀន។

២. អ្នកសំរបសំរួលធ្វើសេចក្តីសង្ខេបដោយនិយាយថា មនុស្សម្នាក់បានឆ្លងកាត់ដំណាក់កាលផ្សេងៗគ្នានៅក្នុងជីវិតរបស់ខ្លួន ដូចជាដំណាក់កាលនៅជាទារក កុមារភាព វ័យជំទង់ ពេញវ័យ វ័យមធ្យម និងវ័យចំណាស់។ នៅដំណាក់កាលនីមួយៗ ស្ត្រីបុរសមានភារៈកិច្ចផ្សេងៗ ដែលត្រូវធ្វើ មានការរំពឹងទុកផ្សេងៗពីអ្នកដទៃមកលើស្ត្រី ហើយដែលបណ្តាលអោយស្ត្រីប្រឈមមុខនឹងគ្រោះថ្នាក់និងការលំបាកផ្សេងៗ។

៣. អ្នកសំរបសំរួលពន្យល់ថា មេរៀននេះគឺដើម្បីពិនិត្យមើលលើគ្រោះថ្នាក់ ការរើសអើង និងបញ្ហាផ្សេងៗ ដែលស្ត្រីភាគច្រើនបានជួបប្រទះនៅក្នុងសហគមន៍របស់ពួកគាត់នៅក្នុងកំឡុងពេលនៃដំណាក់កាលនីមួយៗនៃជីវិតរបស់ពួកគាត់។ គ្រោះថ្នាក់ ការរើសអើង និងបញ្ហាទាំងនេះនាំឱ្យជីវិតរបស់ពួកគេមានការលំបាកកាន់តែខ្លាំងឡើង។ ឧទាហរណ៍ ចាប់ពីអាយុ៧ដល់១២ឆ្នាំ កុមារី

មិនអាចទៅសាលារៀនដោយគ្រួសាររបស់នាងមិនបញ្ជូននាងទៅសាលារៀន។ (អ្នកសំរបសំរួលអាចបន្ថែមចំនុចមួយចំនួនទៀត ដើម្បីលើកជាឧទាហរណ៍ ដែលមាននៅក្នុងមេរៀនទី២.៣)

៤. អ្នកសំរបសំរួលចែកក្រុមពិភាក្សាជាបីឬបួនក្រុមតាមចំនួនអ្នកចូលរួមដោយឱ្យក្រុមនីមួយៗពិភាក្សាពីបញ្ហានិងការរើសអើងដែលកុមារី-កុមារា និងស្ត្រី-បុរសប្រឈមមុខនៅក្នុងដំណាក់កាលទាំង៧នៃវដ្តជីវិតគឺអាយុពី០-៦ឆ្នាំ ៧-១៧ឆ្នាំ ១៨-២៥ឆ្នាំ ២៦-៤៥ឆ្នាំ ពី៤៦ដល់ចាស់។ សរសេរលទ្ធផលនៃការពិភាក្សាលើក្រដាសផ្ទាំងធំឬក្តារខៀន។

៥. ក្រុមនីមួយៗឡើងបង្ហាញពីលទ្ធផលនៃការពិភាក្សា។ បន្ទាប់មកអ្នកសំរបសំរួលសង្ខេបចំណុចសំខាន់ៗក្នុងលទ្ធផលរបស់ក្រុមពិភាក្សាដោយផ្តោតលើភាពរើសអើង និងបញ្ហារបស់ស្ត្រី-កុមារីដែលជួបប្រទះក្នុងមួយជីវិតរបស់ពួកគេ។ (អ្នកសំរបសំរួលអាចប្រើប្រាស់មេរៀនទី ២.៣ ដើម្បីពន្យល់ដល់អ្នកចូលរួម)។

៦. អ្នកសំរបសំរួលចែកឯកសារមេរៀនទី២.៣ ដល់អ្នកចូលរួម និងបង្ហាញនូវគោលគំនិតសំខាន់ៗនៅក្នុងឯកសារមេរៀនទី២.៣ និងពន្យល់ចំណុចនានាដែលអ្នកចូលរួមមិនបានលើកឡើង។

៧. អ្នកសំរបសំរួលសួរអ្នកចូលរួមថា តើពួកគេមានចំងល់ និងយោបល់អ្វីទាក់ទងទៅនឹងការបង្ហាញនោះដែរឬទេ? អ្នកសំរបសំរួលត្រូវផ្តល់ពេលវេលាឱ្យបានគ្រប់គ្រាន់សំរាប់អ្នកចូលរួមអានឯកសារមេរៀន និងមានចម្ងល់។ អ្នកសំរបសំរួលឆ្លើយនឹងសំនួររបស់អ្នកចូលរួម។

៨. អ្នកសំរបសំរួលសង្ខេបដោយនិយាយថា ស្ត្រី-កុមារីត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ បញ្ហានិងការរើសអើងច្រើនយ៉ាងនៅក្នុងជីវិតរបស់ពួកគេតាំងពីកើតរហូតដល់ស្លាប់។ បញ្ហា និងគ្រោះថ្នាក់ខ្លះបណ្តាលមកពីតម្រូវការរបស់ពួកគេទាក់ទងទៅនឹងបញ្ហាសុខភាពបន្តពូជ (ឧទាហរណ៍ ការថែទាំសុខភាពក្នុងកំឡុងពេល និងក្រោយពេលសម្រាលកូន) ហើយជាទូទៅតំរូវការទាំងនេះមិនសូវបានដោះស្រាយឡើយ។ គ្រោះថ្នាក់ខ្លះទៀត បណ្តាលមកពីការប្រព្រឹត្ត និងការឱ្យតម្លៃរបស់សង្គមមកលើស្ត្រី-កុមារី និងបុរស-កុមារាមិនស្មើគ្នាតាំងពីពេលដែលពួកគេចាប់កំណើតមក។ ជាលទ្ធផលជីវិតរបស់ស្ត្រី-កុមារីតែងតែមានការលំបាក និងមិនមានសមធម៌ក្នុងការទទួលបាននូវតម្រូវការទទួលបាននូវឱកាសនិងការគ្រប់គ្រងធនធាន និងការធ្វើសេចក្តីសំរេច។ នៅក្នុងមេរៀនបន្ទាប់នឹងរៀបរាប់ពីផលប៉ះពាល់ជាអវិជ្ជមានដែលបណ្តាលមកពីបញ្ហាវិសមភាពយេនឌ័រ។

កំណត់សំគាល់សំរាប់អ្នកសំរបសំរួល:

អ្នកសំរបសំរួលត្រូវព្យាយាមពន្យល់និងលើកទឹកចិត្តឱ្យអ្នកចូលរួមឱ្យយល់ថា "*បញ្ហាយេនឌ័រ*" គឺជារបៀបទំនាក់ទំនងអសមធម៌រវាងបុរស-ស្ត្រីដែលបាននិងកំពុងរៀនសូត្រពីសង្គម ចាប់ផ្តើមតាំងពីសង្គមគ្រួសារឡើងទៅ។ ហេតុដូច្នេះទាំងកុមារី-កុមារា និងស្ត្រី-បុរស ត្រូវតែ យល់ដឹងអំពីរបៀប

កំណត់ទំនាក់ទំនងទាំងនេះ ដើម្បីរកយុទ្ធសាស្ត្រសមស្របក្នុងការផ្លាស់ប្តូរនូវទំនាក់ ទំនងអវិជ្ជមានទាំងអស់នេះ។ ការផ្លាស់ប្តូរនេះមិនមែនធ្វើតែជាមួយស្ត្រីនោះទេ ត្រូវតែមានការទទួលខុសត្រូវទាំងស្រុងពីសង្គម ដែលក្នុងនោះមានទាំងស្ត្រី-បុរស ទើបអាចផ្លាស់ប្តូរនូវឥរិយាបថនិងផ្នត់គំនិតនៃការរើសអើងទាំងនេះបាន។

## ឯកសារមេរៀនទី២.៤ : វដ្តជីវិតរបស់ស្ត្រី

នៅក្នុងសង្គមកម្ពុជា ស្ត្រី-កុមារី និងបុរស-កុមារាចាប់តាំងពីពេលដែលពួកគេកើតរហូតដល់បាត់បង់ជីវិត ពួកគេបានទទួលការចិញ្ចឹមនិងការប្រព្រឹត្តពីសង្គមមិនដូចគ្នាទេ។ ការប្រព្រឹត្តខុសៗគ្នានេះ បានកំណត់នូវភារកិច្ច តួនាទី ការទទួលបានការគ្រប់គ្រងលើធនធាន និងការធ្វើសេចក្តីសំរេចរបស់ស្ត្រីនិងបុរសខុសៗគ្នាដែរ។ ដូចបានអធិប្បាយខាងលើនេះ យើងអាចមើលឃើញថា ស្ត្រី-កុមារីមានស្ថានភាពទាបក្នុងលទ្ធភាពទទួលបាននូវធនធាន និងការគ្រប់គ្រងលើធនធានតិចជាងបុរស-កុមារាដែលបណ្តាលឱ្យមានផលវិបាក និងគ្រោះថ្នាក់ដល់សុខុមាលភាពរបស់ស្ត្រី-កុមារី។

បន្ថែមពីលើនេះទៀត ស្ត្រីនិងបុរសមានតួនាទីខុសគ្នាក្នុងការបង្កើតកូន និងការបំបៅដោះកូនទៅក្នុងវ័យបន្តពូជរបស់ពួកគេ។ ដូចនេះ នៅក្នុងកំឡុងពេលនោះ ស្ត្រី និងបុរសមានតម្រូវការថែទាំសុខភាពខុសៗ គ្នា។ ស្ត្រីមានតំរូវការថែ្នកសុខភាពច្រើនជាងបុរស ដោយសារការបង្កើតកូន និងការបំបៅដោះកូន។ តែតម្រូវការពិសេសទាំងនេះរបស់ស្ត្រីភាគច្រើន មិនសូវបានដោះស្រាយទេ ជាលទ្ធផលបណ្តាលឱ្យមានផលវិបាក និងគ្រោះថ្នាក់កាន់តែខ្លាំងឡើងដល់សុខភាព និងសុខុមាលភាពរបស់ស្ត្រី។

នៅពេលយើងក្រឡេកមើលទៅលើវដ្តជីវិតរបស់ស្ត្រី យើងត្រូវពិនិត្យមើលទៅភាពខុសគ្នា និងទំនាក់ទំនងទាំងអស់នេះលើគ្រប់ដំណាក់កាលទាំងអស់នៃវដ្តជីវិត។ ក្មេងស្រី ក្មេងប្រុសជាច្រើនចាប់ផ្តើមទទួលនូវភាពមិនស្មើគ្នា និងគ្រោះថ្នាក់តាំងពីវ័យទារក តែនៅពេលពួកគេធំឡើង គុណវិបត្តិ និងគ្រោះថ្នាក់របស់ស្ត្រីចាប់ផ្តើមមានទំហំធំជាងបុរស ហើយដែលបណ្តាលឱ្យគម្លាតនៃបញ្ហាយេនឌ័រកាន់តែមានទំហំធំឡើង។

### ទារក



ទារក ១នាក់ ក្នុងចំណោមទារក១០នាក់ អាចត្រូវស្លាប់មុនថ្ងៃកំណើតរបស់ពួកគេ។ មានទារកតែ១នាក់ក្នុងចំណោមទារក១០នាក់ ដែលអាចដកដង្ហើមក្រោយពីការសម្រាល។ ពាក់កណ្តាលនៃចំនួនទារកមានបញ្ហាកង្វះជីវជាតិ។ ទារកនៅកម្ពុជាភាគច្រើនចាប់តាំងពីពេលដែល ពួកគេកើតរហូតដល់អាយុ១ឆ្នាំប្រឈមមុខនឹងគ្រោះថ្នាក់នៃកង្វះជីវជាតិ មានជំងឺនិងការស្លាប់។ គ្រោះថ្នាក់ទាំងនេះភាគច្រើន មានភាពប្រហាក់ប្រហែលគ្នារវាងក្មេងស្រីនិងក្មេងប្រុស ហើយ

អាចបន្តកាន់តែធ្ងន់ធ្ងរនៅពេលពួកគេធំឡើង។ ជាលទ្ធផល នៅថ្ងៃកើតដំបូង ទារកអាចមិនគ្រប់ទម្ងន់ក្រិន ឬតូច។ ពួកគេស្ទើរតែមិនអាចបៅបានភ្លាមឬមិនអាចបៅតែទឹកដោះមួយមុខនៅក្នុងកំឡុងពេល៤ទៅ៦ខែដំបូងទេ។ ម្តាយរបស់ទារកភាគច្រើនអាចមិនចេះពីរបៀបបញ្ចុកអាហារសមស្របបន្ថែមដល់ទារក។ ពេលខ្លះទាំងទារក-ទារិកាអាចមិនទទួលបានការចាក់ថ្នាំបង្ការជំងឺផ្សេងៗពេញលេញទេ។

| ទារិកា | ទារក |
|---|---|
| ទារិកា អាចមិនទទួលបាននូវការថ្នាក់ថ្នមពេញលេញដូចទារកទេ ជាពិសេសចំពោះគ្រួសារដែលមិនមានកូនប្រុសនិងគ្រួសារដែលមានកូនដំបូង។ ការចង់បានកូនប្រុសក្នុងចំណោមគ្រួសារនានានៅតែមានកំរិតខ្ពស់ លើកលែងតែគ្រួសារណាដែលទាមទារចង់ប្រើកំលាំងពលកម្មកូនស្រីប៉ុណ្ណោះ។ | ចំពោះទារក ជាពិសេសចំពោះកូនដំបូងគឺជាការរីករាយនិងមោទនភាពរបស់គ្រួសារ។ |
| មានជំនឿខ្លះថា ទារិកាអាចបៅបានត្រឹមតែ១៨-២០ខែ តែទារកអាចបៅដល់២៤-៣៦ខែ។ ក្នុងនេះដោយសារការមានជំនឿថា កាលណាកូនស្រីបៅយូរអាចរឹងនិងមានតំរូវការផ្លែកភេទខ្ពស់ ដែលចំណុចនេះប្រឆាំងទៅនឹងប្រពៃណីទំនៀមទម្លាប់។ រីឯទារកវិញត្រូវមានកម្លាំងខ្លាំង រាងកាយមាំមួន។ | កូនប្រុសមានសារៈសំខាន់ណាស់សំរាប់បន្តពូជអម្បូរគ្រួសារ។ |

## <u>វ័យកុមារ</u>



កុមារ១នាក់ ក្នុងចំណោមកុមារ៥នាក់ មិនទទួលបានការ ចាក់ថ្នាំបង្ការជំងឺផ្សេងៗពេញលេញទេ។ ជាទូទៅកុមារច្រើនមានជំងឺរាគរូស។ ពាក់កណ្តាលនៃចំនួនកុមារមានបញ្ហាកង្វះជីវជាតិ។ ចាប់ពីអាយុ១ឆ្នាំ ដល់អាយុ៦ឆ្នាំ កុមារចាប់ផ្តើមរៀនអំពីអ្វីដែលក្មេងស្រីត្រូវធ្វើ និងអ្វីដែលក្មេងប្រុសត្រូវធ្វើ។ ការទទួលបានផ្នែកម្ហូបអាហារ និងការយកចិត្តទុកដាក់ផ្នែក សុខភាពនៅតែជាបញ្ហាសំរាប់កុមារជាច្រើន។ ទាំងកុមារី និងកុមារាត្រូវប្រឈមមុខនឹងគ្រោះថ្នាក់នៃកង្វះជីវជាតិ ជំងឺ និងការស្លាប់។

| កុមារី | កុមារា |
|---|---|
| កុមារីត្រូវបានគេបង្រៀនឱ្យនិយាយទន់ភ្លន់សុភាពរាបសារ និងឱ្យចេះស្តាប់បង្គាប់ យកគំរូតាមម្តាយ និងឱ្យជួយធ្វើការងារនៅក្នុងផ្ទះ។ កុមារីត្រូវបានគេប្រាប់ថា តួនាទីរបស់ស្ត្រីជាតួនាទីបន្ទាប់បន្សំ ជាការងារតូចតាច ស្ត្រីមិនអាចមានតួនាទីជាអ្នកដឹកនាំទេ។ កុមារីមិនត្រូវមានការទាមទារ ឬជជែកតវ៉ាអ្វីទេហើយពួកគេត្រូវនៅតែផ្ទះ និងស្តាប់បង្គាប់ចាស់ទុំ។<br>កុមារី ច្រើនតែចាប់ផ្តើមចូលរៀននៅសាលាបឋមសិក្សានៅពេលក្រោយអាយុ៦ឆ្នាំ ហើយអ្នកខ្លះអាចមិនបានចូលរៀនទៀតផង ។ | កុមារាត្រូវបានបង្រៀនអោយក្លាហានជាអ្នកដឹកនាំ ហើយអាចទៅទីកន្លែងណាក៏បាន។ បន្ថែមលើនេះ កុមារាអាចមានឱកាសទៅសង្គមខាងក្រៅច្រើន ។ ទង្វើទាំងនេះផ្តល់នូវលទ្ធផលជាវិជ្ជមាន ដោយកាត់បន្ថយការមានជម្ងឺ បង្កើននូវជីវជាតិ និងភាពជឿជាក់លើខ្លួនឯង ភាពដឹកនាំ និងការចាត់ចែងដល់ក្មេងប្រុស។ |

**ការអនុវត្តន៍សំរាប់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៃព្រះរាជាណាចក្រកម្ពុជា**

**គោលដៅទី ១ :** កាត់បន្ថយភាពក្រីក្រនិងភាពអត់ឃ្លាន

**គោលដៅទី ៥ :** កាត់បន្ថយការស្លាប់របស់កុមារ

## កុមារធំ

ក្មេងស្រីតិចជាងពាក់កណ្តាលបានបញ្ចប់ការអប់រំកំរិតបឋមសិក្សា រីឯក្មេងប្រុសវិញជាងពាក់កណ្តាលបានបញ្ចប់ការអប់រំកំរិតនេះ។

ក្នុងចំណោមកុមារ១០នាក់ មានកុមារ១នាក់ចូលរួមសកម្មក្នុងផ្នែកសេដ្ឋកិច្ច។



ការអប់រំគឺជាជំហានដំបូងនៃវដ្តជីវិតដើម្បីទទួលបានការងារមានកំរៃល្អ។ ប្រសិនបើក្មេងស្រីមិនបានទទួលការអប់រំល្អនោះទេ មួយជីវិតនាងនឹងត្រូវជួបប្រទះនូវការលំបាកក្នុងការរកការងារដែលមានកំរៃធ្វើ។ នៅប្រទេសកម្ពុជា ការបោះបង់ចោលសាលា និងការរៀនត្រួតថ្នាក់មានកំរិតខ្ពស់។ កុមារជាច្រើនមិនបានបញ្ចប់ការអប់រំកំរិតបឋមសិក្សា។ ទោះបីជាផ្លូវការ ការអប់រំមិនចាំបាច់បង់ប្រាក់ តែការបង់ប្រាក់ក្រៅនិងចំណាយផ្សេងៗធ្វើឱ្យ ការអប់រំកុមារជួបប្រទះការលំបាក។ម្យ៉ាងទៀត ប្រសិនបើឪពុកម្តាយមិន

មានលទ្ធភាពបញ្ជូនកូនរបស់ខ្លួនទាំងអស់អោយទៅសាលារៀន ពួកគាត់ច្រើនតែបញ្ជូនកូនប្រុសឱ្យទៅសាលារៀន។

| ក្មេងស្រី | ក្មេងប្រុស |
|---|---|
| ចាប់ពីអាយុ៦ឆ្នាំ ដល់១២ឆ្នាំ កុមារីច្រើនបោះបង់ការសិក្សាចោលហើយទៅរៀនមិនសូវបានទៀងទាត់ទេ។ ពួកគេអាចរៀនមិនបានចប់កំរិតបឋមសិក្សាហើយដែលធ្វើឱ្យពួកគេមិនអាចបន្តការសិក្សានៅកំរិតខ្ពស់បាន។ | ក្មេងប្រុសត្រូវបានគេលើកទឹកចិត្តឱ្យទៅរៀននិងជំរុញឱ្យច្រើនរៀន។ |
| ជាទូទៅ ក្មេងស្រីធ្វើការប្រមាណជា ១៣ម៉ោងក្នុង១ថ្ងៃ នៅក្នុងរដូវវស្សា និង១៥ម៉ោងនៅក្នុងរដូវប្រាំង។ | ជាទូទៅ ក្មេងប្រុសធ្វើការប្រមាណ១២ម៉ោងក្នុង១ថ្ងៃនៅក្នុងរដូវវស្សានិង១០ម៉ោងនៅក្នុងរដូវប្រាំង។ |
| ក្នុងដំណាក់កាលនេះ តួនាទីយេនឌ័រនិងតួនាទីបន្ទាប់បន្សំរបស់ក្មេងស្រីត្រូវបានអោយឃើញកាន់តែច្បាស់ឡើង។ ក្មេងស្រីត្រូវនៅជួយធ្វើការងារក្នុងផ្ទះ និងត្រូវបានអប់រំឱ្យនិយាយសុភាពស្លូតបូតស្តាប់បង្គាប់និងទន់ភ្លន់។ | ក្នុងដំណាក់កាលនេះ តួនាទីយេនឌ័រកាន់តែបង្ហាញឱ្យឃើញច្បាស់។ ក្មេងប្រុសត្រូវផ្តោតលើការរៀនសូត្រពីសង្គមខាងក្រៅ ត្រូវគ្រប់គ្រងសង្គមគ្រួសារនិងមិនត្រូវធ្វើការងារក្នុងផ្ទះឡើយ។ |
| ក្មេងស្រីមួយចំនួនត្រូវបានទទួលរងគ្រោះដោយត្រូវបានលក់ឱ្យផ្ទះបនអនិងត្រូវបានបង្ខំអោយធ្វើពលកម្មធ្ងន់ធ្ងរ។ | ក្មេងប្រុសអាចត្រូវរងគ្រោះដោយការងារពលកម្មធ្ងន់ធ្ងរផងផ្សេងៗដែរ។ |

**ការអនុវត្តន៍សំរាប់គោលដៅអភិវឌ្ឍន៍សហសវត្សរ៍នៃព្រះរាជាណាចក្រកម្ពុជា**

**គោលដៅទី ២ : សំរេចបាននូវការអប់រំកំរិតបឋមជាសាកល**

## វ័យជំទង់

នៅក្នុងវ័យជំទង់ ពួកគេអាចមានការប្រឈមមុខខុសៗគ្នា។ កុមារខ្លះមានឱកាសចូលរៀនបានតិចតួច តែក៏មានកុមារ ភាគច្រើនដែលមិនមានឱកាសបានចូលរៀនសោះ។ នៅតំបន់ខ្លះ កុមារវ័យជំទង់ត្រូវបានរៀបការតាំងពីក្មេង។ កុមារវ័យជំទង់វាច្រើនបានចូលរួមក្នុងការងាររកប្រាក់ចំណូល ដូចជានៅក្នុងរោងចក្រកាត់ដេរ ការងារស្រែចម្ការ ឬការងារផ្សេងៗទៀត។



ទន្ទឹមនេះពាក្យប្រៀនប្រដៅនៅក្នុង "ច្បាប់ស្ត្រី" និងក្នុង "ច្បាប់ប្រុស" កាន់តែជំរុញអោយគម្លាតនៃតួនាទីនិងទំនាក់ទំនងយេនឌ័រកាន់តែចាក់ឫសខ្លាំងឡើង។ ទន្ទឹមនឹងនេះពួកគេ ស្ថិតនៅក្រោមឥទ្ធិពលសង្គមដែលមិនអាចចៀសវាងបាន។

| កុមារីវ័យជំទង់ | កុមារាវ័យជំទង់ |
|---|---|
| **លក្ខណៈជីវសាស្ត្រក្នុងកំឡុងពេលវ័យជំទង់**<br>ក្នុងកំឡុងពេលវ័យជំទង់ កុមារទាំងអស់ត្រូវឆ្លងកាត់ការប្រែប្រួលទាំងផ្លូវកាយ ផ្លូវចិត្ត ដែលអាចបណ្តាលឱ្យមានភាពច្រួលច្របល់ ខ្មាស់អៀន និងភាពភ័យខ្លាច។ ក្មេងស្រីនៅកម្ពុជា ទទួលបានពត៌មានយ៉ាងតិចតួចអំពីភាពពេញក្រមុំ ការមានរដូវ បញ្ហាភេទ និងការមានគភ៌។ ការមានអារម្មណ៍អៀនខ្មាស់ពីការមានរដូវបណ្តាលឱ្យខ្វះការយល់ដឹងពីអនាម័យ (ជាមួយនឹងការឆ្លងជំងឺ) ខ្វះការយកចិត្តទុកដាក់ចំពោះបញ្ហាសុខភាពបន្តពូជ (រួមមានទាំងជំងឺកាមរោគ) និងបញ្ហាសុខភាពផ្សេងទៀត។<br><br>**ព្រហ្មចារីយ៍**<br>ក្មេងស្រីត្រូវបានគេប្រាប់ថា នៅក្នុងវ័យជំទង់ពួកគេប្រៀបដូចជាផ្កាក្រពុំដែលអាចនឹងមានភាពសៅហ្មងនិងខូចបង់យ៉ាងងាយ។ ដូច្នេះក្មេងស្រីត្រូវតែប្រុងប្រយត្ន័ ព្រោះពួកគេអាចទទួលគ្រោះថ្នាក់បានពីបុរស។ ព្រហ្មចារីយ៍ត្រូវបានគេអោយតំលៃយ៉ាងខ្ពស់ ហើយក្មេងស្រីមានការភ័យខ្លាចថា ជីវិតរបស់ពួកគេនឹងត្រូវបំផ្លាញ ប្រសិនបើពួកគេបានបាត់បង់នូវព្រហ្មចារីយ៍។ នៅក្នុងស្ថានភាពខ្លះ ក្មេងស្រីដែលមានមិត្តប្រុសមានការភ័យខ្លាចក្នុងការចរចាពីការរួមភេទ និងការប្រើស្រោមអនាម័យ ដោយការភ័យខ្លាចបាត់បង់មិត្តប្រុសហើយម្យ៉ាងទៀត ពួកគេក៏មានការភ័យខ្លាចបាត់បង់ព្រហ្មចារីយ៍របស់ពួកគេដែរ។<br><br>នៅក្នុងប្រទេសកម្ពុជា ការព្រួយបារម្ភរបស់ម្តាយឪពុកក្នុងការខ្លាចកូនស្រីរបស់ពួកគាត់បាត់បង់ព្រហ្មចារីយ៍ បានបណ្តាលឱ្យមានការដាក់កំរិតតឹងរ៉ឹងមិនឱ្យកូនស្រីដើរហើរឆ្ងាយពីផ្ទះ។ ម្តាយឪពុកជាច្រើន ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងការពារកូនស្រីឱ្យកូនស្រីរបស់គាត់នៅតែផ្ទះ និងផ្តោតទៅលើការងារផ្ទះសម្បែង។ បន្ថែមលើនេះទៀត មានជំនឿថា "ក្មេងស្រីដែលល្អ គឺក្មេងស្រីណាដែលនៅក្រោមការការពាររបស់ម្តាយឪពុក" ។ ជំនឿទាំងអស់នេះ បានជំរុញឱ្យស្ត្រី | **លក្ខណៈជីវសាស្ត្រក្នុងកំឡុងវ័យជំទង់**<br>ក្នុងកំឡុងពេលវ័យជំទង់ កុមារទាំងអស់ត្រូវឆ្លងកាត់ការប្រែប្រួលទាំងផ្លូវកាយ ផ្លូវចិត្តដែលអាចបណ្តាលឱ្យមានភាពច្រួលច្របល់ ខ្មាស់អៀននិងភាពភ័យខ្លាច។ ក្មេងប្រុសនៅកម្ពុជាភាគច្រើនបានទទួលពត៌មានតិចតួចអំពីភាពពេញវ័យ ភាពទាក់ទងនឹងបញ្ហាភេទ និងការមានគភ៌របស់ក្មេងស្រីវ័យជំទង់។<br><br>**ព្រហ្មចារីយ៍**<br>ព្រហ្មចារីយ៍របស់ក្មេងប្រុស មិនសូវមានតំលៃខ្ពស់ដូចក្មេងស្រីទេ។ ក្នុងវ័យនេះក្មេងប្រុសត្រូវបានសង្គមជិតថា មានតំរូវការផ្នែកភេទច្រើនជាងក្មេងស្រី ហើយភាគច្រើនមិនអាចគ្រប់គ្រងបាន។ សង្គមមានជំនឿថា តម្រូវការផ្នែកភេទខ្ពស់គឺបង្ហាញពីភាពជាបុរសពិតប្រាកដ។ ជុំវិញតំរូវការទាំងអស់នេះ អាចមានបញ្ហាប្រកួតប្រជែង និងជល្មើសគ្នាដែលបណ្តាលឱ្យសង្គមគ្មានសណ្តាប់ធ្នាប់។ |

នៅតែផ្ទះ កាត់បន្ថយនូវការជឿជាក់និងភាពអង់អាចរបស់ស្ត្រី។

នៅក្នុងវ័យនេះ តួនាទីយេនឌ័រត្រូវបានពង្រឹងកាន់តែខ្លាំងឡើង។ ក្មេងស្រីត្រូវបានគេប្រាប់ថា ពួកគេមានតំលៃ និងសារៈសំខាន់ទាបជាងក្មេងប្រុស ការងាររបស់ក្មេងស្រី គឺគ្រាន់តែជាការងារជំនួយបន្ថែមលើការងារក្មេងប្រុសតែប៉ុណ្ណោះ ដូចនេះ ក្មេងស្រីត្រូវតែរណបក្មេងប្រុស។ ក្មេងស្រីត្រូវបានគេប្រាប់ថា ស្ត្រីដែលចេះទាមទារ ជជែក និងមានភាពឯករាជ្យ មិនអាចរៀបការមានសុភមង្គល និងមិនអាចរកដៃគូជីវិតបានទេ។ ក្មេងស្រីត្រូវបានគេដាក់លក្ខខ័ណ្ឌអោយរៀបការ ហើយត្រូវបានគេប្រាប់ថាបន្ទាប់ពីរៀបការរួច តួនាទីដំបូងរបស់គេ គឺត្រូវថែទាំ និងស្តាប់បង្គាប់ប្តី មើលថែទាំកូន និងផ្ទះសម្បែង។ ក្មេងស្រីត្រូវបានគេប្រាប់មិនឱ្យគិតគូរពីការរួមភេទ ត្រូវចេះខ្មាស់អៀនមានភាពផ្អែមល្ហែមនិងស្តាប់បង្គាប់។ ទង្វើទាំងអស់នេះត្រូវបានសង្គមចាត់ទុកថាជាលក្ខណៈនិងឥរិយាបថល្អរបស់ស្ត្រី។

## ការអប់រំ

ក្នុងចំណោមកុមារី៧នាក់ មានកុមារី១នាក់ បានទទួលការអប់រំត្រឹមមធ្យមសិក្សាកំរិត១ និងមាន១នាក់ក្នុងចំណោមកុមារី២០នាក់ បានទទួលការអប់រំមធ្យមសិក្សាកំរិត២។ ក្មេងស្រីត្រូវបានឈប់ពីការសិក្សាដើម្បីជួយរកកំរៃសំរាប់គ្រួសារ ជួយការងារនៅផ្ទះសម្បែង និងជួយថែទាំបងប្អូននិងសាច់ញាតិដែលមានជំងឺ។ ការឱ្យតម្លៃរបស់សង្គមទៅលើការអប់រំរបស់ក្មេងស្រី ជាពិសេសលើការអប់រំនៅកំរិតខ្ពស់នៅមានតម្លៃទាប។ ឪពុកម្តាយផ្តោតទៅលើការឱ្យកូនរៀបការជាជាងការរកការងារល្អធ្វើទៅអនាគត។ ម្យ៉ាងទៀត ឪពុកម្តាយមានការភ័យខ្លាចចំពោះការបញ្ជូនកូនស្រីទៅសាលារៀនដោយខ្លាចមានការចាប់ជំរិត និងការចាប់រំលោភ។

## ការងារនិងពលកម្ម



ក្នុងចំណោម៤នាក់ មានក្មេងស្រី៣នាក់ ដែលមានអាយុ១៧ឆ្នាំបានចូលរួមយ៉ាងសកម្មក្នុងការងារពលកម្ម។ ក្មេងស្រីត្រូវបានគេរំពឹងថា

នៅក្នុងវ័យនេះ តួនាទីយេនឌ័ររបស់ក្មេងប្រុសត្រូវបានពង្រឹងកាន់តែខ្លាំងឡើងក្នុងការដឹកនាំ និងគ្រប់គ្រងលើស្ត្រី។ ក្មេងប្រុសត្រូវបានជំរុញឱ្យចូលរួមនិងបង្កើតទំនាក់ទំនងជាមួយសង្គមខាងក្រៅ ត្រៀមរៀបខ្លួនជាអ្នកទទួលខុសត្រូវ និងជាមេគ្រួសារ។ ក្មេងប្រុសត្រូវបានគេរំពឹងថាជាអ្នកដឹកនាំនៅក្នុងគ្រួសារ និងជាអ្នកដែលដឹងឮពីបញ្ហារួមភេទ។ ក្មេងប្រុសត្រូវតែរៀនឱ្យបានពូកែ មានចំណេះដឹងច្រើនជាងក្មេងស្រី ដើម្បីធ្វើជាអ្នកដឹកនាំគ្រួសារ និងដឹកនាំក្នុងសង្គម។

## ការអប់រំ

ក្នុងចំណោមកុមារា៥នាក់ មាន១នាក់បានទទួលការអប់រំមធ្យមសិក្សាកំរិត១ និងមាន១នាក់ក្នុងចំណោមកុមារា១០នាក់បានទទួលការអប់រំមធ្យមសិក្សាកំរិត២។ ប្រសិនបើម្តាយឪពុកមានលទ្ធភាពអាចបញ្ជូនកូនប្រុសទៅរៀនបាន ពួកគេនឹងបញ្ជូនកូនប្រុសភ្លាម ដោយមិនមានការភ័យខ្លាចចំពោះសុវត្ថិភាពរបស់កូនប្រុសគេឡើយ ។ ពួកគេមិនសូវមានការតឹងតែងជាមួយកូនប្រុសទេ។ នៅក្នុងការអប់រំកំរិតមហាវិទ្យាល័យមានសិស្សប្រុសច្រើនជាងសិស្សស្រី។

## ការងារនិងពលកម្ម

ពាក់កណ្តាលនៃក្មេងប្រុសអាយុ១៧ឆ្នាំ បានចូលរួមក្នុងការងារពលកម្ម។ ក្មេងប្រុសមិនត្រូវបានគេរំពឹងថានឹងជួយធ្វើផ្ទះនៅពេលគេចូលដល់វ័យជំទង់ទេ ប៉ុន្តែពួកគេត្រូវជួយការងាររកប្រាក់ចំណូល។

| | |
|---|---|
| និងជួយដល់គ្រួសារនៅពេលគេចូលដល់វ័យជំទង់។ ការងារ ផ្ទះដូចជា ដងទឹក រកអុស ដាំស្ល និងថែទាំប្អូនតូចៗ តែងតែធ្លាក់មកលើ ក្មេងស្រីជំទង់។ ទន្ទឹម នេះពួកគេត្រូវធ្វើការងារផ្សេងទៀតដើម្បីជួយដល់ក្រុម គ្រួសារដូចជា រកប្រាក់ចំណូលដោយយកត្រីទៅលក់ នៅផ្សារ ធ្វើការងារក្នុង ស្រែ ចិញ្ចឹមសត្វ។ល។ | |
| ក្មេងស្រីជាច្រើននៅតំបន់ជនបទបានផ្លាស់មកនៅទីក្រុងដោយសង្ឃឹមថារកការងារធ្វើនៅក្នុងរោងចក្រកាត់ដេរ។ ក្នុងចំណោម១៨០.០០០ នៃនិយោជិករោងចក្រកាត់ដេរភាគច្រើនមានអាយុពី១៥ទៅ១៩ឆ្នាំ។ ជាទូទៅក្មេងស្រីដែលមិនទាន់រៀបការ ហើយមករស់នៅឆ្ងាយពីគ្រួសារ ងាយនឹងរងគ្រោះដោយការរំលោភរាងកាយនិងផ្លូវភេទ។ ជាងនេះទៅទៀតពួកគេមានអារម្មណ៍ឯកោ ដោយសាររស់នៅឆ្ងាយពីក្រុមគ្រួសារ។ នាពេលបច្ចុប្បន្ន សេវាសង្គមគាំទ្រពួកគេមានតិចតួចណាស់។ ម្យ៉ាងទៀត ទោះជារោងចក្រកាត់ដេរបានផ្តល់ការងារដល់ក្មេងស្រីជាច្រើននាក់ តែស្ថានភាពការងារនៅក្នុងរោងចក្រជាច្រើនមានភាពកេងប្រវ័ញ្ច និងការរើសអើង។ | បុរសវ័យក្មេងខ្លះ អាចចំណាកស្រុកទៅប្រកបមុខរបរនៅទីក្រុង ដូចជា ការងារសាងសង់ រត់ម៉ូតូឌុប ឬការងារផ្សេងៗទៀត។ |
| **សុខភាព**<br>ក្នុងចំណោមម្តាយ១២នាក់ មានម្តាយ១នាក់ដែលមានវ័យជំទង់។ នៅខេត្តរតនគិរី និងខេត្តមណ្ឌលគិរី ក្នុងចំណោមម្តាយ៥នាក់មានម្តាយដែលមានវ័យជំទង់ម្នាក់។ នៅតាមតំបន់ជាច្រើន ក្មេងស្រីត្រូវបានរៀបការតាំងពីវ័យក្មេង ហើយត្រូវបានជំរុញឱ្យមានកូនភ្លាមបន្ទាប់ពីរៀបការរួច។ ដោយពួកគេទាំងនោះមិនបានត្រៀមខ្លួនជាមុនសំរាប់ការរួមភេទឬការចិញ្ចឹមកូន ពួកគេអាចត្រូវប្រឈមនឹងគ្រោះថ្នាក់ចំពោះការឆ្លងជំងឺកាមរោគ និងមេរោគអេដស៍ពីដៃគូរបស់ពួកគេ។ ការមានគភ៌នៅវ័យក្មេងពេក បង្កើននូវការមានជំងឺនិងការស្លាប់។ ម្យ៉ាងទៀតសេវាកម្មសំរាប់មាតានៅមានការខ្វះខាតនៅក្នុងតំបន់ជាច្រើននៅក្នុងកម្ពុជា។ ដោយសារតាំងពីកុមារភាព ក្មេងស្រីមួយចំនួនមិនបានទទួលអាហារគ្រប់គ្រាន់ មានទំងន់តិចនិងមានកង្វះជាតិដែក ពួកគេត្រូវរងនូវការលំបាកកាន់តែខ្លាំងនៅកំឡុងមានគភ៌និងក្រោយពេលសម្រាល។ | **សុខភាព**<br>មិនសូវមានបុរសឆាប់រៀបការពីវ័យក្មេងពេកទេ។ ស្វាមីមានវ័យក្មេងអាចមានអារម្មណ៍មិនសូវទុកចិត្តលើភរិយារបស់គេ ហើយដែលធ្វើឱ្យគេមានការត្រួតត្រាលើភរិយារបស់គេ។ ម្យ៉ាងទៀត ស្វាមីវ័យក្មេង មិនបានត្រៀមខ្លួនជាមុនសំរាប់ការថែទាំភរិយារបស់គេ និងការចិញ្ចឹមកូនទេ។ |
| **គ្រោះថ្នាក់ផ្សេងៗទៀត**<br>ក្មេងស្រីខ្លះកំពុងស្ថិតក្នុងភាពគ្រោះថ្នាក់ដោយការជួញដូរ។ កុមារីខ្លះត្រូវបានលក់ | **គ្រោះថ្នាក់ផ្សេងទៀត**<br>កុមារាអាចទទួលរងគ្រោះថ្នាក់ពីការជួញដូរ |

| | |
|---|---|
| ដោយឪពុកម្តាយឬដោយសាច់ញាតិរបស់ពួកគេនិងខ្លះទៀតត្រូវបានគេចាប់ពង្រត់និងជួញដូរ។ ក្មេងស្រីខ្លះមកទីក្រុងដើម្បីស្វែងរកការងារធ្វើ ហើយអាចត្រូវគេលួងលោមឬបង្ខំឬអាចស្ម័គ្រចិត្តធ្វើជាស្រីរកស៊ីផ្លូវភេទដើម្បីរកប្រាក់ចំណូល។ មានស្ត្រីចំនួនប្រមាណជា១០០.០០០នាក់ប្រកបមុខរបរផ្លូវភេទ ដែលភាគច្រើនមានអាយុក្រោម១៨ឆ្នាំ។ ជាទូទៅក្មេងស្រីប្រកបមុខរបរផ្លូវភេទត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ជំងឺកាមរោគនិងមេរោគអេដស៍។ ភាពព្រហ្មចារីយ៍មានតំលៃជាពិសេស ដោយសារមានការជឿថា ការរួមភេទជាមួយស្ត្រីបរិសុទ្ធអាចព្យាបាលមេរោគអេដស៍ ម្យ៉ាងទៀតគេជឿថាភាពបរិសុទ្ធមិនមានជំងឺទេ។ ក្មេងស្រីដែលនៅភាពបរិសុទ្ធអាចពិបាកក្នុងការចរចាឱ្យបុរសប្រើស្រោមអនាម័យ ហើយអាចត្រូវទទួលរងនូវការចាប់រំលោភ ដែលបណ្តាលឱ្យមានការខូចខាតខាងរាងកាយ និងខាងសរីរាង្គរបស់ពួកគេ។ ក្មេងស្រីដែលប្រកបមុខរបរផ្លូវភេទត្រូវបានគេទាត់ចោលពីសង្គម។ ពួកគេត្រូវអស់តំលៃនិងអស់អនាគតហើយមិនអាចរៀបការដែលមានសុភមង្គលបានទៀត។ ជាទូទៅ អ្នកប្រកបរបរផ្លូវភេទអាចត្រូវរងគ្រោះថ្នាក់ខ្លាំងពីការរំលោភលើរាងកាយ រំលោភផ្លូវភេទ និងការកេងប្រវ័ញ្ចនានា។ | ឱ្យទៅធ្វើការនៅក្រៅប្រទេស។ |

**ការអនុវត្តន៍សំរាប់គោលដៅនៃអភិវឌ្ឍន៍សហស្សវត្សរ៍នៃព្រះរាជាណាចក្រកម្ពុជា**

**គោលដៅទី ៣ :** **កាត់បន្ថយគម្លាតយេនឌ័រនៅគ្រប់កំរិតនៃការអប់រំ**

**បង្កើនប្រាក់កំរៃនៃការប្រកបមុខរបររបស់ស្ត្រី**

**កាត់បន្ថយរាល់ទំរង់នៃអំពើហិង្សាប្រឆាំងលើស្ត្រី**

## ពេញវ័យ



នៅក្នុងវ័យនេះ តម្លាតតួនាទីយេនឌ័របានចាក់ឫសយ៉ាងជ្រៅនៅក្នុងអារម្មណ៍ និងផ្នត់គំនិតរបស់មនុស្ស។ ទាំងស្ត្រីវ័យក្មេង និងបុរសវ័យក្មេងប្រកាន់យកនិងអនុវត្តទៅតាមការកំណត់យ៉ាងតឹងរ៉ឹងនេះ។ វាជាការលំបាកខ្លាំងណាស់ក្នុងការធ្វើឱ្យមានសមភាពយេនឌ័រនៅក្នុងក្រុមគ្រួសារដែលមានជំនឿនិងឱ្យតម្លៃខុសគ្នាទៅលើតួនាទីស្ត្រី និងបុរស។ ជំនឿទាំងអស់នេះបានបន្តរហូតដល់ក្មេងជំនាន់ក្រោយទៅតាមវដ្តនៃ

ជីវិតរបស់ពួកគេ។ វាមានការលំបាកកាន់តែខ្លាំងឡើង ក្នុងការធ្វើឱ្យមានសមភាពយេនឌ័រនៅក្នុងសហគមន៍ បើសិនជានៅក្នុងរង្វង់គ្រួសារមិនទាន់មានសមភាព យេនឌ័រនៅឡើយ។

| ស្ត្រីវ័យក្មេង | បុរសវ័យក្មេង |
|---|---|
| ស្ត្រីកម្ពុជាភាគច្រើនរៀបការនៅពេលចាប់ផ្តើមពេញវ័យ។ នៅកម្ពុជា ជាទូទៅការស្ថិតនៅក្នុងភាពនៅលីវមានភាពមិនសូវល្អ ហើយអាចធ្វើឱ្យគេមានចម្ងល់ច្រើន ជាពិសេសចំពោះស្ត្រី។ ដូចនេះក្មេងស្រីត្រូវបានគេបញ្ចុះបញ្ចូលឱ្យរៀបការតាំងពីវ័យក្មេង។ ស្ត្រីត្រូវបានគេប្រាប់ថា មិនត្រូវបដិសេធនៅពេលដែលប្តីរបស់ខ្លួនចង់រួមដំណេកទេ។ ស្ត្រីត្រូវបានគេលើកទឹកចិត្តឬតម្រូវអោយមានកូនភ្លាមបន្ទាប់ពីរៀបការរួច ដើម្បីបង្ហាញពីលទ្ធភាពនៃការបង្កើតកូន និងការដែលមានកូនច្បងជាបុរស។ នៅកម្ពុជាចំនួនតិចជាងពាក់កណ្តាលនៃស្ត្រីមានផ្ទៃពោះបានទទួលនូវការថែទាំក្នុងពេលមានផ្ទៃពោះ ហើយមានតែស្ត្រី១នាក់ក្នុងចំណោមស្ត្រី៣នាក់បានទទួលការបង្កើតកូនដោយឆ្មបដែលបានបណ្តុះបណ្តាលត្រឹមត្រូវ។ | បុរសកម្ពុជាភាគច្រើន រៀបការនៅពេលដែលពួកគេមានអាយុប្រមាណជា ២០ឆ្នាំ។ បុរសក៏ដូចជាស្ត្រីដែរ ការស្ថិតនៅក្នុងភាពនៅលីវមានភាពមិនសូវល្អសំរាប់គេទេ។ បុរសមានការរំពឹងថា ភរិយារបស់គេនឹងធ្វើការងារផ្ទះសម្បែង។ ជាទូទៅ បុរសដែលធ្វើការងារផ្ទះសម្បែង អាចត្រូវសង្គមថា ជាបុរសទន់ខ្សោយ ឬមានចរិកស្រី។ |
| ការមិនមានអាហារហូបគ្រប់គ្រាន់អាចជាលទ្ធផលមិនល្អសំរាប់មាតាក្នុងការផ្តល់កំណើត។ នៅកំឡុងពេលមានគភ៌ ស្ត្រីមិនទទួលបានការថែទាំសុខភាពឱ្យបានល្អ ដូចជាការចាក់ថ្នាំបង្ការតេតាណូស ការផ្គត់ផ្គង់ជីវជាតិ អាហារ និងការពិគ្រោះយោបល់។ ការបង្កើតនិងការថែទាំក្រោយពេលសំរាលកូនមិនបានល្អត្រឹមត្រូវ រឹតតែបង្កើននូវជំងឺដល់មាតានិងទារក។ ការតមអាហារមួយចំនួននៅពេលមានគភ៌ក៏បណ្តាលឱ្យមានបញ្ហាកង្វះជីវជាតិអាហារសំរាប់ស្ត្រីផងដែរ។ ជំនឿអវិជ្ជមានមួយចំនួនស្តីពីការមានគភ៌ ការឆ្លងទន្លេនិងការថែទាំក្រោយពេលសំរាល (ឧ.មិនឱ្យងូតទឹករយៈពេលមួយខែបន្ទាប់ពីឆ្លងទន្លេរួច) អាចជាគ្រោះថ្នាក់ដល់សុខភាពស្ត្រី និងទារក។ បន្ទាប់ពីមានកូនដំបូងរួចមានស្ត្រីតិចតួចណាស់ដែលអាចទទួលបាននូវការពន្យាកំណើត ដូចនេះការមានគភ៌លើកទីពីរអាចកើតមានភ្លាមបន្ទាប់ពីកូនដំបូងរួច ដោយមិនមានពេលគ្រប់គ្រាន់សំរាប់ឱ្យខ្លួនប្រាណស្ត្រីបានទទួលភាពនូវភាពប្រសើរឡើងវិញបន្ទាប់ពីការមានគភ៌លើកដំបូង។ | បុរសភាគច្រើនមិនដឹងពីគ្រោះថ្នាក់ដែលបណ្តាលមកពីការមានផ្ទៃពោះការសំរាលកូន។ល។ ពួកគេអាចមិនយកចិត្តទុកដាក់ក្នុងការថែទាំផ្ទៃពោះនិងរកឆ្មបដែលមានជំនាញពិតប្រាកដសំរាប់បង្កើតកូនរបស់គេ។ ជាទូទៅ បុរសកម្ពុជាមិនសូវចាប់អារម្មណ៍ និងទទួលខុសត្រូវលើការពន្យាកំណើតឡើយ។ |
| មានក្មេងស្រីមួយចំនួនតូចដែលទទួលការអប់រំនៅកំរិតវិទ្យាល័យ និងកំរិតឧត្តមសិក្សា។ ជាលទ្ធផល ពួកគេមួយចំនួនតូចតែប៉ុណ្ណោះដែលមានជំរើសសំរាប់ការងារមានកំរៃ។ ចំពោះស្ត្រីដែលមានការងារមានប្រាក់ខែ ភាគច្រើនទទួលកំរៃទាបជាងបុរស ហើយមិនងាយនឹងទទួលបានការតម្លើងឋានៈទេ។ មានស្ត្រីប្រមាណ១៤% ប្រកបមុខរបរបានប្រាក់កំរៃ | ទោះបីជាបុរសទទួលបានការអប់រំមធ្យមសិក្សាកំរិត២ និងកំរិតឧត្តមសិក្សាច្រើនជាងស្ត្រី តែក៏នៅមានបុរសភាគច្រើនមិនបានទទួលការអប់រំ |

| | |
|---|---|
| ប៉ុន្តែស្ត្រីទទួលបានប្រាក់កំរៃតិចជាងបុរសប្រមាណ៣៣%។ ស្ត្រីធ្វើការ១៨ម៉ោងក្នុង១ថ្ងៃនៅក្នុងរដូវវស្សា ហើយត្រូវបានគេរំពឹងឱ្យធ្វើការងារគ្មានកំរៃទាំងអស់នៅក្នុងផ្ទះ ដូចជាមើលថែទាំកូន សំអាតផ្ទះ ចិញ្ចឹមសត្វ ដាំបន្លែ ដាំស្ល ដងទឹកនិងរកអុស ហើយត្រូវជួយការងារប្តីក្នុងការរកប្រាក់ចំណូល (ជាទូទៅបុរសធ្វើការប្រមាណជា១០ម៉ោងក្នុង១ថ្ងៃ)។ | កំរិតខ្ពស់ដែរ។ ភាពគ្មានការងារធ្វើ និងឱកាសក្នុងការប្រាក់ចំណូល បានដាក់សម្ពាធធ្ងន់ទៅលើបុរស។ គេបាត់បង់ទំនុកចិត្តលើខ្លួនឯង នៅពេលគេរកប្រាក់ចំណូលមិនបានគ្រប់គ្រាន់។ មានបុរសប្រមាណតែ ១៩ភាគរយប៉ុណ្ណោះដែលប្រកបការងារមានប្រាក់កំរៃ។ |
| មានស្ត្រី១ភាគ៤ដែលចូលរួមឆ្លើយនៅក្នុងការអង្កេតស្តីពីប្រជាសាស្ត្រ និងសុខភាព នៅប្រទេសកម្ពុជាបានផ្តល់យោបល់ថា ពួកគេប្រឈមមុខនឹងគ្រោះថ្នាក់នៃអំពើហិង្សាក្នុងគ្រួសារ ត្រូវបានបង្ខំឱ្យរួមភេទ និងត្រូវរងការបំពានខាងផ្លូវចិត្ត។ ស្ត្រីត្រូវបានគេឃាមមិនឱ្យនិយាយទៅក្រៅផ្ទះអំពីការរំលោភបំពានពីប្តីរបស់ខ្លួន ហើយត្រូវបានគេប្រាប់ថា វាជាការធម្មតាដែលប្តីវាយប្រពន្ធ។ | ពុំមានស្ថិតិគ្រប់គ្រាន់ស្តីពីបុរសដែលប្រព្រឹត្តអំពើហិង្សាលើស្ត្រីក្នុងកម្ពុជា។ |

ការអនុវត្តន៍សំរាប់គោលដៅអភិវឌ្ឍន៍សហសវត្សរ៍នៃព្រះរាជាណាចក្រកម្ពុជា

គោលដៅទី ១ : កាត់បន្ថយភាពក្រីក្រនិងភាពអត់ឃ្លាន

គោលដៅទី ៣ : កាត់បន្ថយគម្លាតយេនឌ័រនៅក្នុងវិស័យនយោបាយ

បង្កើនប្រាក់កំរៃនៃការប្រកបមុខរបររបស់ស្ត្រី

កាត់បន្ថយរាល់ទំរង់អំពើហិង្សាប្រឆាំងលើស្ត្រី

គោលដៅទី ៥ : កាត់បន្ថយការស្លាប់របស់កុមារ

គោលដៅទី ៥ : ប្រយុទ្ធប្រឆាំងនឹងវីរុសហ៊ីវ ជម្ងឺអេដស៍ ជម្ងឺរបេង និងគ្រុនចាញ់

## យុវវ័យ



នៅក្នុងប្រទេសកម្ពុជា ស្ត្រីភាគច្រើនក្នុងចន្លោះអាយុពី២៥ទៅ៥០ឆ្នាំ អាចមានកូនច្រើនលើសពីចំនួនដែលពួកគេចង់បាន។ កង្វះនូវសេវាពន្យាកំណើត និងសេវាមាតុភាពគ្មាន

គ្រោះថ្នាក់ អាចបណ្ដាលឱ្យអត្រានៃជម្ងឺ និង មរណៈភាពខ្ពស់ក្នុងចំណោមស្ត្រីក្នុងវ័យនេះ។ ការមានកូនច្រើនអាចបណ្ដាលឱ្យប៉ះពាល់ដល់កង្វះ អាហារូបត្ថម្ភផងដែរ។ បន្ទុកការងារច្រើន រួមទាំងការងាររកប្រាក់កំរៃ ការងារផ្ទះសម្បែង ការហូបចុកមិនបានល្អ ការមានគភ៌ញឹកញាប់និងភាពមានជម្ងឺ បណ្ដាលឱ្យស្ត្រីទទួលមរណៈភាពពីវ័យក្មេង។ ស្ត្រីត្រូវទទួលបន្ទុកការងារផ្ទះសម្បែង និងថែទាំកូនចៅ។ ជាទូទៅ ស្ត្រីតែងតែផ្ទេរបន្ទុកការងារទាំងអស់នេះទៅកូនស្រីរបស់គេ ដែលជាការបន្ថែមនូវបញ្ហានិងការលំបាកដល់ជីវិតរបស់ស្ត្រី។ ស្ត្រីនិងបុរសរងគ្រោះថ្នាក់ពីការឆ្លងមេរោគអេដស៍និងជម្ងឺកាមរោគ។ បុរសដែលមានភរិយា និងមានដៃគូច្រើន គិតថាពួកគេមិនចាំបាច់ប្រើស្រោមអនាម័យឡើយ។ ជាទូទៅ ស្ត្រី គឺជាអ្នកថែទាំអ្នកមានជម្ងឺ និងអ្នកផ្ទុកមេរោគអេដស៍ ហើយនាពេលបច្ចុប្បន្ន កម្មវិធី និងសេវាគាំទ្រអ្នកផ្ទុកមេរោគអេដស៍នៅមានចំនួនតិចនៅឡើយ។

| ស្ត្រីពេញវ័យ | បុរសពេញវ័យ |
|---|---|
| សុខភាពនិងអាហារូបត្ថម្ភ<br>នៅប្រទេសកម្ពុជា មានស្ត្រីចំនួន២.០០០នាក់បានស្លាប់ជារៀងរាល់ឆ្នាំដោយសារបញ្ហានៃការសំរាលកូន។ មានស្ត្រីជាងពាក់កណ្ដាលនៃអ្នកមានផ្ទៃពោះ មានបញ្ហាកង្វះឈាមក្រហម។ ជាទូទៅស្ត្រីប្រើប្រាស់ស្រូវអង្ករ ត្រី សាច់ និងស៊ុតតិចជាងបុរស។ ស្ត្រីមានផ្ទៃពោះចំនួនប្រហែលពី២,៥%ទៅ២,៧% ដែលបានធ្វើតេស្តឈាម ហើយរកឃើញថាមានផ្ទុកមេរោគអេដស៍។ ១ភាគ៣នៃស្ត្រីប្រកបរបរផ្លូវភេទ មានផ្ទុកមេរោគអេដស៍។ | សុខភាពនិងអាហារូបត្ថម្ភ<br>បុរសទទួលរងគ្រោះអំពីការកង្វះអាហារនិងជម្ងឺគ្រុនចាញ់និងការរងរបួសផ្សេងៗ។ គ្រោះថ្នាក់ទាំងនេះកើតដោយសារការកំណត់របស់សង្គមដែលថា បុរសត្រូវចំណាយពេលច្រើននៅសង្គមខាងក្រៅ។ |
| ការចូលរួមក្នុងអភិបាលកិច្ច<br>នៅក្នុងគណៈកម្មការអភិវឌ្ឍន៍ភូមិ ស្ត្រីបានចូលរួមប្រមាណ៤០ភាគរយ ហើយសំរេចទៅតាមការកំណត់ ដើម្បីធានាថាស្ត្រីមានឱកាសចូលរួមក្នុងការដឹកនាំ និងចូលរួមក្នុងនយោបាយ។ ប៉ុន្តែពេលបច្ចុប្បន្ន មានស្ត្រីប្រមាណតែ៨.៥% ប៉ុណ្ណោះជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់។ ក្នុងចំណោមសមាជិកតំណាងរាស្ត្រ (រដ្ឋសភា) ១០នាក់ មាន១នាក់ជាស្ត្រី។ ស្ត្រីកម្រនឹងទទួលបាននូវឱកាសចូលរួមក្នុងការធ្វើសេចក្ដីសំរេចនៅគ្រប់លំដាប់ថ្នាក់ ហើយកម្រនឹងមានឋានៈធំដុំក្នុងវិស័យនយោបាយណាស់។ ដូចនេះជាលទ្ធផល តម្រូវការរបស់ស្ត្រីត្រូវបានគេយកចិត្តទុកដាក់យ៉ាងតិចតួច ហើយភាគច្រើនមិនទាន់បានដោះស្រាយនៅឡើយ។ | ការចូលរួមក្នុងអភិបាលកិច្ច<br>បុរសមានចំនួនច្រើននៅក្នុងតួនាទីធ្វើសេចក្ដីសំរេចផ្នែកនយោបាយ។ |

| ការប្រកបការងារ | ការប្រកបការងារ |
| --- | --- |
| មានស្ត្រីជាច្រើនដែលទទួលបានការអប់រំត្រឹមតែបីបួនឆ្នាំប៉ុណ្ណោះ។ តម្រូវនៃការរកប្រាក់ចំណូលមានកំរិតខ្ពស់ តែឱកាសសំរាប់រកប្រាក់ចំណូលរបស់ស្ត្រីមានកំរិតទាប។ ការគ្មានដីធ្លីកើតមាននៅក្នុងគ្រួសារក្រីក្រជាច្រើន។ គ្រួសារដែលមានស្ត្រីជាមេគ្រួសារភាគច្រើន គ្មានដីធ្លីច្រើនជាងគ្រួសារដែលមានបុរសជាមេគ្រួសារ។ មិនត្រឹមតែមិនមានដីធ្លី មិនមានប្រាក់ចំណូល សូម្បីតែការធ្វើកសិកម្មសំរាប់ការហូបចុក ក៏ស្ត្រីមានការលំបាកខ្លាំងដែរ។ មានស្ត្រីជាច្រើននាក់ត្រូវជួបប្រទះនូវអសន្តិសុខស្បៀងរយៈពេលជាច្រើនខែ ហើយមានស្ត្រីច្រើនជាងបុរសដែលរស់នៅក្រោមភាពក្រីក្រ។ ការទទួលបានឥណទានរបស់ស្ត្រីមានកំរិតទាប។ នៅតាមតំបន់ជាយក្រុង ស្ត្រីធ្វើជាអ្នកជួញដូរតូចតាច ដើម្បីបង្កើនប្រាក់ចំណូលសំរាប់គ្រួសាររបស់ពួកគេ។ ម្យ៉ាងទៀត ក្រៅពីការងាររកប្រាក់ចំណូល ស្ត្រីនៅមានភារកិច្ច និងការងារផ្ទះសម្បែងដ៏ច្រើនទៀតផង។ | ការប្រកបការងារ និងការរកប្រាក់កំរៃ ជាកង្វល់ដ៏ធំរបស់បុរសកម្ពុជា។ ជាទូទៅការទទួលបាននូវឥណទាន និងសេវាផ្សព្វផ្សាយសំរាប់ប្រជាពលរដ្ឋកម្ពុជានៅមានកំរិតទាប។ មានបុរសជាច្រើននាក់ផងដែរដែលជួបប្រទះនូវបញ្ហាអសន្តិសុខស្បៀងរយៈពេលជាច្រើនខែ។ |

**ការអនុវត្តន៍សំរាប់គោលដៅនៃអភិវឌ្ឍន៍សហស្សវត្សរ៍នៃព្រះរាជាណាចក្រកម្ពុជា**

គោលដៅទី ១ : កាត់បន្ថយភាពក្រីក្រនិងភាពអត់ឃ្លាន

គោលដៅទី ៣ : កាត់បន្ថយគម្លាតយេនឌ័រនៅក្នុងការចូលរួមក្នុងឆាកនយោបាយ

បង្កើនប្រាក់កំរៃនៃការប្រកបមុខរបររបស់ស្ត្រី

កាត់បន្ថយរាល់ទំរង់នៃអំពើហិង្សាប្រឆាំងលើស្ត្រី

គោលដៅទី ៥ : កាត់បន្ថយការស្លាប់របស់កុមារ

គោលដៅទី ៦ : ប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍និងអេដស៍ ជម្ងឺរបេងនិងគ្រុនចាញ់

## វ័យចំណាស់



សេវាសុខាភិបាលសាធារណៈសំរាប់ស្ត្រីដែលអស់រដូវ ឬសំរាប់ថែទាំស្ត្រីវ័យចំណាស់មិនទាន់មាននៅឡើយ។ មនុស្សវ័យចំណាស់តែងតែត្រូវបានថែទាំដោយ ក្រុមគ្រួសាររបស់ពួកគេ។ ការមានជំងឺអាច បណ្តាលឱ្យមានភាពក្រីក្រកាន់តែ

ខ្លាំងឡើង ដោយសារពួកគេត្រូវលក់សត្វ ដីធ្លី និងទ្រព្យ សម្បត្តិផ្សេងៗ ដើម្បីចំណាយទៅលើការថែទាំជម្ងឺ។

| ស្ត្រីវ័យចំណាស់ | បុរសវ័យចំណាស់ |
|---|---|
| ក្នុងចំណោម៥គ្រួសារដែលមានមេគ្រួសារជាស្ត្រី មាន១គ្រួសារដែលគ្មានដី ហើយចំពោះគ្រួសារដែលមានដី ក៏មានទំហំតិចតួចដែរ។<br>ប្រាក់កំរៃរបស់ស្ត្រីចាប់ពីអាយុ៤៥ឆ្នាំ ចាប់ផ្តើមថយចុះ។ | ប្រាក់កំរៃរបស់បុរសចាប់ពីអាយុ៥៥ឆ្នាំ ចាប់ផ្តើមថយចុះ។ |
| ពាក់កណ្តាលនៃស្ត្រីពីអាយុ៤៥-៥៤ឆ្នាំ និង១ភាគ៣នៃស្ត្រីដែលមានអាយុពី ៥៥-៦៤ឆ្នាំ ខេះអក្សរ។<br>ស្ត្រីទទួលបន្ទុកធ្ងន់ធ្ងរនៃការថែទាំកូន និងចៅៗខ្លួនរហូតដល់វ័យចំណាស់។<br>ស្ត្រីវ័យចំណាស់តែងតែចំណាយពេលវេលាថែទាំកុមារកំព្រាដែលបានទទួលរងនូវអំពើហិង្សាជម្ងឺអេដស៍ ឬមូលហេតុផ្សេងទៀតក៏ដោយ។ | ៨៤% នៃបុរសក្នុងចន្លោះពីអាយុ៤៥-៥៤ឆ្នាំ និង ៧៤%នៃបុរសមានអាយុពី៥៥-៦៤ឆ្នាំខេះអក្សរ។ |
| ស្ត្រីស្ថិតក្នុងវ័យចំណាស់កាន់តែមានឱកាសតិចតួចសំរាប់រកប្រាក់ចំណូល ហើយកាន់តែបាត់បង់នូវសុវត្ថិភាពនិងសន្តិសុខ។ | បុរសស្ថិតក្នុងវ័យចំណាស់កាន់តែបាត់បង់នូវ សុវត្ថិភាព និងសន្តិសុខ។ |

**ការអនុវត្តន៍សំរាប់គោលដៅអភិវឌ្ឍន៍សហសវត្សរ៍នៃព្រះរាជាណាចក្រកម្ពុជា**

គោលដៅទី ១ : កាត់បន្ថយភាពក្រីក្រនិងភាពអត់ឃ្លាន

គោលដៅទី ៣ : កាត់បន្ថយគម្លាតយេនឌ័រនៅក្នុងការចូលរួមក្នុងឆាកនយោបាយ
កាត់បន្ថយរាល់ទំរង់នៃអំពើហិង្សាប្រឆាំងលើស្ត្រី

គោលដៅទី ៥ : កាត់បន្ថយការស្លាប់របស់កុមារ

គោលដៅទី ៦ : ប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ ជម្ងឺអេដស៍ និងជម្ងឺរបេងនិងគ្រុនចាញ់

*បញ្ហាយេនឌ័រ* គឺជារបៀបទំនាក់ទំនងអសមធម៌រវាងបុរស-ស្ត្រីដែលបាននិងកំពុងរៀនសូត្រពី សង្គម ចាប់ផ្តើមតាំងពីសង្គមគ្រួសារឡើងទៅ។ ហេតុដូច្នេះទាំងកុមារី-កុមារា និងស្ត្រី-បុរស ត្រូវតែយល់ ដឹងអំពីរបៀបកំណត់ទំនាក់ទំនងទាំងនេះ ដើម្បីរកយុទ្ធសាស្ត្រសមស្របក្នុងការផ្លាស់ប្តូរនូវទំនាក់ទំនង អវិជ្ជមាន ទាំងនេះ។ ការផ្លាស់ប្តូរនេះមិនមែនធ្វើតែជាមួយស្ត្រីនោះទេ ត្រូវតែមានការទទួលខុសត្រូវ ទាំងស្រុងពីសង្គម ដែលក្នុងនោះមានទាំងស្ត្រី-បុរស ទើបអាចផ្លាស់ប្តូរនូវឥរិយាបថនិងផ្នត់គំនិតនៃ ការរើសអើងទាំងនេះបានប្រកបដោយប្រសិទ្ធភាព។

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀន អ្នកចូលរួមនឹងអាច :

- ពន្យល់បានពីផលប៉ះពាល់ជាអវិជ្ជមានដែលបណ្តាលមកពីបញ្ហាវិសមភាពយេនឌ័រនៅក្នុងវិស័យនានា ដូចជាអប់រំ សុខាភិបាល ការចូលរួមផ្នែកនយោបាយ ឱកាសផ្នែកសេដ្ឋកិច្ច និងអំពើហិង្សាលើស្ត្រី។
- យល់ដឹងពីមូលហេតុ និងសារៈប្រយោជន៍ក្នុងការដោះស្រាយបញ្ហាវិសមភាពយេនឌ័រនៅក្នុងកិច្ចអភិវឌ្ឍន៍ប្រទេស។

**រយៈពេល** : ប្រហែល៦០ នាទី។

**វិធីសាស្ត្រ** : សំនួរបំផុសគំនិត និង ការអធិប្បាយ។

**សំភារៈ** : ក្រដាសផ្ទាំងធំ និងសម្ភារៈផ្សេងៗ ។ល។

**ឯកសារមេរៀន** : ឯកសារមេរៀនទី២.៤ ផលប៉ះពាល់ជាអវិជ្ជមានដែលបណ្តាលមកពីបញ្ហាវិសមភាពយេនឌ័រ។

**របៀបសំរបសំរួល**

១. អ្នកសំរបសំរួលត្រូវភ្ជាប់ការអធិប្បាយទៅនឹងមេរៀនវដ្តនៃជីវិត ដោយសុំឱ្យអ្នកចូលរួមសង្ខេបពីការឱ្យតម្លៃ ការប្រព្រឹត្ត ការបង្ហាត់បង្ហាញ និងកត្តាផ្សេងៗដែលបណ្តាលអោយមានបញ្ហាវិសមភាពយេនឌ័រ (អាស្រ័យពេលវេលា)។

២. អ្នកសំរបសំរួលបង្ហាញ និងអធិប្បាយមេរៀនស្តីពី ផលប៉ះពាល់ជាអវិជ្ជមានដែលបណ្តាលមកពីបញ្ហាវិសមភាពយេនឌ័រម្តងមួយចំណុចៗ (មាននៅក្នុងឯកសារមេរៀនទី២.៤)។

៣. អ្នកសំរបសំរួលសួរថា *តើពួកគេមានចំងល់អំពីព័ត៌មានដែលបានបង្ហាញនេះដែរឬទេ?* ឆ្លើយនឹងសំនួរប្រសិនបើមាន។

៤. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមគិតថា *តើនៅក្នុងសហគមន៍របស់ពួកគេមានស្ថានភាពប្រហាក់ប្រហែលនេះដែរឬទេ? តើមានអ្វីខ្លះ?* សុំឱ្យគេចែករំលែកនូវព័ត៌មាននិងបទពិសោធន៍ទៅវិញទៅមក។ អ្នកសំរបសំរួលកត់ត្រាព័ត៌មានទាំងនោះដាក់លើក្រដាសផ្ទាំងធំ។ ពន្យល់ថា ឃុំ-សង្កាត់នីមួយៗ អាចមានព័ត៌មាននិងស្ថានភាពខុសៗគ្នា។ អ្នកសំរបសំរួលអាចលើកឧទាហរណ៍ជាក់ស្តែងដែលអ្នកចូលរួមទើបតែបានលើកឡើង។

៥. អ្នកសំរបសំរួលសួរអ្នកចូលរួម *ពីមូលហេតុ និងសារៈសំខាន់ក្នុងការដោះស្រាយបញ្ហាវិសមភាពយេនឌ័រនៅក្នុងកិច្ចអភិវឌ្ឍន៍ប្រទេសជាតិ*។ កត់ត្រានូវចម្លើយទាំងនោះដាក់លើក្រដាស់ផ្ទាំងធំ។

៦. អ្នកសំរបសំរួលពន្យល់ថា ស្ត្រីមានសិទ្ធិស្មើនឹងបុរស ស្ត្រីត្រូវទទួលបាននូវឱកាស ការគ្រប់គ្រងលើធនធាន និងអំណាចក្នុងការធ្វើសេចក្តីសំរេចដូចបុរសដែរ។ ប្រសិនបើស្ត្រីបានទទួលនូវឱកាស ការគ្រប់គ្រងលើធនធាន និងអំណាចក្នុងការធ្វើសេចក្តីសំរេចដូចបុរសដែរ ប្រទេសជាតិទាំងមូលក៏ដូចជាឃុំ.សង្កាត់របស់ពួកគេ នឹងទទួលបាននូវការរីកចំរើនយ៉ាងឆាប់រហ័សទាំងផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ចជាក់ជាមិនខាន។ ឧទាហរណ៍ មាតាដែលមានការអប់រំខ្ពស់ ជាទូទៅ កូនរបស់ពួកគេច្រើនមានសុខភាពល្អ មានកំរិតអប់រំខ្ពស់និងមានការងារដែលមានប្រាក់កំរៃសមរម្យ។ ម្យ៉ាងទៀត ស្ត្រីដែលមានឱកាសរកប្រាក់ចំណូល តែងតែប្រើប្រាស់ប្រាក់ចំណូលទាំងអស់នេះ សំរាប់ផ្គត់ផ្គង់ និង អប់រំគ្រួសារដែលជាកត្តាជំរុញអោយកូនៗនិងគ្រួសារមានសុខភាពល្អ។

៧. អ្នកសំរបសំរួលចែកឯកសារមេរៀនទី២.៤ និងសុំឱ្យអ្នកចូលរួមអានចំណុចខ្លីៗ ហើយសួរសំនួរឬផ្តល់នូវយោបល់ពាក់ពន្ធ័នឹងមេរៀន។ អ្នកសំរបសំរួលឆ្លើយតបនឹងសំនួរនិងយោបល់ទាំងនោះ។

៨. អ្នកសំរបសំរួលសរុបចំណុចសំខាន់ៗ ពាក់ពន្ធ័ទៅនឹងខ្លឹមសារមេរៀន។

កំណត់សំគាល់សំរាប់អ្នកសំរបសំរួលៈ

ពន្យល់អ្នកចូលរួមឱ្យយល់ដឹង និងទទួលស្គាល់ថា ការឱ្យតម្លៃ និងការបង្ហាត់បង្ហាញខុសគ្នាៗរបស់សង្គមមកលើស្ត្រីនិងបុរស នឹងផ្តល់ត្រឡប់មកវិញនូវផលលំបាក និងផលប៉ះពាល់ជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់សង្គមទាំងមូល ជាពិសេសដល់ស្ត្រីនិងកុមារ។ បញ្ហាទាំងអស់នេះអាចដោះស្រាយបានប្រកបដោយប្រសិទ្ធភាព អាស្រ័យដោយមានការចូលរួមយ៉ាងយកចិត្តទុកដាក់ពីគ្រប់ស្ថាប័ននៅក្នុងសហគមន៍ និងក្នុងសង្គម ដែលក្នុងនោះរួមមានទាំងស្ត្រី.បុរស ក្មេងស្រី.ក្មេងប្រុស។

ឈឈឈឈ ☺☺☺ សសសស

គុណវិបត្តិដែលស្ត្រីបានទទួលនៅក្នុងជីវិត មានឥទ្ធិពលទៅលើសង្គមនិងសេដ្ឋកិច្ចជាតិ ហើយក៏មានផលប៉ះពាល់អវិជ្ជមានជាទូទៅដល់ប្រទេសជាតិផងដែរ។ នៅក្នុងប្រទេសកម្ពុជា ប្រជាពលរដ្ឋទាំងបុរសនិងស្ត្រីបានរួមចំណែកដល់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម។ កំលាំងពលកម្មផ្នែកកសិកម្មជាងពាក់កណ្ដាលជាស្ត្រី។ ឧស្សាហកម្មកាត់ដេរ ដែលភាគច្រើនផ្ដល់ការងារដល់ស្ត្រីវ័យក្មេង បានរួមចំណែកបង្កើនប្រាក់ចំណូលរបស់ប្រទេសមួយចំនួនធំ។ សង្គមកំណត់ឱ្យស្ត្រីទទួលខុសត្រូវស្ទើរតែទាំងស្រុងក្នុងការថែទាំ កូនចៅ និងសុខុមាលភាពនៃគ្រួសាររបស់ពួកគេ។

**ស្ថានភាពទូទៅរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា :**

- ស្ត្រីមានចំនួនប្រមាណ ៥១ភាគរយ នៃចំនួនប្រជាពលរដ្ឋទូទាំងប្រទេស ។
- ប្រហែល៨១ភាគរយ នៃស្ត្រីដែលមានអាយុចន្លោះពី ២០ ទៅ ៥៤ ឆ្នាំ រស់នៅក្នុងតំបន់ជនបទ ហើយជាកំលាំងពលកម្មសកម្មក្នុងវិស័យសេដ្ឋកិច្ច ។
- មានស្ត្រីជាមេគ្រួសារ ប្រមាណជា ២៤ភាគរយក្នុងចំណោមគ្រួសារទាំងអស់ ។
- ប្រហែល៦៤ភាគរយនៃក្មេងស្រីអាយុពី១៥ ទៅ១៩ឆ្នាំ ជាកំលាំងពលកម្មសកម្ម បើធៀបជាមួយក្មេងប្រុសស្ថិតក្នុងក្រុមអាយុដូចគ្នា គឺមានប្រមាណតែ ៤៣ភាគរយប៉ុណ្ណោះ ។

បុរសនិងស្ត្រីទទួលបាននូវស្ថានភាពនិងគុណភាពរស់នៅខុសៗគ្នា ដូចមានបង្ហាញនៅក្នុងក្រោមនេះ ដូចជា : **សុខភាព ការអប់រំ ការចូលរួមខាងនយោបាយ ការទទួលបានប្រាក់ចំណូល និងការគ្រប់គ្រងផ្នែកសេដ្ឋកិច្ច។**

**<u>សុខភាព</u>**

ដោយសារមុខងារបន្តពូជរបស់ពួកគេ ស្ត្រីមានតម្រូវថែទាំសុខភាពខ្លាំងជាងបុរស។ នៅក្នុងប្រទេសកម្ពុជា ជាទូទៅ ស្ត្រីមិនសូវទទួលបានការថែទាំសុខភាពត្រឹមត្រូវនៅក្នុងកំឡុងពេលមានគភ៌ និងសម្រាលកូន។ ជាលទ្ធផល ស្ត្រីកម្ពុជាមានអត្រាស្លាប់ខ្ពស់ដែលបណ្ដាលមកពីការមានផ្ទៃពោះនិងសម្រាលកូន (នៅក្នុងចំណោមប្រទេសនានានៅអាស៊ីអាគ្នេយ៍)។

រូបទី 1: ការប្រៀបធៀបអត្រាមរណៈរបស់មាតានិងទារកនៅក្នុងតំបន់




*ប្រភព : ធនាគារពិភពលោក ២០០២ : បញ្ហាយេនឌ័រនៅក្នុងផែនការនិងការចំណាយសាធារណៈ*
*Source: World Bank 2002. Gender Issues in Planning and Expenditure*

- នៅក្នុងតំបន់ជនបទ ស្ត្រីម្នាក់ជាមធ្យមមានកូន ៤នាក់ ហើយនៅតំបន់ទីក្រុង ស្ត្រីជាមធ្យមមានកូន៣នាក់។
- មានស្ត្រីតែ ៣២ភាគរយ ទទួលបានជំនួយការពីអ្នកផ្តល់សេវាសុខភាពដែលទទួលការបណ្តុះបណ្តាលនៅពេលសំរាលកូន។
- មានស្ត្រីតែ ៣៨ភាគរយទទួលបានការថែទាំមុនពេលឆ្លងទន្លេ។
- មានស្ត្រី ៦៥ភាគរយ មានបញ្ហាកង្វះឈាមក្រហម (ខ្វះជាតិដែក) នៅក្នុងពេលមានផ្ទៃពោះ ហើយមានស្ត្រី ៥៨ភាគរយមានបញ្ហាកង្វះឈាមក្រហមនៅអាយុចន្លោះពី១៥ទៅ៤៩ឆ្នាំ។
- មានស្ត្រីចំនួនពាក់កណ្តាលបានទទួលការថែទាំបន្ទាប់ពីសំរាលកូនរួច ។
- ស្ត្រីចំនួន ២.០០០ នាក់បានស្លាប់ជារៀងរាល់ឆ្នាំ ដោយសារបញ្ហានៃការសំរាលកូន (៤៧៣ ក្នុងចំនួន១០០.០០០ កំណើត)។ មរណៈភាពទាំងនេះភាគច្រើនអាចចៀសវាងបាន ដោយការអនុវត្តន៍ការថែទាំសុខភាព ការទទួលទានអាហារនិងសំរាកឱ្យបានគ្រប់គ្រាន់។
- មានស្ត្រីដែលបានរៀបការហើយចំនួនតែ ១៩ភាគរយប៉ុណ្ណោះដែលប្រើស្រោមអនាម័យជាវិធីពន្យាកំណើត និង២៤ភាគរយទៀតប្រើវិធីពន្យាកំណើតផ្សេងៗ ។ ចំនួន ២ភាគ៣នៃស្ត្រីនៅក្នុងប្រទេសកម្ពុជានិយាយថា "ពួកគេមិនចង់មានកូនថែមទៀតទេ ពួកគេចង់បានកូន

រធ្វើល"។ ការលើកឡើងនេះបង្ហាញថា មានតម្រូវការផ្នែកពន្យាកំណើតច្រើន ដែលពេលបច្ចុប្បន្នមិនទាន់បានដោះស្រាយឱ្យបានទូលំទូលាយនៅឡើយ។

- ស្ត្រីមានលក្ខណៈជីវសាស្ត្រដែលងាយនឹងរងគ្រោះពីជំងឺអេដស៍ ហើយតែងតែមានបញ្ហាលំបាកក្នុងការបញ្ចុះបញ្ចូលដៃគូអោយប្រើស្រោមអនាម័យ។
- ស្ត្រីមានផ្ទៃពោះចំនួនប្រហែលពី២.៥ភាគរយ ទៅ២.៧ភាគរយបានធ្វើតេស្តឈាម ហើយរកឃើញថាមានផ្ទុកមេរោគអេដស៍ (ទិន្នន័យកាលពី៣-៤ឆ្នាំមុន)។ នៅឆ្នាំខាងមុខ អាចមានស្ត្រីច្រើនថែមទៀតនឹងទទួលឆ្លងមេរោគអេដស៍ច្រើនជាងបុរស។

## វិស័យអប់រំ

នៅក្នុងប្រទេសកម្ពុជា មានក្មេងស្រីចំនួនតិចតួចដែលបានទទួលការអប់រំ។ អត្រានៃក្មេងស្រីធៀបទៅនឹងក្មេងប្រុសនៅថ្នាក់អប់រំកំរិតផ្សេងៗ មានបង្ហាញនៅក្នុងក្រាហ្វិកខាងក្រោម។ អត្រានេះកាន់តែមានគម្លាតខុសគ្នានៅពេលការអប់រំកាន់តែមានកំរិតខ្ពស់ឡើង។ នៅថ្នាក់បឋមសិក្សាមានអត្រាស្មើគ្នា តែនៅកំរិតសិក្សាកាន់តែខ្ពស់ ចំនួនក្មេងស្រីនៅក្នុងសាលាកាន់តែថយចុះ។ ការកង្វះការអប់រំរបស់ស្ត្រីពាក់ពន្ធ័នឹងកង្វះលទ្ធភាពក្នុងការរកការងារដែលមានកំរៃរបស់ស្ត្រី។ ម្យ៉ាងទៀត សុខភាពមាតានិងទារកមានការពាក់ពន្ធ័យ៉ាងខ្លាំងទៅនឹងកំរិតអប់រំដែលស្ត្រីជាមាតាបានទទួលបានកាលពីកុមារភាព ។

**រូបទី2: សមភាពយេនឌ័រនៅគ្រប់កំរិតអប់រំ**




*Source: EMIS 2001/2002 and Department of Higher Education, MOEYS.*
*Note: Tertiary Education data are for 2002/2003*

- កុមារីចំនួន ៨១ភាគរយបានចាប់ផ្តើមការសិក្សានៅសាលាបឋមសិក្សា ធៀបជាមួយកុមារា ដែលមានចំនួន ៨៧ភាគរយ។
- មានកុមារីចំនួន៤៧.៥ភាគរយ បានបញ្ចប់ការសិក្សានៅសាលាបឋមសិក្សា ធៀបជាមួយនឹង កុមារាដែលមានចំនួន៥៥ភាគរយ។
- កុមារីចំនួន១៨ភាគរយបានចាប់ផ្តើមការសិក្សានៅសាលាមធ្យមសិក្សាបឋមភូមិ ធៀបជាមួយ កុមារាចំនួន២០ភាគរយ។

<u>ការពង្រឹងអំណាចសេដ្ឋកិច្ច</u>

បច្ចុប្បន្ននេះ ស្ត្រីមានឱកាសបានចូលរួមនៅក្នុងវិស័យសេដ្ឋកិច្ច ប៉ុន្តែស្ថិតនៅក្នុងមុខរបរ បណ្តោះអាសន្ន មានប្រាក់កំរៃតិច ងាយរងគ្រោះ ពុំមានការការពារពីសង្គមនិងមុខរបរក្លួចតាចឬក្រៅ ផ្លូវការ។ ទន្ទឹមនឹងនេះ ស្ត្រីជួបប្រទះនឹងការលំបាកក្នុងការប្រឡងប្រណាំងនៅក្នុងសេដ្ឋកិច្ចទីផ្សារ មិន មានលទ្ធភាពក្នុងការប្រកបមុខរបរអចិន្ត្រៃយ៍ និងមានចំនួនតិចបំផុតដែលមានតួនាទីជាអ្នកដឹកនាំនៅ ក្នុងផ្នែកសេដ្ឋកិច្ច។ នៅក្នុងការស្រាវជ្រាវរបស់អង្គការស្បៀងអាហារពិភពលោកបានបង្ហាញអោយ ឃើញថា ភាពក្រីក្ររបស់ស្ត្រី មានដល់ទៅបួនដង លើអ្នកក្រីក្រធម្មតា ក្នុងនោះមាន : ១. គ្មានទ្រព្យ សម្បត្តិ ២. គ្មានកម្លាំងពលកម្ម ៣.គ្មានឥទ្ធិពល និង៤. គ្មានមធ្យោបាយសំរាប់ការផលិត។

ស្ត្រីទទួលកំរៃទាបជាងបុរសសំរាប់ការងារដូចគ្នា។ បុរសរកចំណូលបានពាពាភាគរយ លើស ស្ត្រី ទោះជាពួកគេមានការអប់រំត្រឹមកំរិតដូចគ្នា បទពិសោធន៍ដូចគ្នា និងអាយុដូចគ្នាក៏ដោយ ។




Source: LFS 2001

- មានស្ត្រីដែលធ្វើការត្រឹមតែចំនួន ៧ភាគរយ ដែលធ្វើការងារមានកំរៃ ធៀបទៅនឹងចំនួនបុរសមាន១៨ភាគរយ។
- ការងារភាគច្រើនរបស់ស្ត្រីជាការងារគ្មានកំរៃ។ ៦២ភាគរយនៃស្ត្រីបាននិយាយថាការងារបឋមរបស់ពួកគេជាការងារគ្មានកំរៃ ដែលជាការងារនៅក្នុងគ្រួសារ។
- ស្ត្រីកំរនឹងមានប្លង់ដី ហើយងាយរងគ្រោះពីការជណ្ដើមយកដីធ្លី ។ មានគ្រួសារដែលមានស្ត្រីជាមេគ្រួសារចំនួន២១ភាគរយ ដែលគ្មានដីធ្លីធៀបទៅនឹងគ្រួសារដែលមានបុរសជាមេគ្រួសារមានតែ១៣ភាគរយ ដែលគ្មានដីធ្លី។

## ការចូលរួមខាងផ្នែកនយោបាយ :

នៅក្នុងប្រទេសកម្ពុជា ស្ត្រីមិនសូវបានចូលរួម និងមិនសូវមានតួនាទីខ្ពស់ក្នុងការធ្វើសេចក្តីសំរេចខាងផ្នែកនយោបាយច្រើនដូចបុរសទេ។ កង្វះការចូលរួមក្នុងនយោបាយនេះ ធ្វើឱ្យស្ត្រីកាន់តែគ្មានអំណាច ហើយបញ្ហា និងតម្រូវការរបស់ស្ត្រីមិនទាន់ត្រូវបានដាក់បញ្ចូលអោយបានទូលំទូលាយនេ ក្នុងផែនការអភិវឌ្ឍនសេដ្ឋកិច្ចនិងសង្គមសំរាប់ប្រទេសឡើយ។

- មានចំនួន១១ភាគរយនៃសមាជិកសភាជាតិជាស្ត្រី ។
- មានចំនួន ១៣ភាគរយនៃសមាជិកព្រឹទ្ធសភាជាស្ត្រី ។
- គ្មានស្ត្រីជាអភិបាលខេត្ត-ក្រុងទេ ហើយមានស្ត្រីតែ១រូប ជាអភិបាលរងខេត្តទីពីរ ស្មើនឹង១.៣ភាគរយ។
- មានចំនួន ៩ភាគរយ នៃក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រី។

## អំពើហិង្សានៅក្នុងគ្រួសារ



អំពើហិង្សា ត្រូវបានសង្គមគ្រួសារកម្ពុជាភាគច្រើនចាត់ទុកថា ជាបញ្ហាទំនាស់ផ្ទៃក្នុងគ្រួសារដែលមិនបណ្តាលឱ្យមានបញ្ហាអ្វីធ្ងន់ធ្ងរដល់គ្រួសារនិងដល់សង្គមឡើយ។ តែជាក់ស្តែង អំពើហិង្សាបានផ្តល់នូវផលអាក្រក់យ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ និងសុខភាពផ្លូវចិត្តចំពោះសមាជិកគ្រួសារ (កូនស្រី-ប្រុស។ល។)។ អំពើហិង្សាត្រូវបានចាត់ទុកជាបទល្មើសទៅលើសិទ្ធិរបស់ស្ត្រី។

ការអង្កេតមួយបានរកឃើញថា មានស្ត្រី១នាក់ក្នុងចំណោមស្ត្រី៦នាក់ បានទទួលការរំលោភបំពានលើរាងកាយ ហើយនៅមុនពេលធ្វើអង្កេត១២ខែ មានស្ត្រី១នាក់ក្នុងចំណោមស្ត្រី៧នាក់ បានទទួលការរំលោភបំពានលើរាងកាយ។ ស្ត្រីភាគច្រើននិយាយថា "អំពើហិង្សាគឺជាកង្វល់ដ៏ធំរបស់ពួកគេ"។ អំពើហិង្សាក្នុងគ្រួសារត្រូវបានគេយល់ថា ជាបញ្ហានៅក្នុងផ្ទះ ហើយជាទូទៅរដ្ឋអំណាចមូលដ្ឋានតែងតែមានភាពស្ទាក់ស្ទើរក្នុងការអន្តរាគមន៍ ។

- ករណីរំលោភផ្លូវភេទភាគច្រើន មិនសូវបានបញ្ជូនទៅកាន់ប្រព័ន្ធកាត់ក្តីទេ។
- មានស្ត្រីរកស៊ីផ្លូវភេទចំនួនពី៤០-៦០ភាគរយត្រូវបានគេបង្ខំអោយធ្វើជាស្ត្រីរកស៊ីផ្លូវភេទ។
- កម្មការិនីរោងចក្រកាត់ដេរក៏កំពុងស្ថិតក្នុងគ្រោះថ្នាក់នៃការរំលោភផ្លូវភេទ រំលោភលើរាងកាយ និងការរំលោភផ្សេងទៀតដែរ ។
- មានក្មេងស្រីចំនួនប្រមាណជា១០០.០០០នាក់ ត្រូវបានគេធ្វើការជួញដូរ។
- មានស្ត្រីរកស៊ីផ្លូវភេទចំនួនប្រមាណ១០០.០០០នាក់ នៅក្នុងប្រទេសកម្ពុជា (បើប្រៀបធៀបទៅនឹងចំនួនកម្មការិនីកាត់ដេរដែលមានចំនួនតែប្រមាណ១៨០.០០០នាក់ប៉ុណ្ណោះ)។
- មានស្ត្រីរកស៊ីផ្លូវភេទជាច្រើន ឬ ស្ត្រីដែលត្រូវបានគេជួញដូរជាច្រើនត្រូវបានគេរំលោភបំពានធ្វើទារុណកម្ម និងរំលោភផ្លូវភេទ ។

## ផលប៉ះពាល់នៃវិសមភាពយេនឌ័រលើការអភិវឌ្ឍន៍ជាតិ

នៅក្នុងប្រទេសជាច្រើនបានបង្ហាញអោយឃើញថា បញ្ហាវិសមភាពយេនឌ័របានធ្វើអោយភាពក្រីក្រមានទំហំកាន់តែខ្លាំងឡើង ហើយភាពក្រីក្រក៏កាន់តែធ្វើអោយមានគម្លាតវិសមភាពរវាងប្រជាពលរដ្ឋប្រុសនិងស្រីកាន់តែច្រើនឡើង។

វិសមភាពរវាងក្មេងប្រុសនិងក្មេងស្រីក្នុងការទទួលសេវាអប់រំ និងការថែទាំសុខភាពមានកំរិតខ្ពស់នៅក្នុងចំណោមប្រជាពលរដ្ឋក្រីក្រជាងអ្នកដែលមានជីវភាពកំរិតខ្ពស់ ក្នុងនោះរួមមានទាំងការគ្រប់គ្រងធនធាន ផលិតកម្ម ឬអំណាច និងឥទ្ធិពលលើផ្នែកនយោបាយ។ គេសង្កេតឃើញថា នៅក្នុងសហគមន៍បុរសក្រីក្រតែងតែមានឥទ្ធិពលតិចជាងបុរសដែលមានជីវភាពធូរធារ ហើយជាទូទៅស្ត្រីក្រីក្រមានឥទ្ធិពលតិចតួចបំផុត។ ភាពខុសគ្នានេះបានធ្វើឱ្យស្ត្រី-ក្មេងស្រីគ្មានឱកាស និងធ្វើឱ្យលទ្ធភាពរបស់ពួកគេក្នុងការចូលរួមនិងទទួលផលប្រយោជន៍ពីការអភិវឌ្ឍន៍មានកំរិតទាប។

**ភាពទំនាក់ទំនងរវាងការលើកស្ទួយសិទ្ធិស្ត្រីនិងការអភិវឌ្ឍន៍ជាតិមានដូចតទៅ :**

- **ការធ្វើវិនិយោគទៅលើការអប់រំនិងលើសុខភាពរបស់ស្ត្រីនិងក្មេងស្រី គឺជាគុណសម្បត្តិនិងមានសារប្រយោជន៍ខ្ពស់:**

ស្ត្រីដែលមានការអប់រំនិងមានសុខភាពល្អ កាន់តែមានលទ្ធភាពខ្ពស់ក្នុងការចូលរួមក្នុងសកម្មភាពផលិតកម្ម និងអាចរកការងារក្នុងវិស័យផ្លូវការ (ដែលមានប្រាក់កំរៃសមរម្យនិងទៀងទាត់ជាប្រចាំ) អាចរកបានប្រាក់ចំណូលខ្ពស់ជាងស្ត្រីដែលមិនមានការអប់រំ និងស្ត្រីដែលមានសុខភាពមិនល្អ។ លើសពីនេះទៅទៀត ស្ត្រីដែលមានការអប់រំអាចផ្តល់ការអប់រំកូនរបស់ខ្លួនបានល្អ ដែលជួយធ្វើអោយយុវវ័យជំនាន់ក្រោយមានកំរិតអប់រំនិងមានគុណភាពខ្ពស់។ ឧទាហរណ៍ នៅក្នុងប្រទេសមួយចំនួន កូនរបស់ស្ត្រីដែលចេះអាននិងសរសេរបានចំណាយពេលចំនួនពីរម៉ោងក្នុងមួយថ្ងៃទៅលើការរៀនសូត្រច្រើនជាងកូនរបស់ស្ត្រីដែលមិនមានការអប់រំ។

- **កសិករជាស្ត្រីធ្វើការមានប្រសិទ្ធភាពដូចកសិករជាបុរសដែរ ហើយការបង្កើនការទទួលបាននូវសំភារៈនិងធនធាន និងបង្កើននូវផលិតផលផ្នែកកសិកម្មបានកំរិតខ្ពស់ :**

ក្នុងបណ្តាប្រទេសមួយចំនួនធំ ដែលមានស្ថាប័នជាច្រើនបានកំណត់ និងរារាំងស្ត្រីក្នុងការទទួលបាននូវសំភារៈ និងធនធានផលិតកម្ម ដូចជា ដីធ្លី សេវាកម្មហិរញ្ញវត្ថុ និងការងារក្នុងវិស័យផ្លូវការ។ ទទឹមនេះ ការមានប័ណ្ណកាន់កាប់ដីធ្លី គឺជាបញ្ហាពិសេស។ ស្ត្រីកំរមានប័ណ្ណកាន់កាប់ដីធ្លីណាស់ ទោះបីជាស្ត្រីភាគច្រើនជាអ្នកប្រើប្រាស់ដីក៏ដោយ។ ជាទូទៅស្ត្រីមិនអាចប្រើប្រាស់ប្លង់ដីសំរាប់បញ្ចាំខ្ចីឥណទានបានទេ។ នៅក្នុងប្រទេសមួយចំនួន មានភស្តុតាងបង្ហាញថា ប្រសិនបើស្ត្រីអាចទទួលបានធនធានដូចបុរស ផលិតផលកសិកម្មសរុប អាចនឹងត្រូវបានបង្កើនពី៦ភាគរយទៅ ២០ភាគរយ។

- **ការកាត់បន្ថយពេលវេលាដែលស្ត្រី និងក្មេងស្រីចំណាយទៅលើការរកអុស និងដកទឹក អាចជួយអោយពួកគេមានពេលសំរាប់បង្កើនប្រាក់ចំណូល :**

នៅតាមតំបន់ជាច្រើន ស្ត្រីបានធ្វើការជាច្រើនម៉ោងជាងបុរសក្នុងមួយថ្ងៃៗ ហើយនៅក្នុងប្រទេសជាច្រើនដែលមានប្រាក់ចំណូលទាប។ ស្ត្រីបានចំណាយពេលជាច្រើនម៉ោងទៅលើការរកអុសនិងដកទឹក។ ការចំណាយពេលវេលាដ៏ច្រើននេះរារាំងដល់ស្ត្រីក្នុងការចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូលនិងរារាំងការចូលរួមក្នុងកិច្ចការសហគមន៍។ ជាទូទៅក្មេងស្រីតែងតែត្រូវបានគេរក្សាទុកអោយនៅផ្ទះ ដើម្បីជួយធ្វើការងារផ្ទះសម្បែង ។

ស្ត្រីតែងតែប្រើប្រាស់ប្រាក់ចំណូលរបស់ខ្លួនទៅលើម្ហូបអាហារ ការអប់រំនិងតម្រូវការមូលដ្ឋានរបស់គ្រួសារ ។

ការបង្កើនប្រាក់ចំណូលរបស់ស្ត្រីនិងបង្កើនសុខុមាលភាពនៃគ្រួសារទាំងមូល :

នៅក្នុងសង្គមភាគច្រើន បុរសរក្សាទុកប្រាក់ចំណូលរបស់ខ្លួនមួយចំនួនសំរាប់លេងល្បែងស៊ីសង រួមភេទជាមួយស្ត្រីរកស៊ីផ្លូវភេទ និងសំរាប់គ្រឿងស្រវឹង ដែលកាត់បន្ថយដល់ប្រាក់ចំណូលក្នុងគ្រួសារ។ ជាទូទៅ ស្ត្រីមានឱកាសតិចតួចដើម្បីរកប្រាក់ចំណូល ហើយពួកគេតែងតែប្រើប្រាស់ប្រាក់ចំណូលដែលគេរកបានទៅលើការចំណាយសំរាប់ក្រុមគ្រួសារ។ ការបង្កើនឱកាសរកប្រាក់ចំណូលរបស់ពួកគេនឹងផ្តល់ប្រយោជន៍ខ្ពស់ និងភ្លាមៗ ដល់ក្រុមគ្រួសាររបស់ពួកគេ ដូចជាផ្នែកសុខភាព ផ្នែកអប់រំ និងតំរូវការជាមូលដ្ឋាន ។ល។

ឈឃឈឃ ☺☺☺ ឃងឃង

## ឯកសារមេរៀនទី២.៥ ៖ តម្រូវការយេនឌ័រ

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះអ្នកចូលរួមនឹងអាច ៖

* យល់ពីអត្ថន័យនៃពាក្យតម្រូវការយេនឌ័រ។
* កំណត់បានពីភាពខុសប្លែកគ្នារវាងតម្រូវការយេនឌ័រទាំងពីរ។

**រយៈពេល** : ប្រហែល៦០នាទី

**វិធីសាស្ត្រ** : អធិប្បាយ និងពិភាក្សាក្រុម។

**សំភារៈ** : ក្តារខៀន ក្រដាសផ្ទាំងធំ និង ហ្វឺត។

**ឯកសារមេរៀន** : ឯកសាររៀនទី២.៥ តម្រូវការយេនឌ័រ។

តារាង២.៦ គំរោងអភិវឌ្ឍន៍និងតំរូវការយេនឌ័រ

របៀបសំរបសំរួល ៖

១. អ្នកសំរបសំរួលសួរអ្នកចូលរួមថា ផ្អែកលើមេរៀនមុនៗ តើគេយល់ស្របទេថា ស្ត្រីនិងបុរសមានតម្រូវការខុសគ្នា និងត្រូវការការគាំទ្រខុសគ្នាពីកិច្ចអភិវឌ្ឍន៍។

២. អ្នកសំរបសំរួលចែកអ្នកចូលរួមជាបីក្រុម ហើយសុំឱ្យក្រុមនីមួយៗ គិតនិងពិភាក្សាអំពីតម្រូវការរបស់ស្ត្រីពីកម្មវិធីនៃកិច្ចអភិវឌ្ឍន៍។

៣. អ្នកសំរបសំរួលសុំឱ្យក្រុមនីមួយៗឡើងបង្ហាញដល់ក្រុមធំ។ អ្នកសំរបសំរួលបំផុសឱ្យក្រុមចូលរួមពិភាក្សា និងប្រៀបធៀបនូវតម្រូវការទាំងនោះ។

៤. អ្នកសំរបសំរួលសង្ខេបថា ស្ត្រីនិងបុរសមានតម្រូវការខុសគ្នាពីកិច្ចអភិវឌ្ឍន៍ ដោយស្ត្រីមានតួនាទីនិងការទទួលខុសត្រូវខុសពីបុរស ដូចនេះតម្រូវការរបស់ស្ត្រីក៏ខុសពីបុរសដែរ។ អ្នកសំរបសំរួលពន្យល់ថា អ្នកជំនាញផ្នែកយេនឌ័របានគិតថាតំរូវការរបស់ស្ត្រីមានពីរប្រភេទផ្សេងគ្នា គឺតម្រូវការជាក់ស្តែង និងតម្រូវការជាយុទ្ធសាស្ត្រ។

៥. អ្នកសំរបសំរួលពន្យល់ទៀតថា តម្រូវការជាក់ស្តែង គឺជាតម្រូវការរបស់ស្ត្រីដើម្បីបំពេញការទទួលខុសត្រូវរបស់ពួកគេដែលបានកំណត់ដោយសង្គម។ តម្រូវការទាំងនេះរួមមានការទទួលខុសត្រូវរបស់ស្ត្រីនៅក្នុងផ្ទះនិងនៅកន្លែងធ្វើការ។ ការបំពេញតំរូវការជាក់ស្តែងរួមមានការផ្តល់សុវត្ថិភាពស្បៀង អាហារ ទឹក ជំរក និងការថែទាំសុខភាព ជាពិសេសសំរាប់ស្ត្រី។ ឧទាហរណ៍ ស្ត្រីត្រូវការ

ទឹកស្អាត ហើយស្ត្រីប្រើរយៈពេលវែងដើម្បីដងទឹកស្អាត ដូចនេះតម្រូវការចំពោះមុខរបស់ស្ត្រីគឺទឹកស្អាត។

៦. អ្នកសំរបសំរួលពន្យល់ថា បញ្ហាវិសមភាពយេនឌ័រមិនអាចដោះស្រាយបានដោយការគិតគូរត្រឹមតែតម្រូវការចំពោះមុខនោះទេ ព្រោះស្ត្រីក៏ត្រូវការចំបាច់នូវការគ្រប់គ្រងទៅលើធនធាន និងការធ្វើសេចក្តីសំរេចនៅក្នុងគ្រួសារនិងក្នុងសង្គម និងមានតំណែងនិងឋានៈដូចបុរសដែរ។ការបង្កឱកាសឱ្យស្ត្រីទទួលបាននូវការគ្រប់គ្រងធនធាន និងការធ្វើសេចក្តីសំរេច ដូចជា: ដីធ្លី ប្រាក់ចំណូលការងារ ឥណទាន និងចូលរួមដឹកនាំក្នុងគណៈកម្មការនានា គឺជាការបំពេញតំរូវការជាយុទ្ធសាស្ត្ររបស់ស្ត្រី។ អ្នកសំរបសំរួលផ្តល់ឧទាហរណ៍នៃតំរូវការជាយុទ្ធសាស្ត្ររបស់ស្ត្រីនៅក្នុងភូមិ ដូចជាការចូលរួមលើការសំរេចស្តីពីផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់។ អ្នកសំរបសំរួលពន្យល់ថា កម្មវិធី និងគំរោងអភិវឌ្ឍន៍ភាគច្រើនដែលបានអនុវត្តនៅក្នុងសហគមន៍អាចត្រូវបានរៀបចំ និងអនុវត្តដើម្បីបំពេញតម្រូវការចំពោះមុខនិងតម្រូវការជាយុទ្ធសាស្ត្ររបស់ស្ត្រី។ ឧទាហរណ៍ : នៅក្នុងគំរោងស្តីពីការផ្គត់ផ្គង់ទឹកនៅក្នុងភូមិ តំរូវការចំពោះមុខរបស់ស្ត្រីទៅលើការមានទឹកស្អាត រីឯតំរូវការជាយុទ្ធសាស្ត្ររបស់ស្ត្រី គឺការចូលរួមក្នុងការធ្វើសេចក្តីសំរេច និងការគ្រប់គ្រងគំរោងទាំងនោះព្រោះស្ត្រីបានបង្កើននូវតួនាទីក្នុងការធ្វើសេចក្តីសំរេចនៅក្នុងសហគមន៍របស់គេ។

៧. អ្នកសំរបសំរួលគូរតារាងដែលមានកូឡោនបីលើក្តារខៀនឬក្រដាសផ្ទាំងធំ។ កូឡោនទី១ គឺគំរោងអភិវឌ្ឍន៍ កូឡោនទី២ គឺតម្រូវការចំពោះមុខ និងកូឡោនទី៣ គឺតម្រូវការជាយុទ្ធសាស្ត្រ។ អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមគិតពិភាក្សា និងផ្តល់ឧទាហរណ៍ពីឈ្មោះគំរោងអភិវឌ្ឍន៍នានានៅក្នុងសហគមន៍ពួកគេ។ អ្នកសំរបសំរួលកត់ចម្លើយនៅក្នុងកូឡោនទី១។ អ្នកសំរបសំរួលសួរអ្នកចូលរួមថា តើគំរោងណាខ្លះដោះស្រាយតម្រូវការចំពោះមុខ? គូសសញ្ញា (✓) ក្នុងកូឡោនទី២ ចំពោះគំរោងដែលដោះស្រាយតម្រូវការចំពោះមុខរបស់ស្ត្រី និងសួរអ្នកចូលរួមថា តើគំរោងណាខ្លះដោះស្រាយតម្រូវការជាយុទ្ធសាស្ត្ររបស់ស្ត្រី? គូសសញ្ញា (✓) ក្នុងកូឡោនទី២ចំពោះគំរោងដែលដោះស្រាយតម្រូវការយុទ្ធសាស្ត្ររបស់ស្ត្រី។ បើសិនអ្នកចូលរួមពិបាកក្នុងការផ្តល់ឧទាហរណ៍ពាក់ពន្ធ័នឹងតម្រូវការជាយុទ្ធសាស្ត្រ អ្នកសំរបសំរួលអាចផ្តល់ឧទាហរណ៍ជាក់ស្តែង ដូចជាការបញ្ចូលស្ត្រីទៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ការតែងតាំងអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ការបញ្ចូលស្ត្រីជាក្នុងគណៈកម្មការផែនការនិងថវិកា។ល។ គឺជាការដោះស្រាយតម្រូវការយុទ្ធសាស្ត្ររបស់ស្ត្រី ។

## ឯកសារ២.៦ គំរោងអភិវឌ្ឍន៍និងតម្រូវការយេនឌ័រ

| គំរោងអភិវឌ្ឍន៍ | តម្រូវការចំពោះមុខយេនឌ័រ | តម្រូវការយុទ្ធសាស្ត្រយេនឌ័រ |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

៨. អ្នកសំរបសំរួលពន្យល់ថាគំរោងនិងកម្មវិធីអភិវឌ្ឍន៍ត្រូវតែដោះស្រាយលើតម្រូវការទាំងពីរប្រភេទរបស់ស្ត្រី។ គំរោងនិងកម្មវិធីណាដែលបានយកចិត្តទុកដាក់លើតម្រូវការខុសគ្នារបស់ស្ត្រី និងបុរស មានន័យថាគំរោងនោះបានដោះស្រាយ និងឆ្លើយតបទៅនឹងយេនឌ័រ។

៩. អ្នកសំរបសំរួលពន្យល់អ្នកចូលរួមថា ក្នុងនាមជាអ្នកតំណាងឱ្យស្ត្រីនិងកុមារនៅឃុំ-សង្កាត់ (អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ)ពួកគេត្រូវរិះរកគ្រប់មធ្យោបាយនិងគិតគូរនូវការកែប្រែស្ថានភាពស្ត្រី និងកុមារ និងបញ្ចូលស្ត្រីក្នុងតួនាទីគ្រប់គ្រង និងធ្វើសេចក្តីសំរេច។

១០.អ្នកសំរបសំរួលចែកឯកសារមេរៀនទី២.៦ ដល់អ្នកចូលរួមនិងសួរតើពួកគេមានយោបល់ ឬចម្ងល់អ្វីទៀតឬទេ? ឆ្លើយនឹងសំណួររបស់អ្នកចូលរួម។

១១. អ្នកសំរបសំរួលសង្ខេបមេរៀន។

ឈឈឈឈ ☺☺☺ សសសស

# ឯកសារមេរៀនទី ២.៦ ៖ តម្រូវការយេនឌ័រ

ដោយសារតែទំនាក់ទំនង តួនាទី និងអំណាចដែលសង្គមបានផ្ដល់ដល់ស្ត្រី-បុរសមានលក្ខណៈខុសគ្នា សេចក្ដីត្រូវការរបស់គេក៏មានលក្ខណៈខុសគ្នាទៅតាមនោះដែរ។ ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការវិភាគបែងចែកឱ្យដាច់ពីគ្នារវាងតម្រូវការទាំងនោះ ដើម្បីធ្វើឱ្យកម្មវិធីនិងគំរោងអភិវឌ្ឍន៍ឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់ស្ត្រី និងបុរស។

**តម្រូវការយេនឌ័រមាន២ប្រភេទ៖**

### ១. តម្រូវការយេនឌ័រចំពោះមុខ



តម្រូវការចំពោះមុខ កើតចេញពីស្ថានភាពជាក់ស្ដែងដែលស្ត្រីបានជួបប្រទះនៅក្នុងការអនុវត្តន៍ការងារដែលកំណត់ឡើងដោយសារសង្គម។ តម្រូវការនេះទាក់ទងទៅនឹងការងារជាមេផ្ទះ ជាម្ដាយ ជាអ្នក ថែរក្សាផ្ទះសម្បែង និងការខ្វះខាតនៅក្នុងជីវភាពរស់នៅដូចជា៖ ចំណីអាហារ ទឹក ជំរក ប្រាក់ចំណូល ការថែទាំសុខភាព។ល។ តម្រូវការចំពោះមុខរបស់ស្ត្រី-បុរសអាស្រ័យលើឋានៈសេដ្ឋកិច្ចនៃ គ្រួសាររបស់ពួកគេ។

ជាទូទៅការដោះស្រាយតម្រូវការយេនឌ័រចំពោះមុខ មិនបានផ្លាស់ប្ដូរទំនាក់ទំនងយេនឌ័រនៅក្នុងសង្គមឡើយ។ ការវិភាគ និងការធ្វើផែនការដោយយកចិត្តទុកដាក់លើតម្រូវការចំពោះមុខនេះមានភាពចាំបាច់ណាស់ដើម្បីធានាថា រាល់កម្មវិធី និងគំរោងនានាត្រូវបានគ្រោងរៀបចំឡើងដើម្បីបំពេញនូវសេចក្ដីត្រូវការពិតប្រាកដរបស់ស្ត្រី-បុរស និងដើម្បីធានាថា ស្ត្រីទទួលបានការដោះស្រាយតម្រូវការជាយុទ្ធសាស្ត្ររបស់ខ្លួន និងអាចកែប្រែស្ថានភាព និងជីវភាពបានប្រសើរជាងមុន។

## ២. តម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ

តម្រូវការយេនឌ័រជាយុទ្ធសាស្ត្រកើតចេញមកពីបញ្ហា ឋានៈ និងតួនាទីបន្ទាប់បន្សំរបស់ស្ត្រី ដែលបានកំណត់ឡើងដោយសង្គម។ ស្ត្រីភាគច្រើនប្រៀបដូចជាក្រុមមនុស្សដែលគ្មានសិទ្ធិអំណាចស្ថិតនៅលំដាប់ក្រោមក្នុងសង្គម។



ការដោះស្រាយតម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ គឺធ្វើឡើងតាមរយៈការបង្កើត ឬកែប្រែគោលនយោបាយសំរាប់កែលំអឋានៈ និងតួនាទីរបស់ស្ត្រី និងលប់បំបាត់នូវរាល់ការរើសអើងប្រឆាំងនឹងស្ត្រីនិងកុមារ។ជាទូទៅដំណោះស្រាយនេះច្រើនទាក់ទងទៅនឹងគោលការណ៍ សមភាព សមធម៌ដែលអាចធ្វើឱ្យស្ត្រី-កុមារីមានឱកាសស្មើនឹងបុរស-កុមារក្នុងឱកាសទទួលការងារ ការបណ្តុះបណ្តាល ការអប់រំការ ធ្វើសេចក្តីសំរេច ប្រាក់បៀវត្សស្មើគ្នាចំពោះ ការងារដូចគ្នា សិទ្ធិកាន់កាប់ដីធ្លី និងទ្រព្យសម្បត្តិដទៃទៀត សិទ្ធិសេរីភាពក្នុងការជ្រើសរើស ការផ្តល់កំណើតកូន សិទ្ធិគ្រប់គ្រង លើធនធាន ផលកំរៃផ្សេងៗ និងការចូលរួមក្នុងដំណើរការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ។ល។

**ភាពខុសប្លែកគ្នារវាងតម្រូវការចំពោះមុខ តម្រូវការជាយុទ្ធសាស្ត្រ និងសារៈប្រយោជន៍**

| តម្រូវការចំពោះមុខ | តម្រូវការយុទ្ធសាស្ត្រ |
| --- | --- |
| ✧ ដោះស្រាយតម្រូវការសំរាប់តែស្ត្រីមួយចំនួនតែប៉ុណ្ណោះ<br>✧ ទាក់ទងទៅនឹងតំរូវការប្រចាំថ្ងៃ<br>✧ ងាយកំណត់បាន | ✧ ដោះស្រាយឋានៈសំរាប់ស្ត្រីទូទៅ<br>✧ ទាក់ទងទៅនឹងតួនាទីបន្ទាប់បន្សំរបស់ស្ត្រី<br>✧ ជាទូទៅពិបាកក្នុងការកំណត់ |
| **សារៈប្រយោជន៍សំរាប់ស្ត្រីៈតម្រូវការចំពោះមុខ** | **សារៈប្រយោជន៍សំរាប់ស្ត្រី ៈ តម្រូវការយុទ្ធសាស្ត្រ** |
| ✧ ជួយស្ត្រីឱ្យក្លាយទៅជាអ្នកទទួលផលប្រយោជន៍។<br>✧ លើកកំពស់ស្ថានភាពរស់នៅរបស់ស្ត្រី<br>✧ កាត់បន្ថយបន្ទុកការងាររបស់ស្ត្រី។<br>✧ លើកស្ទួយសុខភាពគ្រួសារ។<br>✧ បង្កើនការទទួលបាននូវការងារ | ✧ បង្កឱកាសស្មើគ្នាចំពោះការទទួលបានការងារជាពិសេសការងារ ដែលមិនមែនជាប្រពៃណី។<br>✧ កាត់បន្ថយការរើសអើងនិងការរងគ្រោះដែលបណ្តាលមកពីបញ្ហាអំពើហិង្សានិងការកៀបសង្កត់និងកេងប្រវ័ញ្ចរំលោភបំពាន មកលើស្ត្រី។<br>✧ បង្កើនសុវត្ថិភាពនិងឯករាជភាពផ្នែកសេដ្ឋកិច្ច។ |

| | |
|---|---|
| សិប្បកម្មឬមុខរបរផ្សេងៗ។ | ❖ ចងក្រងក្រុមសម្ព័ន្ធជាមួយនារីឯទៀត។<br>❖ បង្កើនការលើកកំពស់សមភាពផ្នែកនយោបាយ និងផ្នែកច្បាប់សំរាប់ស្ត្រី។<br>❖ បង្កើនសមត្ថភាពក្នុងការលើកកំពស់ជីវភាពរស់នៅ និងអនាគតគ្រួសារឱ្យកាន់តែប្រសើរ។<br>❖ កែប្រែការបែងចែកការងារតាមយេនឌ័រ។<br>❖ វិធានការកាត់បន្ថយបន្ទុកការងារក្នុងគ្រួសារ និងការថែទាំកូនរបស់ស្ត្រី។<br>❖ ចែករំលែកទំនួលខុសត្រូវចំពោះការងារបន្តពូជ។ |

**ឧទាហរណ៍: ដំណោះស្រាយសើតម្រូវការយេនឌ័រ**

| ប្រភេទនៃការធ្វើអន្តរាគមន៍ | តំរូវការចំពោះមុខ | តំរូវការជាយុទ្ធសាស្ត្រ |
|---|---|---|
| ❖ វគ្គហ្វឹកហ្វឺនពីការផ្សព្វផ្សាយផ្នែកកសិកម្ម | ✓ | |
| ❖ វគ្គហ្វឹកហ្វឺនមុខជំនាញ ដេរចាក់ កាត់សក់ | ✓ | |
| ❖ វគ្គហ្វឹកហ្វឺនមុខជំនាញគ្រប់គ្រង-ចាត់ចែង | ✓ | |
| ❖ វគ្គហ្វឹកហ្វឺនផ្នែកច្បាប់ | ✓ | |
| ❖ កម្មវិធីឥណទានសំរាប់ស្ត្រី | ✓ | |
| ❖ មានទីកន្លែងធ្វើការនិងទារកដ្ឋាននៅជិតគ្នា | ✓ | |
| ❖ មានសិទ្ធិកាន់កាប់ដីធ្លី ផ្ទះសម្បែង | | ✓ |
| ❖ បង្កើនសមាសភាពនៅក្នុងថ្នាក់ធ្វើសេចក្តីសំរេច | | ✓ |
| ❖ មានទារកដ្ឋាននៅក្នុងសហគមន៍ | ✓ | |
| ❖ មណ្ឌលសុខភាពនៅក្នុងសហគមន៍ | ✓ | |
| ❖ ផ្តល់បច្ចេកទេសសមស្របដល់ស្ត្រី | ✓ | |
| ❖ បង្កើនសមាសភាពប៉ូលិសស្ត្រី | | ✓ |
| ❖ បង្កើនសមាសភាពមេចារី ចៅក្រមជាស្ត្រី | | ✓ |
| ❖ បង្កើនចំនួនអ្នកផ្សព្វផ្សាយជាស្ត្រី | | ✓ |
| ❖ បង្កើនការចូលរួមរបស់បុរសនៅក្នុងផ្នែកសុខភាពបន្តពូជ | ✓ | |
| ❖ បង្កើតអន្តេវាសិកដ្ឋានសំរាប់សិស្សស្ត្រី | | ✓ |
| ❖ ផ្តល់អាទិភាពដល់ស្ត្រីក្នុងការប្រកបការងារ មុខរបរ ។ល។ | ✓ | |
| ❖ បង្កើនសមត្ថភាពក្នុងការធ្វើសេចក្តីសំរេចគ្រប់គ្រង ដឹកនាំ | | ✓ |

# តំរោងមេរៀនទី ២.៦ : ច្បាប់និងគោលនយោបាយដែលគាំទ្រសមភាពយេនឌ័រ

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀនអ្នកចូលរួមនឹងៈ

- យល់ដឹងពីគោលនយោបាយជាតិនិងអនុសញ្ញាអន្តរជាតិដែលលើកកំពស់ស្ថានភាព និងការគោរពនិងការពារសិទ្ធិស្ត្រី សិទ្ធិកុមារ។
- អាចប្រើប្រាស់គោលនយោបាយជាតិនិងអនុសញ្ញាអន្តរជាតិទាំងនេះជាមូលដ្ឋានក្នុងការបំពេញភារកិច្ចរបស់ពួកគេ។

**រយៈពេល** : ប្រហែល៦០នាទី

**វិធីសាស្ត្រ** : បទបង្ហាញនិងសំណួរបំផុសគំនិត។

**សំភារៈ** : ក្រដាសផ្ទាំងធំ និងសម្ភារៈផ្សេងៗ

**ឯកសារមេរៀន** : ឯកសារមេរៀនទី២.៦ គោលនយោបាយជាតិនិងអនុសញ្ញាអន្តរជាតិសំរាប់គាំទ្រសិទ្ធិស្ត្រី និងសិទ្ធិកុមារ។

**របៀបសំរបសំរួល** :

១. អ្នកសំរបសំរួលសួរអ្នកចូលរួមថា *តើពួកគេមានបានដឹងពីគោលនយោបាយ និងកម្មវិធីជាតិដែលទាក់ទងនឹងស្ត្រីនិងកុមារដែរឬទេ? មានអ្វីខ្លះ?* សរសេរចំលើយដាក់លើក្រដាសផ្ទាំងធំ។

២. អ្នកសំរបសំរួលបង្ហាញនិងអធិប្បាយម្តងមួយចំណុចពី *ច្បាប់គោលនយោបាយជាតិនិងអនុសញ្ញាអន្តរជាតិដែលគាំទ្រស្ត្រីនិងកុមារ* ។

៣. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមលើកឧទាហរណ៍កម្មវិធីឬគោលនយោបាយជាតិដែលការពារ និងលើកស្ទួយសិទ្ធិរបស់ស្ត្រីនិងកុមារនៅក្នុងឃុំរបស់ពួកគេ។ សរសេរចំលើយអ្នកចូលរួមដាក់ក្រដាសផ្ទាំងធំ។

៤. អ្នកសំរបសំរួលសួរអ្នកចូលរួមថា *តើពួកគេមានចម្ងល់និងយោបល់ពាក់ពន្ធ័នឹង គោលនយោបាយនិងកម្មវិធីខាងលើនេះ?* ឆ្លើយតបសំនួររបស់អ្នកចូលរួម។

៥. សង្ខេបចំណុចសំខាន់ៗនៃមេរៀន។

**កំណត់សំគាល់សំរាប់អ្នកសំរបសំរួល៖**

នៅក្នុងមេរៀននេះ មានបំណងដើម្បីឱ្យអ្នកចូលរួមបានយល់ដឹងពីគោលនយោបាយជាតិ និង អនុសញ្ញាអន្តរជាតិដែលគាំទ្រនិងលើកកំពស់ស្ថានភាពរបស់ស្ត្រីនិងកុមារ។ គោលបំណងមួយទៀត គឺ ដើម្បីលើកទឹកចិត្តដល់អ្នកចូលរួមក្នុង ការបំពេញភារកិច្ចរបស់ពួកគេឱ្យកាន់តែមានប្រសិទ្ធភាពដោយ ផ្អែកជាមូលដ្ឋានលើគោលនយោបាយជាតិនិងអនុសញ្ញាអន្តរជាតិទាំងអស់នេះ។ មេរៀននេះនឹងធ្វើឱ្យ អ្នកចូល រួមកាន់តែមានជំនឿទុកចិត្ត មោទនៈភាពលើស្នាដៃរបស់ពួកគេ និងបង្កើនការចូលរួមរបស់ ពួកគេឱ្យកាន់តែសកម្មឡើង ដើម្បីឈានទៅសំរេចបាននូវសមភាពនិងសមធម៌យេនឌ័រ និងលើកកំពស់ ស្ថានភាពស្ត្រី និងកុមារឱ្យកាន់តែប្រសើរឡើង។

ឈឈឈឈ ☺☺☺ ឈឈឈឈ

បច្ចុប្បន្ន រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាអ្នកផ្តល់ជំនួយជាច្រើនបានបង្កើនការយកចិត្តទុកដាក់លើសារៈសំខាន់ក្នុងការបញ្ចូលបញ្ហាយេនឌ័រទៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងគោលនយោបាយអភិវឌ្ឍន៍ជាតិក្នុងការលើកកំពស់ចីរភាពនៃកិច្ចអភិវឌ្ឍន៍សំរាប់ស្ត្រី និងសំរាប់ប្រជាពលរដ្ឋទូទៅ។ ដើម្បីកាត់បន្ថយភាពក្រីក្រតាមរយៈចីរភាពនៃកិច្ចអភិវឌ្ឍន៍ បញ្ហាគម្លាតយេនឌ័រក្នុងការទទួលបាននិងការគ្រប់គ្រងលើធនធាននិងឱកាសខាងផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ចត្រូវតែកាត់បន្ថយ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា :

ក). បានបង្កើតច្បាប់និងគោលនយោបាយសំរាប់លើកកំពស់សមភាពយេនឌ័រ

ខ). បានបញ្ចូលយេនឌ័រទៅក្នុងផែនការនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

គ). បានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិដែលគាំទ្រស្ត្រីនិងកុមារ

## ក). ច្បាប់និងគោលនយោបាយសំរាប់លើកកំពស់សមភាពយេនឌ័រ

ព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្នមានច្បាប់ និងគោលនយោបាយមួយចំនួនសំរាប់ការពារសិទ្ធិនិងសេរីភាពនិងលើកកំពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ។ ក្នុងចំណោមនោះក៏មានច្បាប់ និងគោលនយោបាយមួយចំនួនដែលលើកស្ទួយនិងការពារផលប្រយោជន៍របស់ស្ត្រី និងកុមារ។ ច្បាប់និងគោលនយោបាយសំខាន់ទាំងនោះមាន :

- នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានកំណត់ច្បាស់ថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាពចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌របស់ប្រទេសជាតិនិងក្នុងអាពាហ៍ពិពាហ៍និងគ្រួសារ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិជ្រើសរើសមុខរបរសមស្រប ទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។ ក្នុងនោះក៏មានវិធានការទប់ស្កាត់និងលុបបំបាត់ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រី។
- នៅក្នុងច្បាប់ការងារឆ្នាំ១៩៩៧ មានមាត្រាខ្លះការពារស្ត្រីនិងកុមារពីការប្រកបមុខរបរដែលមានគ្រោះថ្នាក់ ផ្តល់ការការពារជាពិសេសដល់ស្ត្រីមានផ្ទៃពោះនិងការពារការរើសអើងនិងកេងប្រវ័ញ្ចលើស្ត្រី។

■ ច្បាប់គ្រួសារនិងអាពាហ៍ពិពាហ៍អនុញ្ញាតិឱ្យលែងលះបាននៅក្នុងករណី "វាយដំនិងធ្វើបាបធ្ងន់ធ្ងរ" (មាត្រា៣៩) ។

■ អនុញ្ញាតិឱ្យមានការពន្លូតកូនក្រោមអាយុ ៣ខែ ក្នុងករណីចាំបាច់ដែលមិនអាចរក្សាទុកបាន។

■ ច្បាប់ប្រឆាំងនឹងការជួញដូរនិងពេស្យាចារ។ សេចក្តីព្រាងច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាដែលនឹងត្រូវអនុម័តក្នុងពេលខាងមុខនេះ។

ខ). **ផែនការនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**

១. **ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទី២ ឆ្នាំ២០០១-២០០៥**

នៅក្នុងផែនការនេះបានផ្តោតទៅលើការពង្រឹងការចូលរួមយ៉ាងសកម្មនិងមានអត្ថន័យរបស់ស្ត្រី ដើម្បីឱ្យស្ត្រីក្លាយទៅជាដៃគូដ៏សំខាន់ជាមួយបុរស និងទទួលបានផលប្រយោជន៍ស្មើនឹងបុរសនៅគ្រប់វិស័យទាំងអស់ក្នុងការអភិវឌ្ឍន៍ប្រទេសនិងសង្គម។

២. **យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនិងគោលដៅអភិវឌ្ឍន៍សហស្សវត្សថ្មី**

ក្នុងនេះមានគោលនយោបាយសំខាន់ៗពីរ សំរាប់ការអភិវឌ្ឍន៍ព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល៥ឆ្នាំខាងមុខនេះ។ នៅក្នុងគោលនយោបាយនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការកាត់បន្ថយគម្លាតយេនឌ័រនៅគ្រប់វិស័យនៃកិច្ចអភិវឌ្ឍន៍។ សំខាន់ជាងនេះទៅទៀត កិច្ចអន្តរាគមន៍នានាត្រូវតែដោះស្រាយនូវឧបសគ្គទាំងឡាយដែលរារាំងដល់ស្ត្រី និងបង្កឱកាសគ្រប់បែបយ៉ាងដល់ស្ត្រីដើម្បីឱ្យស្ត្រីអាចចូលរួមក្នុងកិច្ចអភិវឌ្ឍន៍បានពេញលេញ។ ជាពិសេសទៅទៀត នៅក្នុងគោលដៅទី៣នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សថ្មី" ការលើកកំពស់សមភាពយេនឌ័រ និងបង្កើនការអង់អាចនិងផ្តល់អំណាចដល់ស្ត្រី។ នៅក្នុងគោលដៅនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើលើការកាត់បន្ថយគម្លាតរវាងក្មេងស្រី-ក្មេងប្រុសនៅក្នុងការអប់រំគ្រប់កំរិត។ ក្នុងនោះក៏មានការធានាថា ស្ត្រីបានចូលរួមកាន់តែច្រើននៅក្នុងរាជរដ្ឋាភិបាល និង មានប្រាក់បៀវត្សឬប្រាក់កំរៃស្មើគ្នា។

៣. **ផែនការនារីរតនៈ**

ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន គឺជាស្ថាប័ននាំមុខក្នុងការលើកកំពស់ស្ថានភាពសេដ្ឋកិច្ចនិងសង្គមកិច្ចរបស់ស្ត្រីកម្ពុជានិងអតីតយុទ្ធជន ជំរុញការចូលរួមប្រកបដោយអត្ថន័យនិងសកម្មរបស់ស្ត្រីទៅក្នុងគ្រប់លំដាប់ថ្នាក់នៃរចនាសម្ព័ន្ធនិងដំណើរការអភិវឌ្ឍន៍របស់ប្រទេស។

ក្រសួងមានភារកិច្ចសំខាន់ៗ ដូចតទៅ :

- ជាអ្នកជំរុញ និងស្វែងរកការគាំទ្រមតិ ដើម្បីបញ្ចូលយេនឌ័រទៅក្នុងគោលនយោបាយនិងកម្មវិធីរបស់ក្រសួងពាក់ពន្ធ័ រដ្ឋបាលមូលដ្ឋាន និងស្ថាប័នសាធារណៈ។

- ជាអ្នកជំរុញ និងស្វែងរកការគាំទ្រមតិ ដើម្បីធានាថាបញ្ហារបស់ស្ត្រីនិងបញ្ហាយេនឌ័រត្រូវបានគេដាក់បញ្ចូលក្នុងដំណើរការធ្វើសេចក្តីសំរេច។
- ជាអ្នកផ្តល់ការណែនាំ សំរបសំរួលនិងកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាស្ត្រីនិងបញ្ហាយេនឌ័រ

ដើម្បីអនុវត្តតួនាទីនិងភារៈកិច្ចដ៏ធំធេងនេះ ក្រសួងបានបង្កើតផែនការនារីរតនៈ ដោយមានគោលដៅរយៈពេល គឺ "**ប្រជាពលរដ្ឋទាំងស្រីប្រុសរួបរួមគ្នាធ្វើដំណើរឆ្ពោះទៅមុខ ដើម្បីស្ថាបនាប្រទេសជាតិប្រកបដោយអភិវឌ្ឍន៍ និងសន្តិភាពលើកស្ទួយការគោរពច្បាប់និងវិន័យ តាមរយៈប្រពន្ធ័មួយដែលមានយុត្តិធម៌ និងតម្លាភាពនៃអភិបាលកិច្ចល្អដែលនាំទៅរកស្ថេរភាពសង្គម_សេដ្ឋកិច្ច និងនយោបាយ**"។ នារីរតនៈ "**នារីគឺជារតនៈសម្បត្តិ**" កំណត់វិស័យជាអាទិភាពសំខាន់ៗចំនួនប្រាំៈ ការបញ្រ្ជាបយេនឌ័រទៅលើវិស័យសុខភាព វិស័យអប់រំ ការបង្កើនភាពអង់អាចលើផ្នែកសេដ្ឋកិច្ច ការការពារផ្លូវច្បាប់ ការគ្រប់គ្រងនិងការកសាងសមត្ថភាព និងស្ត្រីក្នុងការធ្វើសេចក្តីសំរេច។

**គ). ច្បាប់អន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិស្ត្រីនិងសិទ្ធិកុមារ**

ប្រទេសកម្ពុជាបានចុះហត្ថលេខាលើច្បាប់ កតិកាសញ្ញា អនុសញ្ញាអន្តរជាតិជាច្រើន។ នៅក្នុងនោះមានអនុសញ្ញាមួយចំនួនដែលពាក់ព័ន្ធនឹងសិទ្ធិស្ត្រីនិងសិទ្ធិកុមារ។

**១. អនុសញ្ញាស្តីពីការបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី**[៧]

ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីការបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនារីនៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩២។ អនុសញ្ញានេះបានបញ្ចូលនូវអនុសាសន៍ដើម្បីកាត់បន្ថយនូវការគេងប្រវ័ញ្ចការរើសអើងនិងបង្កើននូវវិធានការលើកកំពស់ស្ថានភាព និងការគោរពសិទ្ធិស្ត្រីដែលជាសិទ្ធិមនុស្ស។ អនុសញ្ញានេះផ្តល់ជាមូលដ្ឋាននៃភាពស្មើគ្នារវាងស្ត្រីនិងបុរស ដោយធានានូវការទទួលបានស្មើគ្នា ឱកាសស្មើគ្នានៅក្នុងការរស់នៅជាសាធារណៈនិងក្នុងឆាកនយោបាយក្នុងនោះ មានការចូលរួមបោះឆ្នោត ឈរឈ្មោះឱ្យគេបោះឆ្នោត ក៏ដូចជាការអប់រំ សុខភាពនិងការប្រកបការងារ។ ក្នុងអនុសញ្ញានេះមានបញ្ជាក់ថា រដ្ឋាភិបាលប្រទេសនីមួយៗ ត្រូវតែមានវិធានការសមស្រប ដោយរួម មានច្បាប់ និងវិធានការជាក់លាក់នានា ដែលអាចផ្តល់ឱកាសដល់ស្ត្រីទទួលបាននូវការគោរពសិទ្ធិ និងសេរីភាពពេញលេញ។

ប្រទេសនីមួយៗដែលបានចុះហត្ថលេខាប្តេជ្ញាអនុវត្តនូវវិធានការដើម្បីបញ្ចប់នូវរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី ដូចតទៅ :

---

[៧] *ដកស្រង់សង្ខេបចេញពីអនុសញ្ញាស្តីពីការបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំង នឹងនារី*

- បញ្ចូលគោលការណ៍សមភាពរវាងស្ត្រីនិងបុរសនៅក្នុងប្រព័ន្ធច្បាប់នានា លុបចោលនូវច្បាប់ដែលរើសអើងស្ត្រី និងអនុមត័លើច្បាប់ដែលការពារស្ត្រី។
- បង្កើតសាលាកាត់ក្តីនិងស្ថាប័ននានាដើម្បីធានានូវការការពារស្ត្រីពីការរើសអើងយ៉ាងមានប្រសិទ្ធភាព។
- ធានាក្នុងការកាត់បន្ថយរាល់សកម្មភាពរើសអើងប្រឆាំងស្ត្រី ពីសំណាក់បុគ្គល ស្ថាប័ន និងសហគ្រាសនានា។

អនុសញ្ញានេះ គឺជាសិទ្ធិសញ្ញានៃសិទ្ធិមនុស្សតែមួយគត់ដែលធានានូវសិទ្ធិបន្តពូជរបស់ស្ត្រី និងផ្តោតលើវប្បធម៌និងប្រពៃណីដែលកំណត់នូវតួនាទីយេនឌ័រនិងទំនាក់ទំនងក្នុងគ្រួសារ។ អនុសញ្ញានេះធានានូវសិទ្ធិស្ត្រីក្នុងការទទួល ការផ្លាស់ប្តូរ ការរក្សាទុកនូវសញ្ជាតិកូនរបស់គេ។ រដ្ឋាភិបាលត្រូវអនុវត្តវិធានការដែលប្រឆាំងរាល់ទំរង់នៃការជួញដូរស្ត្រីនិងការកេងប្រវ័ញ្ចលើស្ត្រី។

រាល់ប្រទេសដែលបានចុះហត្ថលេខាត្រូវតែគោរពនិងអនុវត្តអនុសញ្ញានេះ ព្រមទាំងរៀបបញ្ជូនរបាយការណ៍ជាតិ យ៉ាងហោចណាស់រៀងរាល់៤ឆ្នាំម្តង ដោយមានបញ្ចូលនូវវិធានការនានាដែលគេបានអនុវត្តពាក់ពន្ធ័នឹងអនុសញ្ញា។

## ២. អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ[២]

ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩២។ អនុសញ្ញានេះមានទិសដៅដើម្បីធ្វើឱ្យកុមារទទួលបាននូវកុមារភាពមួយប្រកបដោយសុភមង្គល ហើយប្រើប្រាស់នូវសិទ្ធិនិងសេរីភាពដើម្បីជាគុណប្រយោជន៍សំរាប់ខ្លួនផ្ទាល់ សំរាប់សង្គម និងដើម្បីអំពាវនាវដល់មាតាបិតា ស្ត្រីបុរស អង្គការស្ម័គ្រចិត្ត អាជ្ញាធរមូលដ្ឋាននិងរដ្ឋាភិបាលអោយទទួលស្គាល់នូវសិទ្ធិនិងធ្វើអោយមានការគោរពសិទ្ធិទាំងអស់នេះ។

សិទ្ធិដែលមាននៅក្នុងផ្នែកនេះ គឺជាសិទ្ធិរបស់កុមារគ្រប់រូប ទោះបីគេជាអ្នកណាក៏ដោយ។

មាត្រា ១: កុមារគ្រប់រូបដែលមានអាយុក្រោម១៨ឆ្នាំ ត្រូវទទួលបាននូវសិទ្ធិទាំងអស់នេះ។

មាត្រា ២: កុមារគ្រប់រូបមានសិទ្ធិ ដែលមិនត្រូវទទួលនូវការរើសអើងគ្រប់រូបភាព។

មាត្រា ៣: កុមារគ្រប់រូបមានសិទ្ធិក្នុងការទទួលនូវសេចក្តីសំរេចល្អៗសំរាប់ពួកគេ។

មាត្រា ៤: កុមារគ្រប់រូបមានសិទ្ធិក្នុងការទទួលបានការគោរពសិទ្ធិនិងការអនុវត្តន៍ការគោរពសិទ្ធិពិតប្រាកដពីរដ្ឋាភិបាល។

មាត្រា៥: កុមារគ្រប់រូបមានសិទ្ធិ ទទួលបាននូវការថែទាំ គាំពារពីម្តាយឪពុក។

---

[២] *ដកស្រង់សង្ខេបចេញពីអនុសញ្ញាស្តីពីសិទ្ធិកុមារ*

មាត្រា៦: កុមារគ្រប់រូបមានសិទ្ធិ ក្នុងការរស់រានមានជីវិត។

មាត្រា៧: កុមារត្រូវចុះបញ្ជីកំណើត និងសិទ្ធិទទួលស្គាល់ម្ដាយឪពុករបស់ខ្លួន។

មាត្រា៩: កុមារគ្រប់រូបមានសិទ្ធិ រស់នៅជាមួយគ្រួសាររបស់គេ។ មិនឱ្យមានការបំបែកកុមារចេញពីគ្រួសារដោយបង្ខំ លើកលែងតែមានករណីចាំបាច់។

មាត្រា១០: កុមារគ្រប់រូបមានសិទ្ធិ ចេញចូលក្នុងប្រទេសដើម្បីជួបជុំជាមួយគ្រួសាររបស់គេ។

មាត្រា១១: កុមារគ្រប់រូបមានសិទ្ធិ ដែលមិនអាចត្រូវគេចាប់ពង្រត់ឬយកទៅបរទេសដោយខុសច្បាប់ទេ។

មាត្រា១២: កុមារគ្រប់រូបមានសិទ្ធិ សេរីភាពក្នុងការបញ្ចេញទស្សនៈទៅក្នុងវិស័យទាំងអស់ដែលទាក់ទងនឹងកុមារ។

មាត្រា១៣: កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវពត៌មានដែលពាក់ព័ន្ធដល់ការជំរុញផាសុកភាពផ្នែកសង្គម ស្មារតី សីលធម៌ និងសុខភាពផ្នែករាងកាយនិងសតិបញ្ញា។

មាត្រា១៥: កុមារគ្រប់រូបមានសិទ្ធិ ក្នុងការជួបជាមួយអ្នកដទៃ និងអាចចងក្រងក្លិបយុវជនបាន។

មាត្រា១៦: កុមារគ្រប់រូបមានសិទ្ធិ រស់នៅផ្ទាល់ខ្លួន។

មាត្រា១៧: កុមារគ្រប់រូបមានសិទ្ធិ ក្នុងការទទួលពត៌មានតាមវិទ្យុ ទូរទស្សន៍ សៀវភៅ។ល។

មាត្រា១៨: កុមារគ្រប់រូបមានសិទ្ធិ រស់នៅជាមួយឪពុក-ម្ដាយនិងក្រុមគ្រួសាររបស់គេ។

មាត្រា១៩: កុមារគ្រប់រូបមានសិទ្ធិ ទទួលបានការពារកុមារនូវរាល់ទំរង់នៃភាពហិង្សាដែលប៉ះពាល់រាងកាយ គំនិតបញ្ញា ការបំពារបំពានផ្លូវភេទ។ល។

មាត្រា២០: កុមារដែលគ្មានទីពឹងគ្រប់រូបមានសិទ្ធិទទួលបាននូវការការពារនិងថែទាំយ៉ាងពេញលេញពីរដ្ឋាភិបាល។

មាត្រា ២១: កុមារគ្រប់រូបមានសិទ្ធិ ទទួលបាននូវការចិញ្ចឹមនិងថែទាំយ៉ាងពេញលេញពីអ្នកដែលទទួលចិញ្ចឹម។

មាត្រា ២២: កុមារគ្រប់រូបមានសិទ្ធិ ទទួលបាននូវការការពារសុវត្ថិភាពនិងជួយឧបត្ថម្ភ ប្រសិនបើគេជាអ្នកភៀសខ្លួន។

មាត្រា ២៣: កុមារពិការគ្រប់រូបមានសិទ្ធិ ទទួលបាននូវការថែទាំនិងអប់រំជាពិសេស។

មាត្រា ២៤: កុមារគ្រប់រូបមានសិទ្ធិ ទទួលបាននូវការគាំពារផ្នែកសេវាសុខភាពសមស្រប។

មាត្រា ២៥: កុមារគ្រប់រូបមានសិទ្ធិ ទទួលបាននូវការពិនិត្យថែទាំ ទោះបីគេស្ថិតនៅកន្លែងណាក្រៅពីផ្ទះក៏ដោយ។

មាត្រា ២៦: កុមារក្រីក្រគ្រប់រូបមានសិទ្ធិ ទទួលបាននូវជំនួយពីរដ្ឋាភិបាល។

មាត្រា ២៧: កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវម្ហូបអាហារ សំលៀកបំពាក់ និងជំរកគ្រប់គ្រាន់។

មាត្រា២៨: កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការអប់រំដែលមានគុណភាព។

មាត្រា២៩: កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការអប់រំ ដែលអាចជួយឱ្យគេយល់ដឹងពីខ្លួនគេ អ្នកដទៃនិងសិទ្ធិរបស់ពួកគេ។

មាត្រា៣០: កុមារគ្រប់រូបមានសិទ្ធិប្រើប្រាស់ភាសា គោរពសាសនានិងវប្បធម៌របស់គេ។

មាត្រា៣១: កុមារគ្រប់រូបមានសិទ្ធិទទួលបានការសំរាក និងចូលរួមក្នុងផ្នែកតន្ត្រី និងសកម្មភាពវប្បធម៌ផ្សេងៗ។

មាត្រា៣២: កុមារគ្រប់រូបមានសិទ្ធិមិនធ្វើការងារដែលប៉ះពាល់ដល់សុខភាព សុវត្ថិភាពនិងការសិក្សារបស់គេ។

មាត្រា៣៣: កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការពារឱ្យផុតពីការប្រើប្រាស់គ្រឿងញៀននិងគ្រឿងស្រវឹង។

មាត្រា៣៤: កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការការពារពីការរំលោភផ្លូវភេទ ការបង្ខំឱ្យធ្វើពេស្យាកម្ម ហើយនិងការមើលងាយផ្លូវភេទ។

មាត្រា៣៥: កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការការពារពីការចាប់ពង្រត់និងការជួញដូរ។

មាត្រា៣៦: កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការពារពីការកេងប្រវ័ញ្ចផ្សេងៗ។

មាត្រា៣៧: កុមារគ្រប់រូបមិនត្រូវទទួលនូវការធ្វើទណ្ឌកម្មឬទារុណកម្មផ្សេងៗ និងមិនត្រូវរួមពន្ធធនាគារជាមួយមនុស្សពេញវ័យ។

មាត្រា៣៨: កុមារក្រោមអាយុ១៥ឆ្នាំ គ្រប់រូបមានសិទ្ធិមិនចូលរួមជាកងទ័ព ឬធ្វើសង្គ្រាម។

មាត្រា៣៩: កុមារដែលទទួលរងនូវការឈឺចាប់ ឬត្រូវគេបោះបង់ចោល ត្រូវទទួលបាននូវការផ្តល់ជំនួយនិងសង្គ្រោះ។

មាត្រា៤០: កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការការពារស្របច្បាប់នៅក្នុងតុលាការ។

មាត្រា៤១: ប្រសិនបើច្បាប់នៅប្រទេសដទៃទៀត មានភាពល្អប្រសើរជាងច្បាប់នេះ កុមារគ្រប់រូប អាចទទួលបាននូវច្បាប់នោះ។

មាត្រា៤២: កុមារគ្រប់រូបមានសិទ្ធិយល់ដឹងពីសិទ្ធិរបស់គេ។ រដ្ឋាភិបាលមានភារកិច្ចក្នុងការផ្សព្វផ្សាយច្បាប់នេះឱ្យបានទូលំទូលាយ។

មាត្រាផ្សេងទៀតក្រៅពីមាត្រាខាងលើនេះ គឺរៀបរាប់ពីភារកិច្ចរបស់រដ្ឋាភិបាលនិងស្ថាប័ននានាក្នុងការធ្វើឱ្យកុមារគ្រប់រូបទទួលបាននូវសិទ្ធិរបស់ពួកគេបានពេញលេញ។

ᨂᨂᨂᨂ ☺☺☺ ᨂᨂᨂᨂ

## គំរោងមេរៀនទី៣.១: តួនាទី និងការទទួលខុសត្រូវរបស់អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀន អ្នកចូលរួមនឹងអាច :

- យល់ដឹងពីតួនាទីនិងការទទួលខុសត្រូវរបស់អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ
- យល់ដឹងពីស្ថាប័នដែលពួកគេត្រូវធ្វើទំនាក់ទំនងនិងធ្វើកិច្ចសហការ។

**រយៈពេល** : ប្រហែល៦០នាទី។

**វិធីសាស្ត្រ** : ការបកស្រាយនិងពិភាក្សាក្រុមតូច។

**សំភារៈ** : ហ្វឺត ក្រដាសក៉ាមពណ៍ កន្ត្រៃ ក្រដាសផ្ទាំងធំ។ល។

**ឯកសារមេរៀន** :ឯកសារមេរៀន៣.១គោលការណ៍ណែនាំសំរាប់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ

**របៀបសំរបសំរួល :**

ក. **តួនាទីនិងការទទួលខុសត្រូវៈ**

១. អ្នកសំរបសំរួលចែកអ្នកចូលរួមជាក្រុមតូច។ សុំឱ្យក្រុមតូចនីមួយៗ ពិភាក្សាថា *តើអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារត្រូវមានតួនាទីនិងការទទួលខុសត្រូវអ្វីខ្លះ?* អ្នកចូលរួមសរសេរចំលើយលើក្រដាស់ផ្ទាំងធំ។

២. អ្នកសំរបសំរួលសុំឱ្យតំណាងក្រុមតូចនីមួយៗ ឡើងបង្ហាញលទ្ធផលដល់ក្រុមធំ។

៣. អ្នកសំរបសំរួលសង្ខេប ពីតួនាទីនិងការទទួលខុសត្រូវសំខាន់ៗ របស់អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារដែលបានបកស្រាយដោយក្រុមពិភាក្សានីមួយៗ។

៤. អ្នកសំរបសំរួលបង្ហាញឯកសារមេរៀនទី៣.១ ដោយប្រៀបធៀបជាមួយនឹងតួនាទី និងការទទួលខុសត្រូវដែលបានមកពីក្រុមពិភាក្សានីមួយៗ ។ ប្រសិនបើចាំបាច់ត្រូវពន្យល់លំអិតបន្ថែម។

៥. អ្នកសំរបសំរួលសួរអ្នកចូលរួម " *តើអ្វីដែលជាតម្លៃនិងសារៈសំខាន់របស់អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ?*។ សរសេរចម្លើយលើក្រដាសផ្ទាំងធំ។

៦. អ្នកសំរបសំរួលពន្យល់ថា នៅក្នុងមេរៀនមុនៗ ពួកគេបានរៀននិងយល់បានពីសារៈសំខាន់នៃសមភាពយេនឌ័រ និងតម្រូវការយេនឌ័ររបស់ស្ត្រីនិងកុមាររួចមកហើយ។ អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារមានតួនាទីនិងការទទួលខុសត្រូវយ៉ាងសំខាន់ក្នុងការលើកកំពស់សិទ្ធិ ដោះស្រាយនូវតម្រូវការរបស់ស្ត្រី-កុមារនៅក្នុងឃុំ-សង្កាត់របស់ពួកគេ។

៧. អ្នកសំរបសំរួលសួរអ្នកចូលរួម *តើពួកគេមានចម្ងល់អ្វីឬទេ?* អ្នកសំរបសំរួលបកស្រាយនូវចម្ងល់ទាំងនេះ។ អ្នកសំរបសំរួលសង្ខេប និងសរុបបញ្ចប់។

**ឌ. ស្ថាប័ននិងក្រុមពាក់ព័ន្ធផ្សេងៗ ដែលអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារត្រូវប្រស្រ័យទាក់ទង**

១. អ្នកសំរបសំរួលបង្ហាញ និងពន្យល់ពីស្ថាប័ននិងក្រុមផ្សេងៗដែលអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារត្រូវធ្វើការប្រស្រ័យទាក់ទងជាមួយ។

២. អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា *តើពួកគេស្គាល់ច្បាស់នូវក្រុមពាក់ព័ន្ធផ្សេងៗ នោះដែរឬទេ?* និងសុំឱ្យពួកគាត់គិតពី *មធ្យោបាយ និងមូលហេតុអ្វីខ្លះក្នុងការប្រស្រ័យទាក់ទងជាមួយក្រុមពាក់ព័ន្ធទាំងនេះ*។ អ្នកសំរបសំរួលសរសេរចំលើយដាក់លើក្រដាសផ្ទាំងធំ។

៣. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួម*ផ្តល់យោបល់ពីជំនាញផ្សេងៗដែលពួកគេត្រូវការសំរាប់ការប្រស្រ័យទាក់ទងទាំងនេះ* និងសរសេរចំលើយដាក់លើក្រដាសផ្ទាំងធំ។

៤. អ្នកសំរបសំរួលធ្វើការសង្ខេបដូចតទៅៈ អ្នកទទួលបន្ទុកកិច្ចការនារី និង កុមារត្រូវប្រស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធជាច្រើន ហើយការប្រស្រ័យទាក់ទងនេះអាចធ្វើតាមមធ្យោបាយផ្សេងៗ និងសំរាប់មូលហេតុផ្សេងៗ។ ពួកគេអាចត្រូវធ្វើការពិគ្រោះយោបល់ ផ្តល់-ទទួលពត៌មាន ចរចា និងស្វែងរកការគាំទ្រមតិក្នុងនាមពួកគេជាតំណាងរបស់ស្ត្រីនិងកុមារនៅក្នុងឃុំ-សង្កាត់។ សំរាប់អនុវត្តការប្រស្រ័យទាក់ទងទាំងនេះឱ្យមានប្រសិទ្ធភាព ពួកគេត្រូវការពត៌មាន និងជំនាញផ្សេងៗជាច្រើន។ នៅក្នុងមេរៀនបន្តបន្ទាប់ខាងមុខនឹងមានបង្រៀននិងអនុវត្តនូវជំនាញទាំងអស់នេះ។

## ឯកសារមេរៀនទី៣.១: គោលការណ៍ណែនាំសំរាប់អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ

អនុក្រិត្យលេខ២២អនក្រ.បក ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០២ ស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅអោយក្រុមប្រឹក្សាឃុំ-សង្កាត់របស់រាជរដ្ឋាភិបាល មាត្រា១៩ បានចែងថាក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវតែងតាំងសមាជិកស្រ្តីមួយរូបជាអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ណាដែលពុំមានសមាជិកស្រ្តី ត្រូវតែងតាំងស្រ្តីមួយរូបពីខាងក្រៅជាអ្នកជំនួយការកិច្ចការនារីនិងកុមារ។

ដើម្បីជាជំនួយដល់អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារក្នុងការអនុវត្តន៍ការងាររបស់គេឱ្យមានប្រសិទ្ធភាព ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន សហការជាមួយក្រសួងមហាផ្ទៃ និងមានការគាំទ្រពីគំរោងភាពជាដៃគូសំរាប់អភិបាលកិច្ចមូលដ្ឋាន បានរៀបចំបង្កើតសេចក្តីព្រាងនូវតួនាទីនិងការទទួលខុសត្រូវរបស់អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារទាំងនេះឡើង។ គណកម្មាធិការជាតិគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់នឹងចេញជាគោលការណ៍ណែនាំពីតួនាទីនិងការទទួលខុសត្រូវទាំងនេះជាផ្លូវការក្នុងពេលឆាប់ៗ ខាងមុខនេះ។

<u>ភារកិច្ចនិងការទទួលខុសត្រូវៈ</u>

- ទំនាក់ទំនងជាមួយស្ត្រី-បុរសនិងកុមារនៅក្នុងឃុំ-សង្កាត់អំពីបញ្ហារបស់ស្ត្រីនិងកុមារនិងលើកបញ្ហាទាំងអស់នេះនៅក្នុងការប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់។
- ធានាថាស្ត្រីអាចចូលរួមបញ្ចេញគំនិតនិងយោបល់នៅក្នុងការកសាងផែនការអភិវឌ្ឍន៍មូលដ្ឋាន។
- ធានាថានៅក្នុងពេលកសាងផែនការអភិវឌ្ឍន៍មូលដ្ឋាន តម្រូវការអាទិភាពរបស់ស្ត្រីត្រូវបានគេយកចិត្តទុកដាក់ដូចតម្រូវការរបស់បុរសដែរ។
- ធានាថា គំរោងអភិវឌ្ឍន៍ថ្នាក់ឃុំ-សង្កាត់ឆ្លើយតបនិងដោះស្រាយនូវតម្រូវការរបស់ស្ត្រី និងកុមារ។
- ទំនាក់ទំនងជាមួយមន្ត្រីថ្នាក់ស្រុក-ខ័ណ្ឌ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលធ្វើការនៅក្នុងឃុំពីបញ្ហា និងសកម្មភាពរបស់ស្ត្រីនិងកុមារ។

- ទំនាក់ទំនងជាមួយជនបង្គោលដ៏ទៃទៀតនិងមន្ត្រីផ្សព្វផ្សាយនៅថ្នាក់ឃុំ-សង្កាត់ (ការគ្រប់គ្រងធនធានធម្មជាតិ យេនឌ័រ កសិកម្ម សុខាភិបាល ។ល។) ពីបញ្ហាស្ត្រីនិងកុមារ និង បញ្ចូលបញ្ហានេះទៅក្នុងការងាររបស់គេ។
- ស្វែងរកការគាំទ្រមតិដើម្បីអោយស្ត្រីបានចូលរួមធ្វើសេចក្តីសំរេចនិងទទួលបាននូវធនធាននិងផលប្រយោជន៍ដូចបុរសដែរ។
- ទំនាក់ទំនងពីពត៌មានពាក់ពន្ធ័នឹងសិទ្ធិនិងបញ្ហាផ្សេងៗរបស់ស្ត្រីនិងកុមារនិងក្រុមប្រឹក្សាឃុំ-សង្កាត់។
- ទំនាក់ទំនងនិងបញ្ចូលនូវសិទ្ធិនិងពត៌មានផ្សេងៗពាក់ពន្ធ័នឹងស្ត្រីនិងកុមារទៅក្នុងពត៌មានរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់។
- ផ្សព្វផ្សាយពីចំណេះដឹងពីគោលគំនិតយេនឌ័រដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍។

## ស្ថាប័ននិងក្រុមពាក់ពន្ធ័នានាដែលអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារត្រូវប្រាស្រ័យទាក់ទង



# គំរោងមេរៀនទី៤.១: សេចក្តីផ្តើមស្តីពីការប្រស្រ័យទាក់ទង

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ អ្នកចូលរួមទាំងអស់នឹងអាចៈ

* កំណត់បានពីចំណុចសំខាន់ៗ នៃគោលការណ៍ការប្រស្រ័យទាក់ទង។

**រយៈពេល** : ប្រហែល៤៥នាទី។

**វិធីសាស្ត្រ** : អធិប្បាយ និងសំនួរបំផុសគំនិត។

**សំភារៈ** : ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត និងកន្ត្រៃ។

**ឯកសារមេរៀន** : ឯកសារមេរៀនទី ៤.១ គោលការណ៍នៃការប្រស្រ័យទាក់ទង។

**របៀបសំរបសំរួល** :

១. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមរកពាក្យដែលមានអត្ថន័យស្រដៀងនឹងពាក្យប្រស្រ័យទាក់ទង។ អ្នកសំរបសំរួលសរសេរចំលើយដាក់លើក្រដាសផ្ទាំងធំ។

២. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមពិពណ៌នាពីស្ថានភាពផ្សេងៗដែលមនុស្សម្នាក់ៗធ្វើការប្រស្រ័យទាក់ទង ដោយសួរថា *តើការប្រស្រ័យទាក់ទងមានលក្ខណៈដូចម្តេច?* អ្នកសំរបសំរួលសរសេរចំលើយដាក់ក្រដាស់ផ្ទាំងធំ។

៣. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមរៀបរាប់ពីបច្ចេកទេសខ្លះៗ ដែលពួកគាត់ធ្លាប់ធ្វើការប្រស្រ័យទាក់ទងដែលមានប្រសិទ្ធភាព។ សរសេរចំលើយដាក់ក្រដាស់ផ្ទាំងធំ។

៤. អ្នកសំរបសំរួលបង្ហាញនិងអធិប្បាយស្តីពីឯកសារមេរៀនទី ៤.១ សេចក្តីសង្ខេបស្តីពីមូលដ្ឋានគោលការណ៍នៃការប្រស្រ័យទាក់ទងដែលមានប្រសិទ្ធភាព។

៥. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមមានយោបល់ និងសួរសំនួរ។ ឆ្លើយតបទៅនឹងយោបល់និងសំនួររបស់ពួកគាត់។

៦. អ្នកសំរបសំរួលធ្វើសេចក្តីសង្ខេបទៅតាមខ្លឹមសារនៅក្នុងគោលការណ៍នៃការប្រស្រ័យទាក់ទង។

## គោលការណ៍នៃការប្រស្រ័យទាក់ទង:

១. ស្គាល់អ្នកដែលត្រូវប្រស្រ័យទាក់ទងជាមួយ
២. ធ្វើឱ្យសារ[1] របស់អ្នកមានភាពសាមញ្ញ
៣. ត្រូវមានពត៌មានពិត
៤. ប្រើប្រាស់សំភារៈទស្សន៍និងឧទាហរណ៍ពិតៗ
៥. ប្រើភាសាកាយវិការដែលមានប្រសិទ្ធភាពនិងទាក់ទាញ
៦. ការស្តាប់ ការសួរសំនួរនិងការសង្ខេប

១. ស្គាល់អ្នកដែលត្រូវប្រស្រ័យទាក់ទងជាមួយ

- ត្រូវដឹងចំនួនមនុស្សដែលត្រូវប្រស្រ័យទាក់ទងជាមួយ។
- ត្រូវដឹងពីអាទិភាព និងតម្រូវការរបស់ពួកគេ។
- ត្រូវដឹងថាតើអ្នកមានពេលប៉ុន្មានជាមួយពួកគេ។

២. ធ្វើឱ្យសាររបស់អ្នកមានភាពសាមញ្ញ

- នៅក្នុងការប្រស្រ័យទាក់ទងរបស់អ្នកត្រូវឱ្យមានសារតែមួយ។
- មិនត្រូវឱ្យសាររបស់អ្នកមានភាពស្មុគស្មាញទេ ព្រោះបណ្តាលឱ្យងាយនឹងភ្លេច។
- សាររបស់អ្នកត្រូវបង្ហាញឱ្យឃើញពីផលប្រយោជន៍ដល់អ្នកទទួល។

៣. ត្រូវមានពត៌មានពិត

- ពត៌មានពិតនាំឱ្យសាររបស់អ្នកមានភាពគួរអោយជឿទុកចិត្តបាន។
- រកឱ្យបានពត៌មានពិតពីទីកន្លែងជាច្រើនតាមដែលអាចធ្វើទៅបាន។
- ធ្វើយ៉ាងណាមិនត្រូវអោយពត៌មានពិតរបស់អ្នកមានភាពផ្ទុយគ្នាឡើយ។
- ភ្ជាប់ពត៌មានពិតរបស់អ្នកទៅនឹងការការពារគំនិតរបស់អ្នក។

៤. ប្រើប្រាស់សំភារៈទស្សន៍និងឧទាហរណ៍:

- ប្រើប្រាស់សំភារៈជាក់ស្តែងយកមកបង្ហាញ និងលើកឧទាហរណ៍បញ្ជាក់បន្ថែម។

[1] សារគឺជាប្រយោគឃ្លាដែលត្រូវលើកយកមកនិយាយឬបង្ហាញ។

## ៥. ប្រើភាសាកាយវិការដែលមានប្រសិទ្ធិភាព

- បង្ហាញកាយវិការ ទឹកមុខទៅតាមខ្លឹមសារនៃសាច់រឿង។

## ៦. ការស្តាប់ ការសួរសំនួរ និងការសង្ខេប

- ការស្តាប់ប្រកបដោយប្រសិទ្ធភាព ទាមទារឱ្យអ្នកស្តាប់ផ្តោតការចាប់អារម្មណ៍ដោយពេញលេញទៅលើអ្វីដែលមនុស្សម្នាក់ទៀតនិយាយ។
- ការសួរអាចតាមរយៈសំនួរបើក និងសំនួរបិទ។
    - ☞ លក្ខណៈសំនួរបិទច្រើនប្រើពាក្យ អ្នកណា? អ្វី? នៅទីណា? នៅពេលណា?
    - ☞ លក្ខណៈសំនួរបើកច្រើនប្រើពាក្យ ហេតុអ្វី? ដូចម្តេច? របៀបណា?
- ការសង្ខេបៈ ដើម្បីពិនិត្យឱ្យដឹងថា អ្នកបានយល់ដូចទៅនឹងអ្វីដែលបុគ្គលណាម្នាក់បាន និយាយ និងដើម្បីពិនិត្យឡើងវិញនូវការសំរេច ឬពិនិត្យឡើងវិញនូវចំណុចសំខាន់ៗ។

☹ 😐 ☺

គោលបំណង : នៅចុងបញ្ចប់នៃមេរៀននេះ អ្នកចូលរួមទាំងអស់នឹងអាចៈ

- អនុវត្តបាននូវជំនាញក្នុងការស្តាប់ និងធ្វើសេចក្តីសង្ខេបនូវអ្វីដែលពួកគេបានស្តាប់។
- អាចអនុវត្តប្រើប្រាស់នូវសំណួរបិទនិងសំណួរបើក។

រយៈពេល : ប្រហែល៩០នាទី

វិធីសាស្ត្រ : អានអត្ថបទ និងការសំដែងតួ។

សំភារៈ : ការអធិប្បាយនិងពិភាក្សាក្រុមតូច។

ឯកសារមេរៀន : អត្ថបទដកស្រង់ពីកាសែត ឬព្រឹត្តិប័ត្រ។
មេរៀនទី៤.២ ជំនាញក្នុងការស្តាប់ ការសួរសំណួរនិងការសង្ខេប។

របៀបសំរបសំរួល :

ក. ការស្តាប់

១. អ្នកសំរបសំរួលពន្យល់អ្នកចូលរួមថា ក្នុងពេលពួកគេនឹងរៀននិងអនុវត្តសាកល្បងអំពីការស្តាប់ ការសួរ សំណួរ និងការសង្ខេប។

២. អ្នកសំរបសំរួលចែកអត្ថបទកាសែត ឬព្រឹត្តប័ត្រដល់អ្នកចូលរួម ហើយសុំឱ្យអ្នកចូលរួមទាំងអស់ អានអត្ថបទដែលបាន ចែកជូននោះដោយស្ងាត់ស្ងៀមមិនឱ្យមានការជជែកឬផ្លាស់ប្តូរយោបល់គ្នាឡើយ។

៣. បន្ទាប់មកអ្នកសំរបសំរួលចែកអ្នកចូលរួមជាក្រុមតូចៗ ។ សមាជិកទាំងអស់ក្នុងក្រុមនីមួយៗ ត្រូវសម្តែងតួម្តងម្នាក់ៗ ***ដោយសមាជិក១រូបជាអ្នកនិយាយ ១រូបទៀតជាអ្នកស្តាប់ និង១រូបទៀតជាអ្នកសង្កេត*** អ្នកទាំងនោះត្រូវបំពេញភារៈកិច្ចដូចតទៅ:

- អ្នកនិយាយ ត្រូវនិយាយពីចំណាប់អារម្មណ៍ដែលបានទទួលពីអត្ថបទ ក្នុងរយៈពេល២-៣នាទី ដោយមិនឱ្យអ្នកដ៏ទៃរំខាន ។
- អ្នកស្តាប់មិនត្រូវកត់ត្រាឡើយ គឺគ្រាន់តែស្តាប់ ហើយប្រសិនបើចាំបាច់និយាយបន្ទរពីរបីមាត់ (ដូចជាមែនហើយ ពិតប្រាកដហើយ អញ្ចឹងឬ ។ល។) ដើម្បីលើកទឹកចិត្តដល់អ្នកនិយាយ។ បន្ទាប់ពីអ្នកនិយាយ និយាយចប់ អ្នកស្តាប់ត្រូវសង្ខេបនូវអ្វីដែលអ្នកនិយាយបាននិយាយរួច។

- អ្នកសង្កេតអាចកត់ត្រា ប៉ុន្តែត្រូវមើលអ្នកនិយាយនិងអ្នកស្តាប់។ អ្នកសង្កេតអាចកែតំរូវឬបន្ថែមលើអ្វីដែលអ្នកស្តាប់មិនបាននិយាយ។

៤. បន្តធ្វើលំហាត់នេះដដែលដោយប្តូរតួនាទី *អ្នកនិយាយ អ្នកសង្ខេប អ្នកសង្កេត* រវាងសមាជិកនៅក្នុងក្រុមនីមួយៗរហូតដល់បានសម្តែងគ្រប់គ្នា។

៥. បន្ទាប់ពីធ្វើលំហាត់រួចហើយ សុំអោយក្រុមធំផ្តល់យោបល់តាមសំនួរខាងក្រោមៈ

- ▢ *តើតួនាទីអ្វីដែលងាយស្រួលជាងគេ?*
- ▢ *ក្នុងនាមជាអ្នកនិយាយ តើអ្វីដែលជាការងាយស្រួល? អ្វីជាការលំបាក?*
- ▢ *ក្នុងនាមជាអ្នកស្តាប់ តើអ្វីដែលជាការងាយស្រួល? អ្វីជាការលំបាក?*
- ▢ *តើអ្វីជាឧបសគ្គដល់ការស្តាប់?*
- ▢ *តើការសង្ខេប និង បកស្រាយ មានការលំបាកអ្វីខ្លះ?*
- ▢ *ក្នុងនាមជាអ្នកសង្កេតតើមានភាពងាយស្រួលអ្វីខ្លះ?មានការលំបាកអ្វីខ្លះ?*
- ▢ *តើការកាត់កត់ត្រាមានគុណសម្បត្តិអ្វីខ្លះ?*

៦. សុំឱ្យអ្នកចូលរួមពិភាក្សាអំពីការអនុវត្តន៍ជាក់ស្តែងនូវការស្តាប់និងការសង្ខេបនៅក្នុងការងាររបស់ពួកគេ។

៧. អ្នកសំរបសំរួលធ្វើសេចក្តីសង្ខេបមេរៀន ។

ខ. ការសួរសំណួរបិទនិងសំណួរបើក

១. អ្នកសំរបសំរួលសួរអ្នកចូលរួមថា *តើធ្លាប់ឮពាក្យសំណួរបើក និងសំនួរបិទបានទេ? សុំឱ្យអត្ថន័យនិងឧទាហរណ៍* និងសរសេរចំលើយដាក់លើក្រដាស់ផ្ទាំងធំ។

២. អ្នកសំរបសំរួលពន្យល់ថា *ចំពោះសំនួរបិទ ចំលើយដែលឆ្លើយតបភាគច្រើនគឺ បាទ ចាស់ និងទេ*។

៣. អ្នកសំរបសំរួលពន្យល់ថាសំនួរបើកមិនមែនឆ្លើយថា "*បាទ ចាស់ និងទេ*" នោះទេ គឺតម្រូវឱ្យមានចំលើយបកស្រាយឬអធិប្បាយ។ សំនួរបើកមានដូចជាៈ *ហេតុអ្វី ឬដោយរបៀបណា?* សំណួរបើកផ្តោតទៅលើរបៀបនៃការគិតរបស់មនុស្ស ឬចំណាប់អារម្មណ៍របស់គេ ដូចនេះ *សំនួរបើកត្រូវមានលក្ខណៈអញ្ជើញ ដោយមិនប្រាប់ឬនាំមុខក្នុងការឆ្លើយ*។

៤. អ្នកសំរបសំរួលលើកឧទាហរណ៍ខ្លះៗ ពីសំណួរបិទនិងសំណួរបើក :

ក. សំណួរបិទ: *នៅក្នុងភូមិនេះ តើមានចំនួនគ្រួសារប៉ុន្មាន?*

ខ. សំណួរបើក: *តើអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារមានការលំបាកយ៉ាងណាដែរក្នុងការអនុវត្តន៍នូវភារកិច្ចនិងតួនាទីរបស់គេ? តើអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារអនុវត្តការងាររបៀបណានៅក្នុងឃុំ-សង្កាត់របស់គេ? តើការងាររបស់គេមានប្រសិទ្ធភាពយ៉ាងណាដែរ?*

៥. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមចាប់ដៃគូពីរនាក់ ដោយសុំឱ្យដៃគូនីមួយៗចាត់តាំងម្នាក់ជាអ្នកសួរសំណួរនិងម្នាក់ទៀតជាអ្នកឆ្លើយ។ សំណួរសំរាប់ពិភាក្សាគឺសំណួរពាក់ពន្ធ័នឹងសកម្មភាពកំសាន្តរបស់ពួកគេ។ <u>ជំហានដំបូង</u> អ្នកសួរអាចប្រើបានតែសំនួរបិទ (ដែលមានចំលើយ បាទ ចាស៎ ទេ ឬចំលើយជាតួរលេខ)។ <u>ជំហានទីពីរ</u> អ្នកសួរអាចសួរសំនួរបើក។ សុំដៃគូនីមួយៗ អនុវត្តជំហានទាំងពីរនេះម្តងទៀត ដោយផ្លាស់ប្តូរតួនាទីអ្នកសួរនិងអ្នកឆ្លើយ។

៦. អ្នកសំរបសំរួលសួរអ្នកចូលរួមថា *តើពួកគេមានអារម្មណ៍យ៉ាងដូចម្តេចចំពោះការធ្វើលំហាត់នេះ?*

*ក. នៅពេលសួរសំនួរបិទ តើមានអ្វីបានកើតឡើងខ្លះ?*

*ខ. នៅពេលសួរសំនួរបើក តើមានអ្វីបានកើតឡើងខ្លះ?*

*គ. តើការសន្ទនាបានផ្លាស់ប្តូរយ៉ាងដូចម្តេចពីជុំទីមួយទៅជុំទីពីរ?*

*ឃ. តើអ្នកអាចសន្និដ្ឋានបានយ៉ាងដូចម្តេចពីលំហាត់នេះ?*

៧. ចែកឯកសារមេរៀនដល់អ្នកចូលរួម។ អ្នកសំរបសំរួលពន្យល់បន្ថែមនិងធ្វើសេចក្តីសង្ខេបមេរៀន និងសួរអ្នកចូលរួមថា តើគេមានយោបល់ ឬចម្ងល់អ្វីទៀតឬទេ? ឆ្លើយតបនឹងសំណួររបស់អ្នកចូលរួម។

(ដកស្រង់ចេញពីប្រព័ន្ធបណ្ណាញរបស់ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន)

**តើអ្នកដឹងទេថា...**

ព្រះរាជាណាចក្រកម្ពុជាបានក្លាយទៅជាកន្លែងមួយដ៏សំខាន់ក្នុងការបញ្ជូន ទទួល និងឆ្លងកាត់សំរាប់ការជួញដូរមនុស្សនៅតំបន់អាស៊ីអាគ្នេយ៍។ មានចំនួនប្រជាពលរដ្ឋកម្ពុជា កើនឡើងច្រើនគួរឱ្យភ្ញាក់ផ្អើល ត្រូវបានគេជួញដូរទៅប្រទេសថៃ ឱ្យធ្វើជាពេស្យាចារ អ្នកសុំទាន កម្មករលើផ្នែក កសិកម្ម កម្មករសំណង់ និងអ្នកបំរើទៅតាមផ្ទះ។

ការជួញដូរមនុស្ស: នៅពេលដែលមនុស្សត្រូវបានគេនាំចេញពីផ្ទះ ពីភូមិកំណើត ហើយបញ្ជូនទៅក្រៅដោយផ្ទុយពីឆន្ទៈរបស់ពួកគេ ត្រូវបានគេយកទៅលក់ ត្រូវទទួលរងគ្រោះនូវការកេងប្រវ័ញ្ច និងស្ថិតនៅក្នុងស្ថានភាពកេញប្រវ័ញ្ច និងឃោរឃៅ។

ការជួញដូរមនុស្សគឺជាអំពើខុសច្បាប់ ហើយអ្នកប្រព្រឹត្តបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់១៥ឆ្នាំ។ បើជនរងគ្រោះជាអនីតិជន (កុមារ) ដែលមានអាយុក្រោម១៥ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ឆ្នាំដល់២០ឆ្នាំ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០០៣ គឺបានហាមឃាត់ការលក់ដូរមនុស្ស។ ច្បាប់ស្តីពីការបង្ក្រាប ការចាប់ពង្រត់និងការជួញដូរ និងកេងប្រប្រវ័ញ្ចមនុស្សឆ្នាំ១៩៩៦ បានកំណត់ពីល័ក្ខខ័ណ្ឌនៃការដាក់ទោសដល់ជនល្មើស។

អ្នករកស៊ីផ្លូវភេទកម្ពុជាប្រមាណជា៤០%-៦០% ត្រូវបានគេបង្ខំឱ្យចូលទៅក្នុងរបរពេស្យាចារ ហើយមួយចំនួន ត្រូវបានគេជួញដូរឱ្យធ្វើជាពេស្យាចារ។

**តើអំពើហិង្សាប្រឆាំងលើស្ត្រីជាអ្វី?**

អំពើហិង្សាប្រឆាំងនឹងស្ត្រីម្នាក់ មានឥទ្ធិពលយ៉ាងធំក្រៃលែងទៅលើស្ត្រី... រួមបញ្ចូលទាំងទង្វើ និងការគំរាមកំហែង ដែលបណ្តាលឱ្យប៉ះពាល់ដល់សតិអារម្មណ៍ ផ្លូវចិត្ត ផ្លូវកាយ ផ្លូវភេទ និងការរងទុក្ខវេទនា ធ្វើឱ្យបាត់បង់នូវសិទ្ធិសេរីភាព និងភាពថ្លៃថ្នូររបស់នារី ។ល។

**ទម្រង់ផ្សេងៗនៃអំពើហិង្សាប្រឆាំងនឹងស្ត្រី**

ទម្រង់នៃអំពើហិង្សាទាំងនេះកើតឡើងនៅក្នុងស្ថានភាពដូចជា អំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស ការចាប់រំលោភ និងការបំពារបំពានផ្លូវភេទ។

អំពើហិង្សាប្រឆាំងនឹងនារីភេទកើតឡើងនៅគ្រប់ទីកន្លែង មិនថានៅផ្ទះ នៅកន្លែងធ្វើការងារ នៅសាលារៀន នៅតាមដងផ្លូវនៅក្នុងទីក្រុង និងនៅក្នុងភូមិទេ ។ល។

ការរំលោភបំពានលើរាងកាយៈ ជាទង្វើដែលបណ្តាលឱ្យមានការឈឺចុកចាប់លើរាងកាយ របួសស្នាម ហើយរហូតដល់ស្លាប់... ការវាយដំទះកំផ្លៀង ទាត់ធាក់ ចាក់នឹងកំបិត បាញ់នឹងកាំភ្លើង ជះទឹកអាស៊ីដ ការបដិសេធនូវសេចក្តីត្រូវការជាមូលដ្ឋានដូចជា ម្ហូបអាហារ ទឹក ទីជម្រក និងការដេកលួន។

ការរំលោភបំពានលើផ្លូវចិត្ត និងសតិអារម្មណ៍ៈ ជាការគំរាមគំហែង ជេរស្តីនិងការរំលោភបំពានដោយពាក្យសម្តីដែលបណ្តាលឱ្យមានភាពតានតឹងខាងផ្លូវចិត្ត បាត់បង់នូវតម្លៃផ្ទាល់ខ្លួន ភាពថ្លៃថ្នូរ និងលទ្ធភាពក្នុងការគ្រប់គ្រងខ្លួនឯង។

ការរំលោភបំពានខាងផ្លូវភេទៈ ជាការចាប់រំលោភ ការប៉ះស្ទាបដោយមិនមានការអនុញ្ញាត ការបំពារបំពានផ្លូវភេទដូចជា ការនិយាយ និងកំប្លែងលេងតាមបែបអាសអាភាស។

ការរំលោភបំពាននៅក្នុងសង្គមៈ ស្ត្រីស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្តី ឬដៃគូ ឬក៏ត្រូវបានគេបង្ខំឱ្យដើរតាមទំនៀមទម្លាប់ដែលផ្ទុយពីចន្ទះរបស់ពួកគេដូចជា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

## អំពើហិង្សាក្នុងគ្រួសារ

អំពើហិង្សាមានកើតឡើងជាញឹកញាប់ ប៉ុន្តែអំពើនេះជាធម្មតាមិនត្រូវបានគេរាយការណ៍ ហើយចំណែកឯជនល្មើសគឺមិនត្រូវបានគេដាក់ទោសទណ្ឌឡើយ។

មិនមែនបុរសទាំងអស់សុទ្ធតែជាអ្នករំលោភបំពាននោះទេ ប៉ុន្តែភាគច្រើននៃអ្នករំលោភគឺជាបុរស ហើយចំណែកឯអ្នករងគ្រោះជាស្ត្រី។ អ្នករំលោភបំពានទាំងនេះបានបញ្ចេញកំហឹងរបស់ខ្លួនទៅលើនរណាម្នាក់ដែលខ្លួនទៅលើគិតថាទន់ខ្សោយជាងខ្លួន អ្នកដែលយល់ថា គេមានសិទ្ធិដើម្បីគ្រប់គ្រង/ត្រួតត្រា ។

កុមារដែលឆ្លងកាត់នូវអំពើហិង្សានៅក្នុងផ្ទះរបស់ពួកគេ គឺរងគ្រោះនូវអារម្មណ៍ផ្លូវចិត្ត ហើយក៏អាចក្លាយទៅជាអ្នករំលោភបំពានដោយខ្លួនឯងផ្ទាល់ក៏មាន។

អំពើហិង្សាក្នុងគ្រួសារមិនមែនជារឿងផ្ទាល់ខ្លួនទេ ឬជាបញ្ហាគ្រួសារទេ។ វាគឺជារឿងបញ្ហាសង្គមដែលត្រូវតែដោះស្រាយតាមរយៈអាជ្ញាធរមានសមត្ថកិច្ច និងសង្គម។

***************

នៅក្នុងការរស់នៅ ក៏ដូចជាការអនុវត្តន៍ការងារ យើងតែងតែត្រូវការការប្រាស្រ័យទាក់ទង នៅក្នុងគ្រួសារ ជាមួយបងប្អូន អ្នករួមការងារ និងអ្នកដ៏ទៃផ្សេងៗទៀត ដែលមានឋានៈ តួនាទី ឬ ស្ថានភាពរស់នៅខុសៗគ្នា។ ជាទូទៅ នៅក្នុងការប្រស្រ័យទាក់ទងនានា យើងច្រើនប្រើប្រាស់ការ និយាយ ការស្តាប់ ការសួរសំនួរ និងការសង្ខេប។

ខាងក្រោមនេះ គឺជាគោលការណ៍ខ្លះៗ សំរាប់ជំនួយក្នុងការស្តាប់ ការសួរសំណួរទៅវិញទៅ មក និងការសង្ខេបអោយមានប្រសិទ្ធភាព។

**ការស្តាប់ :**

- ការស្តាប់ប្រកបដោយប្រសិទ្ធភាព ទាមទារឱ្យអ្នកស្តាប់ផ្តោតការចាប់អារម្មណ៍ដោយពេញលេញ ទៅលើអ្វីដែលមនុស្សម្នាក់ទៀតនិយាយ។
- ត្រូវមានអារម្មណ៍ល្អក្នុងការស្តាប់។
- ចៀសវាងការផ្តោតអារម្មណ៍ទៅលើតែរូបភាពដែលបណ្តាលឱ្យភ្លេចខ្លឹមសារ។

**ការសួរសំណួរ :**

- ក្នុងការសួរសំណួរត្រូវមានទំនាក់ទំនងគ្នាពីមួយទៅមួយ។
- ការសួរសំណួរ អាចប្រើទាំងសំនួរបើក និងសំនួរបិទ។ លក្ខណៈសំនួរបិទច្រើនប្រើពាក្យ អ្នកណា? អ្វី? នៅទីណា? នៅពេលណា? រីឯលក្ខណៈសំនួរបើកច្រើនប្រើពាក្យហេតុអ្វី? ដូចម្តេច? របៀបណា?
- ព្យាយាមប្រើនូវសំណួរបើកឱ្យបានច្រើន ដើម្បីទទួលបានចម្លើយច្រើន។
- ត្រូវប្រើពាក្យសាមញ្ញងាយយល់។
- សំណួរត្រូវមានលក្ខណៈច្បាស់លាស់ ថាតើយើងចង់ដឹងពីអ្វី។

**ការសង្ខេប :**

- ដើម្បីពិនិត្យឱ្យដឹងថា អ្នកបានយល់ដូចទៅនឹងអ្វីដែលបុគ្គលណាម្នាក់បាននិយាយ និងដើម្បីពិនិត្យ ឡើងវិញនូវការសំរេច ឬពិនិត្យឡើងវិញនូវចំណុចសំខាន់ៗ។
- ត្រូវចេះសង្ខេបនូវចំណុចសំខាន់ៗ ផ្អែកទៅលើខ្លឹមសារដែលគេបានលើកឡើង។

# តំរោងមេរៀនទី៤.៣: ការប្រស្រ័យទាក់ទងតែម្ខាងនិងការប្រស្រ័យទាក់ទងទាំងសងខាង

គោលបំណង : នៅចុងបញ្ចប់នៃមេរៀននេះ អ្នកចូលរួមទាំងអស់នឹងអាច:

* អនុវត្តបានពីរបៀបប្រស្រ័យទាក់ទងតែម្ខាង និងទាំងសងខាង។

រយៈពេល : ប្រហែល៤៥នាទី។

វិធីសាស្ត្រ : លំហាត់គូរគំនូរជាលក្ខណៈដៃគូ។

សំភារៈ : ក្រដាស់ផ្ទាំងធំ ក្រដាស់ពណ៌ ហ្វឺត។

ឯកសារមេរៀន : គោលការណ៍ណែនាំសំរាប់លំហាត់ទី ៤.៣.ក និងទី៤.៣.ខ។
រូបភាពទី១ និងរូបភាពទី២។

របៀបសំរបសំរួល :

១. អ្នកសំរបសំរួលសួរអ្នកចូលរួមថា *តើពួកគេធ្លាប់បានឮពី "ការប្រស្រ័យទាក់ទងតែម្ខាងនិងទាំងសងខាង" ដែរឬទេ? តើវាមានន័យដូចម្តេច?* សរសេរចំលើយ ដាក់លើក្រដាសផ្ទាំងធំ។

២. អ្នកសំរបសំរួលចាត់ឱ្យអ្នកចូលរួមចាប់ដៃគូ ដោយឱ្យដៃគូនីមួយៗចាត់តាំងម្នាក់ជាឈ្មោះ **ក** និងម្នាក់ទៀតឈ្មោះ **ខ** ។

៣. អ្នកសំរបសំរួលឱ្យឈ្មោះ **ក** ទាំងអស់មកជួបជុំគ្នា ហើយឱ្យរូបភាពទី១ និងគោលការណ៍ណែនាំក្នុងការគូររូបភាពទី១ដល់ពួកគេ និងឱ្យពួកគេអានគោលការណ៍។

៤. អ្នកសំរបសំរួលឱ្យ **ក** និង **ខ** អង្គុយទល់ខ្នងគ្នា ហើយដោយ **ក** និយាយណែនាំនិងពន្យល់ទៅ **ខ** ដើម្បីគូររូបនេះ។ ឈ្មោះ **ខ** មិនអាចមើលរូបភាព ឬសួរសំនួរសួរអ្វីបញ្ជាក់បានទេ។ រីឯឈ្មោះ **ក** មិនត្រូវប្រាប់ការណែនាំនិងពន្យល់របស់ខ្លួនជាលើកទីពីរទេ។ បន្ទាប់ពីដៃគូទាំងអស់គូររូបរួចរាល់ ហើយអ្នកសំរបសំរួលសុំអោយ **ខ** បង្ហាញគំនូរដល់ដៃគូរបស់ខ្លួន និងអ្នកចូលរួមទាំងអស់។

៥. អ្នកសំរបសំរួលឱ្យឈ្មោះ **ខ** ទាំងអស់មកជួបជុំគ្នា ហើយឱ្យរូបទី២ និងគោលការណ៍ណែនាំក្នុងការគូររូបភាពទី២ ដល់ពួកគេ និងឱ្យពួកគេអានគោលការណ៍នេះ។ លើកនេះពួកគេអាចបកស្រាយសួរសំនួរ និងសួរបញ្ជាក់បាន តែឈ្មោះ **ក** មិនអាចមើលរូបភាពបានទេ។

៦. អ្នកសំរបសំរួលឱ្យ **ក** និង **ខ** អង្គុយទល់ខ្នងគ្នា ហើយដោយ **ខ** និយាយណែនាំនិងពន្យល់ទៅ **ក** ដើម្បីគូររូបនេះ។ បន្ទាប់ពីដៃគូទាំងអស់គូររូបរួចរាល់ហើយ អ្នកសំរបសំរួលសុំឱ្យ **ក** បង្ហាញគំនូរដល់អ្នកចូលរួមទាំងអស់។

៧. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមធ្វើការបកស្រាយពីភាពផ្សេងគ្នានៃការប្រស្រ័យទាក់ទងទាំងពីរនេះ និងសួរទៅឈ្មោះ ក និងឈ្មោះ ខ ថា *មានការលំបាកទេ ក្នុងការគូររូបនេះ? រូបភាពមួយណាងាយស្រួលជាង? ហេតុអ្វី?*

៨. ពន្យល់ពីស្ថានភាពជាក់ស្តែង ដែលអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារត្រូវអនុវត្តនូវការប្រស្រ័យទាក់ទងទាំងសងខាងនៅក្នុងការងាររបស់ពួកគេ។

៨. អ្នកសំរបសំរួលធ្វើសេចក្តីសង្ខេបពីការប្រស្រ័យទាក់ទងតែម្ខាងនិងការប្រស្រ័យទាក់ទងសងខាង។ និងសួរអ្នកចូលរួមថា តើគេមានយោបល់ ឬចម្ងល់អ្វីទៀតឬទេ? ឆ្លើយតបនឹងសំណួររបស់អ្នកចូលរួម។

☺☺☺

## គោលការណ៍ណែនាំ ៤.៣.ក សំរាប់គូររូបទី១

- ដៃគូមានគ្នាពីរនាក់ ម្នាក់ឈ្មោះ ក និងម្នាក់ទៀតឈ្មោះ ខ ។
- ឈ្មោះ ក និងឈ្មោះ ខ អង្គុយទល់ខ្នងគ្នា។
- អ្នកសំរបសំរួលឱ្យរូបភាពទី១ ទៅឈ្មោះ ក នៅក្នុងដៃគូនីមួយៗ។
- ឈ្មោះក រៀបរាប់ពីលក្ខណៈរូបភាពឱ្យឈ្មោះ ខ ដើម្បីគូរ។
- ឈ្មោះ ខ មិនអាចសុំឱ្យឈ្មោះ ក រៀបរាប់ពីលក្ខណៈនៃរូបភាពជាលើកទីពីរ ឬ សួរទៅឈ្មោះ ក ឬ សួរបញ្ជាក់ថាខុសឬត្រូវឡើយ។ ឈ្មោះ ក មិននិយាយអ្វីទាំងអស់ពេលដែលកំពុងអនុវត្តការគូររូបនេះ។
- អ្នកទាំងពីរមិនអាចមើលរូបគ្នាទៅវិញទៅមកបានទេ ប្រសិនបើគ្មានការអនុញ្ញាតិពីអ្នកសំរបសំរួលទេ។
- បន្ទាប់ពីគូររូបរួចហើយឈ្មោះ ខ ត្រូវបង្ហាញរូបរបស់ខ្លួនទៅអ្នកចូលរួមទាំងអស់។
- អ្នកសំរបសំរួលសួរឈ្មោះ ខ ពីការលំបាកនិងភាពងាយស្រួលក្នុងការគូររូបនេះ ។

# <u>រូបភាពទី១</u>



## គោលការណ៍ណែនាំ ៤.៣.ខ សំរាប់គូររូបទី២

- អនុវត្តជាមួយដៃគូដដែល។
- ឈ្មោះ ក និងឈ្មោះ ខ អង្គុយទល់ខ្នងគ្នាដដែល។
- អ្នកសំរបសំរួលឱ្យរូបភាពទី២ ទៅឈ្មោះ ខ នៅក្នុងដៃគូនីមួយៗ។
- ឈ្មោះ ខ រៀបរាប់ពីលក្ខណៈរូបភាពនេះឱ្យឈ្មោះ ក ជាអ្នកគូរម្តង។ អ្នកទាំងពីរអាចសួរឆ្លើយឆ្លងគ្នាទៅវិញទៅមកបាន។
- តែអ្នកទាំងពីរមិនអាចមើលរូបគ្នាទៅវិញទៅមកបានទេ ប្រសិនបើគ្មានការអនុញ្ញាតិពីអ្នកសំរបសំរួលទេ។
- បន្ទាប់ពីគូររូបរួចរាល់ហើយ ឈ្មោះ ក និងឈ្មោះ ខ ត្រូវបង្ហាញរូបរបស់ពួកគេទៅអ្នកចូលរួមទាំងអស់ ។
- អ្នកសំរបសំរួលសួរ ឈ្មោះ ក ពីការលំបាកនិងភាពងាយស្រួលក្នុងការគូររូបនេះ ។

☺☺☺

## រូបគំនូរទី២



## គំរោងមេរៀនទី ៤.៤: ប្រការដែលគួរធ្វើនិងមិនគួរធ្វើក្នុងការប្រស្រ័យទាក់ទង

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ អ្នកចូលរួមទាំងអស់នឹងអាចៈ

* កំណត់បាននូវប្រការដែលគួរធ្វើ និងមិនគួរធ្វើក្នុងការប្រស្រ័យទាក់ទង។

**រយៈពេល** : ប្រហែល៤៥នាទី។

**វិធីសាស្ត្រ** : សំនួរបំផុសគំនិត និងការពិភាក្សាក្រុមធំ។

**សំភារៈ** : ក្រដាស់ផ្ទាំងធំ ហ្វឺត ស្កុត និង កន្ត្រៃ។

**ឯកសារមេរៀន** : ឯកសារមេរៀនទី៤.៤ ប្រការដែលគួរនិងមិនគួរធ្វើក្នុងការប្រស្រ័យទាក់ទង

**របៀបសំរបសំរួល** :

១. អ្នកសំរបសំរួលសួរទៅអ្នកចូលរួមថា *តើពួកគេធ្លាប់មានបទពិសោធន៍ក្នុងការប្រស្រ័យទាក់ទងដែរឬទេ?* សរសេរចំលើយនៅលើក្រដាសផ្ទាំងធំ។

២. អ្នកសំរបសំរួលសួរអ្នកចូលរួមថា *តើប្រការអ្វីខ្លះដែលគួរជៀសវាងក្នុងការប្រស្រ័យទាក់ទង?* និងសរសេរយោបល់អ្នកចូលរួមលើក្រដាសផ្ទាំងធំ។

៣. អ្នកសំរបសំរួលបង្ហាញនិងពន្យល់បកស្រាយទៅលើខ្លឹមសារនៃមេរៀន។

៤. ចែកឯកសារមេរៀនទី៤.៤ ស្តីពីប្រការការប្រស្រ័យទាក់ទងដោយកាយវិការនិងពាក្យសំដី។ សុំឱ្យអ្នកចូលរួមសួរសំនួរប្រសិនបើពួកគេមានចម្ងល់។ ឆ្លើយនឹងសំនួរទាំងនោះ។

៥. អ្នកសំរបសំរួលធ្វើសេចក្តីសង្ខេប (សរុបដោយសង្ខេបនូវប្រធានបទទាក់ទងនឹងជំនាញប្រស្រ័យទាក់ទង)។

៦. អ្នកសំរបសំរួលគួរប្រាប់អ្នកចូលរួមថា *ជំនាញនៃការសួរសំនួរ ការស្តាប់ ការធ្វើសេចក្តីសង្ខេប ការប្រស្រ័យទាក់ទងតែម្នាក់និងទាំងសងខាងមានសារប្រយោជន៍ផ្សេងៗគ្នាជាច្រើន* ។ អ្នកសំរបសំរួលគួររលើកសារឡើងវិញខ្លះនូវមេរៀននានាក្នុងជំនាញការប្រស្រ័យទាក់ទង មុននឹងការចូលដល់មេរៀនជំនាញថ្មីក្រោយមួយទៀត។

☺☺☺

**ការប្រស្រ័យទាក់ទងដោយកាយវិការ:**

- នៅពេលដែលអ្នកនិយាយ ត្រូវរក្សាក្រសែភ្នែកជាមួយមនុស្សគ្រប់រូបនៅក្នុងបន្ទប់ និងត្រូវនិយាយទៅរកមនុស្សគ្រប់គ្នា គឺមិនមែននិយាយរកតែមនុស្សដែលអ្នកស្គាល់ ឬមិត្តរបស់អ្នកនោះទេ។
- ឆ្លើយតបទៅនឹងអ្វីដែលអ្នកដទៃនិយាយ ដោយងក់ក្បាលញញឹម ឬសកម្មភាពផ្សេងទៀតដែលបង្ហាញថាអ្នកកំពុងស្តាប់។
- ប្រសិនបើអ្នកកំពុងធ្វើបទបង្ហាញ ចូរឈរឱ្យចំពីមុខអ្នកចូលរួម។ ត្រូវមានជំនឿជឿជាក់លើខ្លួនឯងនិងនិយាយដោយច្បាស់ៗ។

**ការប្រស្រ័យទាក់ទងដោយប្រើពាក្យសំដី:**

- សួរសំនួរដែលជំរុញអោយមានចំលើយតបដែលផ្តល់នូវហេតុផល ដូចជា "តើអ្នកគិតយ៉ាងណាអំពី .........? ហេតុអ្វី .......? ដូចម្តេច ......? ចុះប្រសិនបើ ............? ប្រសិនបើអ្នកចូលរួមឆ្លើយតបដោយ **បាទ ចាស់** និង**ទេ** ត្រូវសួរពីមូលហេតុនៃចំលើយរបស់ពួកគេ។
- សួរអ្នកដទៃទៀត ថាតើពួកគេឯកភាពជាមួយនឹងយោបល់របស់អ្នកណាម្នាក់ដែលបានលើកឡើងដែរឬទេ?
- ត្រូវនិយាយដោយយឺតៗ និង ច្បាស់ៗ ។
- និយាយឡើងវិញដោយរៀបប្រយោគឡើងវិញនូវអ្វីដែលអ្នកណាម្នាក់បាននិយាយ ។
- ធ្វើសេចក្តីសង្ខេបការពិភាក្សា។
- ចៀសវាងការដើរបណ្តើរ និយាយបណ្តើរ។
- ចៀសវាងការនិយាយចេញពីកន្លែងដែលអ្នកស្តាប់មើលមិនឃើញអ្នក។

## គំរោងមេរៀនទី ៥.១: សេចក្តីផ្តើមស្តីពីការប្រមូលពត៌មាន

គោលបំណង : នៅចុងបញ្ចប់នៃមេរៀននេះ អ្នកចូលរួមទាំងអស់នឹងអាចៈ

* ទទួលបានពីគោលគំនិតជាមូលដ្ឋាននៃការប្រមូលពត៌មាន។
* កំណត់បានពីវិធីសាស្ត្រនានាដែលប្រើសំរាប់ប្រមូលពត៌មាន។

រយៈពេល : ប្រហែល៤៥នាទី

វិធីសាស្ត្រ : អធិប្បាយនិងសំណួរបំផុសគំនិត។

សំភារៈ : ក្រដាស់ផ្ទាំងធំ និងហ្វឺត។ល។

ឯកសារមេរៀន : មេរៀននេះត្រូវពឹងផ្អែកទៅលើបទពិសោធន៍របស់អ្នកចូលរួម។

របៀបសំរបសំរួល :

១. អ្នកសំរបសំរួលសួរអ្នកចូលរួមថា *តើពួកគាត់ជារៀងរាល់ថ្ងៃតែងតែប្រមូលពត៌មានមកពីណា?* សរសេរចំលើយអ្នកចូលរួមដាក់ក្រដាសផ្ទាំងធំ។

២. អ្នកសំរបសំរួលសួរអ្នកចូលរួមថា *តើយកពត៌មានទាំងនោះទៅប្រើក្នុងគោលបំណងអ្វីខ្លះ?* សរសេរចំលើយអ្នកចូលរួមដាក់ក្រដាសផ្ទាំងធំ។

៣. អ្នកសំរបសំរួលសួរអ្នកចូលរួមទៀតថា *តើពួកគេដឹងពីរបៀបផ្សេងៗគ្នា នៃការប្រមូលពត៌មានដែរឬទេ?* សរសេរចំលើយអ្នកចូលរួមដាក់ក្រដាសផ្ទាំងធំ។

៤. អ្នកសំរបសំរួលពន្យល់ថា ក្រុមប្រឹក្សាឃុំ-សង្កាត់ធ្វើសេចក្តីសំរេចដើម្បីដោះស្រាយ ឬដើម្បីធ្វើអ្វីមួយ គឺត្រូវពឹងផ្អែកលើពត៌មានដែល ពួកគេទទួលបានពីប្រភពផ្សេងៗ។ សុំឱ្យអ្នកចូលរួមគិតអំពីប្រភពពត៌មានផ្សេងៗ ដែលមាននៅក្នុងឃុំ- សង្កាត់ ដូចជា ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ។ល។ នៅក្នុងឃុំ-សង្កាត់របស់គេ។ សរសេរចំលើយអ្នកចូលរួមដាក់ក្រដាសផ្ទាំងធំ។

៥. អ្នកសំរបសំរួលពន្យល់ថា អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារត្រូវស្វែងយល់និងពិនិត្យលើពត៌មាន និងប្រភពផ្សេងៗ នៃពត៌មានក្នុងឃុំ-សង្កាត់ (ផ្នែកស្ថានភាពសង្គម ផ្នែកសេដ្ឋកិច្ច និងនយោបាយ ។ល។) ហើយពួកគេត្រូវធ្វើសេចក្តីសង្ខេបនូវពត៌មានទាំងនោះ។ ពួកគេអាចនឹងយកពត៌មានទាំងនោះទៅបង្ហាញដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ឬក្រុមនានាដែលជាអ្នកធ្វើសេចក្តីសំរេចនៅថ្នាក់មូលដ្ឋាន ដើម្បីឱ្យពួកគេបានដឹងពីស្ថានភាពរបស់ស្ត្រី និងកុមារ ឬដើម្បីបញ្ចុះបញ្ចូលពួកគេធ្វើ

សេចក្តីសំរេចអ្វីមួយដែលទាក់ទងទៅនឹងផលប្រយោជន៍របស់ស្ត្រីនិងកុមារនៅក្នុងឃុំ-សង្កាត់នោះ។

៦. អ្នកសំរបសំរួលសុំអោយអ្នកចូលរួម សួរសំនួរ និងផ្តល់យោបល់។ ឆ្លើយនឹងសំណួរ។

៧. អ្នកសំរបសំរួលធ្វើសេចក្តីសង្ខេបមេរៀន ។

**កំណត់សំគាល់សំរាប់អ្នកសំរបសំរួល :**

គោលបំណងនៃមេរៀននេះ ដើម្បីឱ្យអ្នកចូលរួមបានយល់ដឹងពីសារៈសំខាន់នៃការពិនិត្យមើល និងយល់ដឹងពីប្រភពពត៌មានដែលពាក់ពន្ធ័នឹងការងាររបស់គេ។ ជារឿយៗ នៅក្នុងកិច្ចប្រជុំអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារមានតួនាទីជាអ្នកតំណាងស្ត្រីនិងកុមារនៅក្នុងឃុំ-សង្កាត់របស់ពួកគេ ដូច្នេះជាចាំបាច់គេត្រូវដឹងពីប្រភពពត៌មានរបស់ស្ត្រីនិងកុមារនៅក្នុងឃុំ-សង្កាត់។ វិធីនៃការប្រមូលពត៌មានរបស់ពួកគេ គឺអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារត្រូវប្រមូលពត៌មានតាមរយៈការពិភាក្សាក្រុមជាមួយស្ត្រី និងក្រុមគោលដៅផ្សេងៗ និងវិធីមួយទៀតតាមរយៈការពិនិត្យមើលពត៌មានដែលមានស្រាប់ ដូចជាពត៌មាន ស្ថិតិស្ថានភាពឃុំ-សង្កាត់ ឬផែនទីឃុំ-សង្កាត់ ។ល។

ឈឈឈ ☺☺☺ ឈឈឈ

## គំរោងមេរៀនទី ៥.២: ការយល់ដឹងពីប្រភពទិន្នន័យផ្សេង

---

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ អ្នកចូលរួមទាំងអស់នឹងអាចៈ

* យល់ពីរបៀបអានពត៌មាននិងទិន្នន័យដែលមាននៅក្នុងឃុំ-សង្កាត់ និងខេត្ត-ក្រុង ដូចជា របាយការណ៍ឃុំ-សង្កាត់ និងស្ថានភាពឃុំ-សង្កាត់និងយល់ដឹងពីពត៌មាន និងទិន្នន័យទាំងអស់នេះ។

**រយៈពេល** : ប្រហែល១២០នាទី។

**វិធីសាស្ត្រ** : ការអាន និងសង្ខេប។

**សំភារៈ** : ក្រដាសផ្ទាំងធំ និង ហ្វឺត។ល។

**ឯកសារមេរៀន** : ឯកសារមេរៀនទី៥.២ក ស្តីពីករណីសិក្សាស្តីពីការអប់រំនៅឃុំ ស្រែលើ។
ឯកសារមេរៀនទី៥.២ខ ស្តីពីឯកសារពត៌មានឃុំ-សង្កាត់ និងសំណួរ។

**របៀបសំរបសំរួល :**

**ក. ករណីសិក្សាស្តីពីការយល់ដឹងពីទិន្នន័យ**

១. អ្នកសំរបសំរួលពន្យល់អ្នកចូលរួមថា មេរៀននេះនឹងផ្តល់ឱកាសឱ្យអ្នកចូលរួមបានអាននិងវិភាគលើពត៌មានដែលពាក់ព័ន្ធនឹងការងាររបស់ពួកគេ។

២. អ្នកសំរបសំរួលចែកអ្នកចូលរួមជាក្រុមតូច (ពីរឬបីក្រុម ទៅតាមចំនួនអ្នកចូលរួម) និងចែកឯកសារមេរៀនករណីសិក្សាស្តីពីការអប់រំនៅឃុំ ស្រែលើ ជូនពួកគាត់។

៣. អ្នកសំរបសំរួលសុំឱ្យក្រុមនីមួយៗ អានករណីសិក្សានេះនិងសួរនូវអ្វីដែលពួកគេមិនយល់។ សុំឱ្យក្រុមនីមួយៗ ឆ្លើយនឹងសំនួរក្នុងករណីសិក្សានេះ ដោយសរសេរចម្លើយដាក់លើក្រដាស់ផ្ទាំងធំ។

៤. អ្នកសំរបសំរួលសុំឱ្យតំណាងក្រុមនីមួយៗបង្ហាញលទ្ធផលរបស់គេដល់ក្រុមធំ។ <u>សុំឱ្យក្រុមនីមួយៗបង្ហាញពីបទពិសោធន៍នៃការអាននិងការយល់បានលើករណីសិក្សានេះ</u>។

៥. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមគិតនិងយកបទពិសោធន៍ក្នុងករណីសិក្សានេះទៅប្រើប្រាស់ក្នុងការងាររបស់ពួកគេ។

**ក. ករណីសិក្សាស្តីពីការយល់ដឹងពីទិន្នន័យ**

១. ចំពោះករណីសិក្សាពីស្ថានភាពឃុំ-សង្កាត់ត្រូវអនុវត្តដូចជំហានទីមួយៗ ក្នុងករណីសិក្សានៃការអប់រំខាងលើនេះដែរ ដោយឱ្យក្រុមនីមួយៗពិនិត្យមើលឯកសារស្ថានភាពឃុំដើម្បីឆ្លើយនឹងសំនួរ។

២. អ្នកសំរបសំរួលសង្ខេបដោយផ្អែកទៅតាមគោលបំណងនៃប្រធានបទ។

**ចំណាំសំរាប់អ្នកសំរបសំរួល :**

គោលបំណងនៃលំហាត់នេះ មិនមែនដើម្បីវិភាគទិន្នន័យឱ្យបានល់អិតទេ គឺដើម្បីបង្កើនជំនាញក្នុងការអានពត៌មាននិងទិន្នន័យផ្សេងៗ និងសង្ខេបពត៌មានទិន្នន័យទាំងនេះ។

អ្នកសំរបសំរួលគួរបញ្ជាក់ថា ដោយយោងតាមការសិក្សាលើករណីសិក្សាទាំងពីរនេះ ក្នុងនាមពួកគេជាអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ គួរតែធ្វើការផ្ទះបញ្ជាំងទៅនឹងស្ថានភាពជាក់ស្តែងក្នុងការងាររបស់ពួកគាត់។

ꕥꕥꕥ ☺☺☺ ꕥꕥ

ឃុំស្រែលើ ស្ថិតប្រមាណ១៥គីឡូម៉ែត្រពីទីរួមស្រុកព្រៃកពោធិ៍ ខេត្តកំពង់ចាមដែលមានប្រជាពលរដ្ឋរស់នៅក្នុងឃុំនោះចំនួន ៨.១៥៩នាក់ មានស្រីចំនួន ៥.៣៤៧នាក់។ ប្រជាពលរដ្ឋនៅក្នុងឃុំស្ទើរតែទាំងអស់ប្រកបមុខរបរកសិកម្មដំណាំស្រូវ ដែលពឹងផ្អែកលើទឹកភ្លៀង។ សំណាងល្អឃុំនេះស្ថិតនៅជាប់ដីងស្ទឹងដែលមានត្រីជ័ច្រើន។ ប្រជាពលរដ្ឋរស់នៅទីនោះភាគច្រើន ជឿលើទំនៀមទម្លាប់បូរាណ និងជីដូនជីតារបស់ពួកគេ។

រៀងរាល់ឆ្នាំ កុមារីនិងកុមារាបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សាមានចំនួនស្ទើរតែស្មើគ្នា។ ប៉ុន្តែនៅចុងបញ្ចប់នៃថ្នាក់ទីបី កុមារីជាច្រើននាក់បានបោះបង់ចោលការសិក្សា ហើយនៅចុងបញ្ចប់នៃថ្នាក់ទីប្រាំមួយ មានចំនួនសិស្សស្រីតែបន្តិចបន្តួចប៉ុណ្ណោះដែលប្រឡងជាប់កំរិតបឋមសិក្សា ដើម្បីឈានទៅបន្តការសិក្សានៅកំរិតមធ្យមសិក្សា។

ក្រៅពីអត្រានៃការបោះបង់ការសិក្សារបស់សិស្សស្រី គេក៏អាចកត់សំគាល់ឃើញថា សិស្សស្រីចំណាយពេលវេលារៀនសូត្រនៅសាលាតិចជាងសិស្សប្រុស។ ដោយឡែកនៅក្នុងរដូវដកស្ទូង និងប្រមូលផលដំណាំវិញ សិស្សស្រីតែងតែអវត្តមានពីសាលារៀនជានិច្ច។ ម្យ៉ាងទៀត គេសង្កេតឃើញថា ការមករៀនរបស់សិស្សស្រីតែងតែយឺត និងចេញពីសាលារៀនមុនសិស្សប្រុស។

ជារួមអត្រាអក្ខរជនមាន៧៥ភាគរយ ក្នុងចំណោមប្រជាពលរដ្ឋទាំងអស់ ហើយ៥៨ភាគរយជាស្ត្រី។ ផ្អែកតាមពត៌មានថ្មីៗ ពីក្រសួងអប់រំ យុវជន និងកីឡាបង្ហាញឱ្យឃើញភាពខុសប្លែកគ្នារវាងក្មេងស្រី និងក្មេងប្រុស។ ក្មេងប្រុសចាប់ផ្តើមចូលរៀនត្រូវតាមអាយុ មានដល់ទៅ ៩៤ភាគរយ តែក្មេងស្រីមានត្រឹមតែ៨៤ភាគរយប៉ុណ្ណោះ។ បន្ថែមលើនោះទៀត មានក្មេងស្រីតិចជាង៥០ភាគរយបានបញ្ចប់បឋមសិក្សាប្រៀបធៀបទៅក្មេងប្រុសដែលមាន៥៥ភាគរយ។ នៅក្នុងកំរិតមធ្យមសិក្សា ក្មេងស្រីមានត្រឹមតែ១៤ ភាគរយ រីឯក្មេងប្រុសមាន២០ភាគរយ។ នៅកំរិតបឋមសិក្សា កុមារីនិងកុមារមានចំនួនប្រហាក់ប្រហែលគ្នា តែក្នុងកំរិតមធ្យមសិក្សាកំរិតមួយ មានក្មេងស្រីតែ៦នាក់ប៉ុណ្ណោះក្នុងចំណោមក្មេងប្រុស១០នាក់។ នៅក្នុងកំរិតមធ្យមសិក្សាពីរនិងកំរិតឧត្តមសិក្សា មានស្ត្រីតិចជាង៥នាក់ក្នុងចំណោមបុរស១០នាក់។

ថ្ងៃមួយក្មេងស្រីម្នាក់ កំពុងបញ្ចុកបាយដល់ប្អូនទាំង២នាក់របស់នាង។ ពេលនោះ មានបុរសម្នាក់បានចូលមកដល់ ហើយសាកសួរនាងពីជីវិតរស់នៅនិងការរៀនសូត្ររបស់នាង។ នាងរៀបរាប់

ប្រាប់បុរសនោះថា "ខ្ញុំឈ្មោះ ចាន់ មុំ។ ខ្ញុំមានបងប្អូន ៨នាក់។ ឪពុកម្តាយខ្ញុំជាអ្នកស្រែចំការ។ ខ្ញុំគឺជាកូនទី២ ហើយខ្ញុំពុំបានទៅសាលារៀនទេ។ បងប្រុសនិងប្អូនប្រុសខ្ញុំបានទៅរៀន។ ប្អូនស្រីខ្ញុំម្នាក់ទៀតក៏បានទៅរៀនដែរ តែនាងរៀនមិនសូវចេះទេ។ ប្អូនស្រីខ្ញុំមិនអាចទៅរៀនរាល់ថ្ងៃបានទេ។ចំពោះខ្ញុំផ្ទាល់ ឪពុកម្តាយខ្ញុំប្រាប់ថា គ្មានប្រយោជន៍សំរាប់ខ្ញុំទៅរៀនទេ។ ម្យ៉ាងទៀត សូម្បីតែរៀនអក្ខរកម្មនៅក្នុងភូមិ ក៏ខ្ញុំពុំមានពេលបានទៅរៀនផង។ ឪពុកម្តាយខ្ញុំឱ្យខ្ញុំនៅផ្ទះ មើលប្អូន ឱ្យចំណីជ្រូក សំអាតចង្ក្រានបានថ្នាំង បោកគក់ សម្លៀកបំពាក់ ដូចនេះទើបខ្ញុំពុំមានពេលបានទៅរៀន។ ខ្ញុំមានអារម្មណ៍ថាខ្ញុំធ្វើការងារផ្ទះកាន់តែច្រើនឡើងៗ។ ចាស់ៗនៅក្បែរផ្ទះខ្ញុំ តែងតែសរសេរខ្ញុំថា ជាកូនល្អ ចេះធ្វើការងារផ្ទះសម្បែង ចេះស្តាប់បង្គាប់ ឪពុកម្តាយ។"

**សំណួរពិភាក្សា :**

១. ហេតុអ្វីបានជា ក្មេងស្រី ចាន់ មុំ មិនបានទៅរៀន?
២. តើអ្នកបានដឹងអ្វីខ្លះពីពត៌មានពាក់ពន្ធ័នឹងការអប់រំរបស់ក្មេងប្រុសនិងក្មេងស្រី?
៣. តើឃុំ-សង្កាត់របស់អ្នកមានស្ថានភាពប្រហាក់ប្រហែលគ្នាឬខុសគ្នាពីឃុំនេះ? តើខុសគ្នាអ្វីខ្លះ?
៤. តើការចូលរៀនរបស់ក្មេងស្រីនិងស្ត្រីទាប បណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានអ្វីខ្លះ?
៥. ក្នុងនាមអ្នកជាអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ឬជនបង្គោលយេនឌ័រ តើអ្នកត្រូវធ្វើអ្វីខ្លះដើម្បីបង្កើនការចូលរៀនរបស់ក្មេងស្រីនិងស្ត្រីឱ្យបានច្រើន?

## ឯកសារមេរៀនទី៥.២.៩ ៖ សំនួរពាក់ព័ន្ធនឹងឯកសារស្ថានភាពឃុំ_សង្កាត់

ចូរអានឯកសារស្ថានភាពឃុំ_សង្កាត់ ។ ឆ្លើយទៅនឹងសំនួរដូចតទៅ ដោយផ្អែកទៅលើការអានរបាយការណ៍ស្ថានភាពឃុំ_សង្កាត់របស់អ្នក។

១. តើភូមិណាមួយដែលមានចំនួនកុមារទៅសាលារៀនតិចជាងគេ? តើមានមូលហេតុ ខ្លះដែលកុមារនៅក្នុងភូមិទាំងនោះមិនទៅសាលារៀន?

២. តើភូមិណាមួយដែលមានចំនួនកុមារទៅសាលារៀនតិចជាងគេ? តើមានមូលហេតុអ្វីខ្លះដែលបណ្តាលអោយកុមារីមិនទៅសាលារៀន?

៣. តើគេអាចធ្វើសកម្មភាពអ្វីខ្លះដើម្បីលើកទឹកចិត្ត និងជំរុញអោយកុមារីទៅចូលរៀនច្រើន?

៤. តើភូមិណាមួយដែលមានអត្រាអនក្ខរភាពរបស់ស្ត្រីខ្ពស់ជាងគេ? តើអ្នកគិតថាមានដំណោះស្រាយអ្វី សំរាប់កាត់បន្ថយអត្រាអនក្ខរភាពរបស់ស្ត្រីនៅក្នុងភូមិនោះ?

៥. តើភូមិណាខ្លះ ដែលមានគ្រួសារប្រើប្រាស់បង្គន់អនាម័យ តិចជាង ១០គ្រួសារ?

៦. ប្រសិនបើពួកគេមិនមានបង្គន់អនាម័យ តើអាចបណ្តាលអោយមានបញ្ហាអ្វីខ្លះដល់ស្ត្រី?

៧. តើភូមិណាខ្លះដែលមានទឹកស្អាតសំរាប់ប្រើប្រាស់តិចជាងគេ? តើអាចបណ្តាលឱ្យមានបញ្ហាអ្វីខ្លះដល់ស្ត្រី?

៨. តើមានភូមិប៉ុន្មានដែលប្រើឆ្មបបុរាណច្រើនជាងគេ? ភូមិណាខ្លះដែលប្រើឆ្មបបុរាណតិចជាងគេ? តើការប្រើឆ្មបបុរាណ និង សុខភាពរបស់ស្ត្រីមានទំនាក់ទំនងគ្នាដូចម្តេចខ្លះ?

ចូរសរសេរពត៌មានសំខាន់ផ្សេងៗទៀត ដែលអ្នកចាប់អារម្មណ៍តាមរយៈការអានរបាយការណ៍ស្ថានភាពឃុំ_សង្កាត់។

## តារាងទិន្នន័យតាមភូមិ (ស្រង់ចេញពី ឯកសារពត៌មាន ស្តីពីស្ថានភាពឃុំបន្ទាយមាសខាងកើត ក្នុងឆ្នាំ២០០៣)

ខេត្ត/ក្រុង: កំពត

ស្រុក/ខណ្ឌ: បន្ទាយមាស

ឃុំ/សង្កាត់: បន្ទាយមាសខាងកើត (៧០២០១)

ឆ្នាំ: ២០០២

| ល.រ | ទិន្នន័យភូមិ | ពេជ្ជនា | ក្រសាំងក្រោម | ក្រសាំងលើ | ត្រពាំងពោធ | ព្រៃបន្ទាំ | ស្រែថ្មុក | ពោធិ៍ | ធ្នង់ |
|---|---|---|---|---|---|---|---|---|---|
| 1 | ចំនួនគ្រួសារសរុបក្នុងភូមិយកតាមសៀវភៅគ្រួសារ) | 255 | 235 | 235 | 349 | 166 | 208 | 159 | 186 |
| 2 | ចំនួនមនុស្សស្រីសរុប | 693 | 521 | 578 | 1161 | 467 | 419 | 340 | 394 |
| 3 | ចំនួនមនុស្សប្រុសសរុប | 603 | 388 | 561 | 1195 | 312 | 456 | 340 | 381 |
| 4 | ចំនួនក្មេងស្រី អាយុពី ០ ដល់ ៥ ឆ្នាំ ក្រោម៦ឆ្នាំ) | 85 | 69 | 54 | 123 | 28 | 36 | 41 | 52 |
| 5 | ចំនួនក្មេងប្រុស អាយុពី ០ ដល់ ៥ ឆ្នាំ ក្រោម៦ឆ្នាំ) | 80 | 65 | 98 | 157 | 23 | 54 | 46 | 40 |
| 6 | ចំនួនក្មេងស្រី អាយុពី ៦ ដល់ ១៤ ឆ្នាំ ក្រោម១៥ឆ្នាំ) | 136 | 98 | 139 | 246 | 179 | 55 | 72 | 60 |
| 7 | ចំនួនក្មេងប្រុស អាយុពី ៦ ដល់ ១៤ ឆ្នាំ ក្រោម១៥ឆ្នាំ) | 157 | 130 | 101 | 246 | 105 | 90 | 77 | 78 |
| 8 | ចំនួនក្មេងស្រីអាយុពី ៦ ដល់ ១៤ ឆ្នាំដែលបានចូលរៀន | 112 | 75 | 106 | 90 | 179 | 54 | 72 | 29 |
| 9 | ចំនួនក្មេងប្រុសអាយុពី ៦ ដល់ ១៤ ឆ្នាំដែលបានចូលរៀន | 146 | 119 | 90 | 76 | 105 | 64 | 75 | 73 |
| 10 | ចំនួនក្មេងស្រី អាយុពី ១៥ ដល់ ១៧ ឆ្នាំ ក្រោម១៨ឆ្នាំ) | 43 | 42 | 24 | 166 | 15 | 30 | 25 | 30 |
| 11 | ចំនួនក្មេងប្រុស អាយុពី ១៥ ដល់ ១៧ ឆ្នាំ ក្រោម១៨ឆ្នាំ) | 49 | 35 | 21 | 166 | 7 | 43 | 40 | 46 |
| 12 | ចំនួនស្ត្រីអាយុពី១៨ឆ្នាំដល់ ៦៤ឆ្នាំ | 392 | 306 | 276 | 554 | 211 | 289 | 189 | 233 |
| 13 | ចំនួនបុរសអាយុពី១៨ឆ្នាំដល់ ៦៤ឆ្នាំ | 299 | 148 | 266 | 554 | 132 | 254 | 167 | 200 |
| 14 | ចំនួនស្ត្រីអាយុពី៦៥ឆ្នាំឡើង | 37 | 6 | 85 | 72 | 34 | 9 | 13 | 19 |
| 15 | ចំនួនបុរសអាយុពី៦៥ឆ្នាំឡើង | 18 | 10 | 75 | 72 | 45 | 15 | 10 | 17 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 16 | ចំនួនអនក្ខរជនភេទស្រីដែលមានអាយុចាប់ពី១៥ឆ្នាំឡើង | 36 | 50 | 81 | 33 | 10 | 64 | 14 | 25 |
| 17 | ចំនួនអនក្ខរជនភេទប្រុសដែលមានអាយុចាប់ពី១៥ឆ្នាំឡើង | 13 | 5 | 14 | 33 | 5 | 11 | 8 | 6 |
| 18 | ចំនួនផ្ទះមានដំបូលប្រក់ស្បូវ/ស្លឹក | 54 | 97 | 83 | 48 | 18 | 69 | 43 | 20 |
| 19 | ចំនួនផ្ទះមានដំបូលប្រក់ក្បឿង | 180 | 119 | 113 | 266 | 146 | 125 | 89 | 148 |
| 20 | ចំនួនផ្ទះមានដំបូលប្រក់ហ្វីប្រូស៊ីមងត៍ | 5 | 5 | 14 | 26 | 1 | 8 | 15 | 3 |
| 21 | ចំនួនផ្ទះមានដំបូលប្រក់សង្កសី | 16 | 14 | 19 | 3 | 6 | 6 | 12 | 15 |
| 22 | ចំនួនផ្ទះមានដំបូលបេតុង | 0 | 0 | 0 | 6 | 0 | 0 | 0 | 0 |
| 23 | ចំនួនគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់ | 0 | 1 | 16 | 15 | 7 | 1 | 0 | 0 |
| 24 | ចំនួនគ្រួសារដែលមានទឹកបំពង់ទុយោ ឬអណ្តូងស្នប់ ឬអណ្តូងលូ ប្រើប្រាស់បានដល់ក្នុងផ្ទះប្រចាំគ្រួសារ | 75 | 27 | 95 | 73 | 57 | 26 | 0 | 7 |
| 25 | ចំនួនគ្រួសារដែលមានទឹកបំពង់ទុយោ ឬអណ្តូងស្នប់ ឬអណ្តូងលូ ប្រើប្រាស់បានរួមគ្នាច្រើនគ្រួសារ ចំងាយ១៥០ម៉ែត្រពីផ្ទះ | 55 | 99 | 22 | 92 | 50 | 37 | 0 | 0 |
| 26 | ចំនួនគ្រួសារដែលប្រើប្រាស់ទឹកពីប្រភពផ្សេងទៀតៈ ស្រះ អណ្តូង បឹង ទន្លេទឹកភ្លៀង... ។ល។ ដែលមិនចូលក្នុងប្រភេទទាំងពីរខាងលើ | 125 | 109 | 118 | 184 | 59 | 145 | 159 | 179 |
| 27 | ចំនួនគ្រួសារដែលចិញ្ចឹមគោ-ក្របីក្នុងភូមិ | 239 | 231 | 217 | 320 | 166 | 202 | 151 | 186 |
| 28 | ចំនួនគ្រួសារចិញ្ចឹមជ្រូកនៅក្នុងភូមិ | 245 | 235 | 231 | 349 | 98 | 203 | 159 | 186 |
| 29 | តំលៃលក់ស្រូវចេញជាមធ្យមក្នុងភូមិក្នុងខែនេះខែ៥) | 500 | 400 | 450 | 360 | 350 | 370 | 370 | 370 |
| 30 | ចំនួនម៉ូតូ ម៉ូតូរ៉ឺម៉ក | 15 | 25 | 50 | 70 | 49 | 25 | 12 | 7 |
| 31 | ចំនួនត្រាក់ទ័រ គោយន្ត រថយន្ត | 0 | 0 | 4 | 2 | 2 | 1 | 1 | 5 |
| 32 | ចំនួនរទេះគោ និង រទេះសេះ | 87 | 134 | 115 | 234 | 156 | 206 | 93 | 153 |
| 33 | ចំនួនកង់ កង់រ៉ឺម៉ក | 153 | 204 | 121 | 250 | 169 | 0 | 102 | 131 |
| 34 | ចំនួនទូកចែវ/អុំ | 13 | 0 | 0 | 0 | 0 | 0 | 0 | 0 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 35 | ចំនួនទូកម៉ាស៊ីន/កាណូត | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 |
| 36 | ចំនួនគ្រួសារមានទូរទស្សន៍ | 46 | 37 | 77 | 90 | 27 | 40 | 30 | 15 |
| 37 | ចំនួនគ្រួសារដែលសំរាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅ | 10 | 13 | 21 | 3 | 2 | 2 | 6 | 9 |
| 38 | ចំនួនគ្រួសារដែលសំរាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង ១ឆ្នាំកន្លងទៅ | 7 | 0 | 4 | 4 | 1 | 4 | 0 | 3 |
| 39 | ចំនួនឆ្មបបុរាណដែលមានក្នុងភូមិ | 2 | 2 | 0 | 2 | 2 | 1 | 2 | 2 |
| 40 | ចំនួនឆ្មបដែលបានបណ្តុះបណ្តាលមានក្នុងភូមិ | 0 | 0 | 0 | 2 | 0 | 0 | 0 | 0 |
| 41 | ចំនួនគ្រួសារមានដីស្រែទទួលបានការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រ | 0 | 0 | 0 | 25 | 0 | 0 | 0 | 0 |
| 42 | ចំនួនគ្រួសារដែលប្រើជីគីមីក្នុងឆ្នាំកន្លងទៅសំរាប់ការដាំដុះ | 255 | 235 | 225 | 349 | 166 | 208 | 150 | 186 |
| 43 | ចំនួនគ្រួសារដែលប្រើថ្នាំសំលាប់សត្វល្អិតក្នុងឆ្នាំកន្លងទៅសំរាប់ការដាំដុះ | 15 | 0 | 15 | 40 | 25 | 45 | 42 | 82 |
| 44 | ចំនួនករណីឃាតកម្ម លួច ប្លន់ ចាប់ជំរិត ចាប់រំលោភ ក្នុង១ឆ្នាំកន្លងដែលមេភូមិដឹង | 0 | 0 | 1 | 1 | 1 | 2 | 0 | 0 |
| 45 | ចំនួនករណីទំនាស់ដីធ្លីក្នុង១ឆ្នាំកន្លងដែលមេភូមិដឹង | 2 | 1 | 5 | 4 | 5 | 13 | 5 | 3 |
| 46 | ចំនួនគ្រួសារដែលមានមេគ្រួសារជាស្ត្រីមានកូនអាយុតិចជាង៥ឆ្នាំ | 4 | 4 | 9 | 2 | 5 | 0 | 3 | 1 |
| 47 | ចំនួនគ្រួសារដែលជួបប្រទះអំពើហឹង្សាក្នុងគ្រួសារ១ឆ្នាំកន្លង | 2 | 0 | 1 | 1 | 0 | 0 | 1 | 0 |
| 48 | ទីតាំងផ្សារភូមិ...........) ជិតបំផុតដែលអ្នកភូមិធ្វើដំណើរទៅទិញទំនិញ | 7021308 | 7021308 | 7021308 | 7021308 | 7021308 | 7021308 | 7021308 | 7021308 |
| 49 | រយៈពេលធ្វើដំណើរពីភូមិទៅផ្សារនៅជិតបំផុតដោយជិះម៉ូតូគិតជាម៉ោង) | 60 | 90 | 30 | 45 | 45 | 45 | 45 | 45 |
| 50 | ចំងាយពីភូមិទៅផ្លូវដែលនៅជិតបំផុតដែលអាចបើកឡានចេញចូលពេញ ១ឆ្នាំ គិតជាគ.ម) | 0 | 2 | 0 | 0 | 0 | 0 | 0 | 1.5 |
| 51 | រយៈពេលធ្វើដំណើរពីភូមិទៅផ្លូវខាងលើដោយជិះម៉ូតូ គិតជាម៉ោង) | 0 | 5 | 0 | 0 | 0 | 0 | 0 | 10 |

## តំរោងមេរៀនទី៥.៣: កិច្ចសម្ភាសន៍ ឬការពិភាក្សាជាក្រុម

គោលបំណង : នៅចុងបញ្ចប់នៃមេរៀននេះ អ្នកចូលរួមទាំងអស់នឹង:

* យល់ពីចំណុចនិងបច្ចេកទេសសំខាន់ៗ ក្នុងការសម្ភាសន៍ជាក្រុម ឬការពិភាក្សា ជាក្រុម។
* បង្កើនបាននូវជំនាញក្នុងការដឹកនាំធ្វើការសម្ភាសន៍ជាក្រុមឬការពិភាក្សាជាក្រុម

រយៈពេល : ប្រហែល៩០នាទី។

វិធីសាស្ត្រ : សំនូរបំផុសគំនិត និងការសម្តែង។

សំភារៈ : ក្រដាសផ្ទាំងធំ ហ្វឺត។ល។

ឯកសារមេរៀន : ឯកសារមេរៀនទី៥.៣ គោលការណ៍ណែនាំស្តីពីការសំភាសន៍ឬពិភាក្សាជាក្រុម

របៀបសំរបសំរួល :

ក. គោលគំនិតនៃការសម្ភាសន៍ ឬពិភាក្សាជាក្រុម :

១. អ្នកសំរបសំរួលអធិប្បាយថា *ការដឹកនាំការសម្ភាសន៍ ឬការពិភាក្សាជាក្រុមនៅក្នុងសហគមន៍ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការប្រមូលពត៌មានអំពីការរស់នៅរបស់ប្រជាពលរដ្ឋ សេចក្តីត្រូវការ កង្វល់ និងបញ្ហារបស់ប្រជាពលរដ្ឋ។*

២. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមផ្តល់នូវបទពិសោធន៍របស់ពួកគាត់ក្នុងការចូលរួមក្នុងការសំភាសន៍ ឬពិភាក្សាជាក្រុមដើម្បីប្រមូលពត៌មានផ្សេងៗ ដោយសួរអ្នកចូលរួមថា:

- *តើពួកគេធ្លាប់បានធ្វើការសំភាសន៍ ឬការពិភាក្សាជាក្រុមជាលើកចុងក្រោយបង្អស់នៅពេលណា? ក្នុងគោលបំណងអ្វី?*
- *តើការពិភាក្សាជាក្រុមនោះមានចំណុចល្អអ្វីខ្លះ និងចំណុចមិនល្អអ្វីខ្លះ? តើគួរធ្វើអ្វីខ្លះដើម្បីកែលំអនូវ ចំណុចខ្វះខាតនេះ?* សរសេរយោបល់ដាក់ក្រដាស់ផ្ទាំងធំ។

៣. អ្នកសំរបសំរួលពន្យល់ពីគោលការណ៍ណែនាំសំរាប់ការសម្ភាសន៍ ឬការពិភាក្សាជាក្រុម និងចែកឯកសារមេរៀនទី៥.៣ ជូនអ្នកចូលរួម។ សួរអ្នកចូលរួមមានចម្ងល់ ឬមានយោបល់បន្ថែមអ្វីទេ។ ឆ្លើយតបនឹងសំណួរ។

៤. អ្នកសំរបសំរួលសួរអ្នកចូលរួម *តើអ្នកចូលរួមធ្លាប់បានប្រើគោលការណ៍ណែនាំទាំងនេះនៅក្នុង*

*ការងាររបស់ពួកគេកាលពីមុនមកដែរឬទេ? អាស្រ័យទៅលើបទពិសោធន៍របស់ពួកគេ តើអ្វីខ្លះដែលពួកគេគួរបន្ថែមពីគោលការណ៍នេះ?* សរសេរយោបល់អ្នកចូលរួមដាក់ក្រដាស់ផ្ទាំងធំ។

៥. អ្នកសំរបសំរួលសេចក្តីសង្ខេបគ្រួសៗលើសកម្មភាពខាងលើ។

ខ. **សំហាត់នៃការពិភាក្សាជាក្រុម**

១. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមជ្រើសរើសប្រធានបទសំខាន់មួយដែលទាក់ទងនឹងបទពិសោធន៍ជាក់ស្តែងរបស់ពួកគេ ដើម្បីលើកមកធ្វើការសម្ភាសន៍ ឬការពិភាក្សាឱ្យបានលំអិត។

២. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួម គិតរកសំនួរទូលំទូលាយដែលទាក់ទងនឹងប្រធានបទដែលពួកគេចង់សួរគ្នាទៅវិញទៅមក។ សរសេរសំណួរលើក្តារខៀនឬក្រដាស់ផ្ទាំងធំ។ ចំពោះសំនួរត្រូវមានចំនួនស្មើនឹងចំនួនអ្នកចូលរួម ដើម្បីឱ្យអ្នកចូលរួមទាំងអស់មានឱកាសអនុវត្តការដឹកនាំនិងសួរសំណួរ។

៣. អ្នកសំរបសំរួលនិងអ្នកចូលរួមកែសំរួលពាក្យពេជន៍ ឃ្លានៅក្នុងសំនួរដើម្បីឱ្យកាន់តែប្រសើរឡើង ហើយរៀបចំដាក់វាឱ្យត្រូវលំដាប់លំដោយ។

៤. អ្នកសំរបសំរួលបំបែកអ្នកចូលរួមជាក្រុមតូច (ក្នុងក្រុមនីមួយៗ អាចមានសមាជិកពី១០ទៅ១៥នាក់)។ អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមប្តូរវេនគ្នាម្តងម្នាក់ដើម្បីដឹកនាំក្រុមពិភាក្សាជុំវិញសំនួរនីមួយៗ។ អ្នកសំរបសំរួលត្រូវជំរុញឱ្យអ្នកចូលរួមសួរនូវសំណួរលំអិត (សំណួរដេញ) ដើម្បីទទួលបាននូវពត៌មានបន្ថែម។ ក្រុមនីមួយៗ ចាត់អ្នកកត់ត្រាម្នាក់ និងអ្នកសង្កេតម្នាក់។ នៅចុងបញ្ចប់នៃការពិភាក្សា អ្នកចូលរួមម្នាក់ៗ គួរតែធ្វើសេចក្តីសង្ខេបនូវអ្វីដែលបានពិភាក្សា ហើយអ្នកកត់ត្រាអាចបន្ថែមទៅលើការសង្ខេបនោះ (បើមិនទាន់គ្រប់គ្រាន់) និងកែសំរួលប្រសិនជាចាំបាច់។ ក្រុមធំក៏អាចបន្ថែមយោបល់និងកែសំរួលបានដែរ។ ចំពោះអ្នកសង្កេតអាចជួយបន្ថែមយោបល់ដល់អ្នកសួរ ប្រសិនបើការសួរមិនទាន់បានពេញលេញ។

៥. អ្នកសំរបសំរួលឆ្លុះបញ្ចាំងនិងធ្វើសេចក្តីសង្ខេបលទ្ធផលសំខាន់ៗលើការអនុវត្តន៍លំហាត់នេះ។

៦. អ្នកសំរបសំរួលធ្វើសេចក្តីសង្ខេបគោលគំនិតមេរៀនដោយឆ្លុះបញ្ចាំងទៅនឹងគោលបំណងមេរៀន

**កំណត់សំគាល់សំរាប់អ្នកសំរបសំរួល :**

ចំពោះការធ្វើលំហាត់នៃការសម្ភាសន៍ ឬពិភាក្សាក្រុម អ្នកសំរបសំរួលត្រូវត្រៀមប្រធានបទដែលទាក់ទងនឹងអ្នកចូលរួមភាគច្រើន និងរៀបចំសំនួរដែលទាក់ទងនឹងប្រធានបទនេះ សំរាប់ប្រើប្រាស់ក្នុងករណីអ្នកចូលរួមពិបាកក្នុងការកំណត់ប្រធានបទ និងសំនួរ។ អ្នកសំរបសំរួលគួររំលឹកមេរៀនមុន ឬពន្យល់បន្ថែមនូវអត្ថន័យនិងលើកឧទាហរណ៍ខ្លះៗ ស្តីពី **សំនួរបើក និងសំនួរបិទ**។

## ឯកសារមេរៀនទី៥.៣: ការសម្ភាសន៍ ឬពិភាក្សាជាក្រុម

### គោលការណ៍ណែនាំសំរាប់ការសម្ភាសន៍ ឬពិភាក្សាជាក្រុម :

- **រៀបចំសំនួររបស់អ្នកជាមុន** : គិតជាមុននិងសរសេរឱ្យហើយនូវសំនួរដែលអ្នកចង់សួរដល់ក្រុមរបស់អ្នក។ អ្នកត្រូវមានទាំងសំនួរបិទនិងសំនួរបើក។ ចាប់ផ្តើមដោយប្រើសំនួរងាយៗ ។
- **ជ្រើសរើសអ្នកសំរបសំរួលនិងអ្នកកត់ត្រា**: នៅក្នុងក្រុមពិភាក្សា សមាជិកម្នាក់ត្រូវសួរសំនួរ ហើយធ្វើការសំរបសំរួលក្រុមពិភាក្សា ហើយម្នាក់ទៀតត្រូវកត់ត្រាអ្វីដែលអ្នកឯទៀតនិយាយ។ អ្នកកត់ត្រាមិនត្រូវរំខានដល់អ្នកសួរសំនួរឬអ្នកឆ្លើយទេ ហើយអ្នកកត់ត្រាគួរតក់ត្រាអោយបានច្រើននូវអ្វីដែលអ្នកចូលរួមបាននិយាយ។
- **ប្រសិនបើអាច ត្រូវជ្រើសរើសអ្នកសង្កេតម្នាក់**: អ្នកសង្កេតម្នាក់អាចមានប្រយោជន៍សំរាប់ពិនិត្យមើលនូវកាយវិការ និងការចូលរួមផ្តល់យោបល់ ហើយអាចបំពេញសំនួរបន្ថែមក្នុងករណីអ្នកសួរសំនួរសួរមិនបានពេញលេញ។ ប្រសិនបើមិនអាចមានអ្នកសង្កេតទេ អ្នកនៅតែអាចធ្វើការសំភាសន៍ជាក្រុមដដែល។
- **ជ្រើសរើសអ្នកចូលរួមឱ្យបានសមស្រប** : ក្រុមរបស់អ្នកមិនត្រូវមានទំហំតូចពេកឬធំពេកទេ។ ត្រូវជ្រើសរើសពីចំនួន៦នាក់ទៅ១២នាក់។ ជាទូទៅត្រូវជ្រើសរើសអ្នកដែលមានអាយុប្រហាក់ប្រហែលគ្នា មានភេទដូចគ្នា និងអ្នកដែលមានស្ថានភាពប្រហាក់ប្រហែលគ្នា។
- **ត្រូវធ្វើអោយសមាជិកក្រុមពិភាក្សាមានអារម្មណ៍កក់ក្តៅ** : ការលេងល្បែងកំសាន្តខ្លីមួយ ឬច្រៀងចំរៀងមុនពេលពិភាក្សាជាក្រុម ដើម្បីធ្វើអោយសមាជិកក្រុមពិភាក្សាភាពស្និទស្នាលនិងបង្កើនទំនុកចិត្ត។ ពួកគេអាចនិយាយត្រង់ជាមួយអ្នក ប្រសិនបើពួកគេមានអារម្មណ៍កក់ក្តៅជាមួយអ្នក។
- **រក្សាទំនាក់ទំនងក្រសែភ្នែកជាមួយសមាជិកទាំងអស់នៅក្នុងក្រុម** : នៅពេលសួរសំនួរអ្នកត្រូវសំឡឹងមើលអ្នកចូលរួមទាំងអស់នៅក្នុងក្រុម។
- **ជំរុញអ្នកដែលមិននិយាយអោយនិយាយ តាមរយៈ:**

  ក). នៅពេលសួរសំនួរត្រូវសំលឹងទៅរកអ្នកនោះ ហើយញញឹមដាក់គាត់ ។

  ខ). និយាយថាអ្នកចង់ឮពីអ្នកដែលមិនទាន់បាននិយាយឬបញ្ចេញយោបល់នៅឡើយ។

  គ). ហើយសួរប្រសិន បើមានអ្នកណាម្នាក់មានអ្វីត្រូវបន្ថែម។

- **មធ្យោបាយសមស្របដើម្បីទប់ស្កាត់អ្នកដែលមានយោបល់ច្រើនហួសហេតុ** តាមរយៈ :

  ក). តើអ្នកណាមានយោបល់ឬទស្សនៈអ្វីផ្សេងទៀត?

  ខ). ប្រាប់ថា អ្នកឮអ្នកដែលមិនទាន់និយាយចង់បញ្ចេញយោបល់ សុំឱ្យអ្នកនិយាយច្រើនរង់ចាំសិន

  គ). ដើរជុំវិញក្រុម ហើយសួរអ្នកចូលរួមគ្រប់គ្នាឱ្យឆ្លើយ។ ធ្វើដូចនេះដើម្បីធានាថាអ្នកចូលរួមគ្រប់គ្នាចូលរួមផ្តល់នូវយោបល់។

- **សួរសំណួរជេញចន្លៈ** នៅពេលដែលចម្លើយឆ្លើយតបទៅនឹងសំណួររបស់អ្នកមិនទាន់បានគ្រប់គ្រាន់ អ្នកអាចសួរសំណួរដេញលំអិតទៀត ដើម្បីទទួលបានពត៌មានបន្ថែម។ ឧ. ប្រសិនបើអ្នកសួរសំណួរ ˝ តើអ្នកដងទឹកទឹកពីអណ្តូងឬពីទន្លេ? អ្នកអាចប្រើសំណួរដេញថាៈ តើអណ្តូងនៅឯណា? មានអណ្តូងប៉ុន្មាន? តើទឹកណាល្អជាង? អណ្តូងឬទន្លេ? តើប្រជាពលរដ្ឋប៉ុន្មានអ្នកដងទឹកអណ្តូង? ប៉ុន្មានអ្នកដងទឹកពីទន្លេ? ។ល។

## ធំរោងមេរៀនទី៦.៤.១: ការបង្ហាញនៅក្នុងកិច្ចប្រជុំ ឬសិក្ខាសាលា

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ អ្នកចូលរួមនឹងអាចទទួលបាននូវ :

* ជំនាញក្នុងការបង្ហាញពត៌មាន និងការពិភាក្សាក្នុងអង្គប្រជុំ។

**រយៈពេល** : ប្រហែល៦០នាទី។

**វិធីសាស្ត្រ** : អធិប្បាយ និងការសម្តែង។

**សំភារៈ** : ក្រដាសផ្ទាំងធំ ហ្វឺត ។ល។

**ឯកសារមេរៀន** : ឯកសារមេរៀនទី៦.៤.១ក ការណែនាំសំរាប់ការបង្ហាញប្រកបដោយប្រសិទ្ធភាពនៅក្នុងអង្គប្រជុំ។

ឯកសារមេរៀនទី៦.៤.១ខ : ករណីសិក្សាស្តីពីការអប់រំ។

**របៀបសំរបសំរួល** :

ក. សេចក្តីផ្តើមនៃការប្រជុំ

១. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួម*គិតពីពេលដែលពួកគេបានចូលរួមនៅក្នុងអង្គប្រជុំ។* ឱ្យអ្នកចូលរួមចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេក្នុងការចូលរួមក្នុងអង្គប្រជុំ។

២. អ្នកសំរបសំរួលពន្យល់ថា *យើងម្នាក់ៗតែងតែចូលរួមក្នុងអង្គប្រជុំ។ នៅក្នុងកិច្ចប្រជុំតែងតែមានការបង្ហាញពត៌មាន ការចូលរួមការពិភាក្សា ឬចរចាពីអ្វីមួយ។ ជាពិសេស អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារត្រូវចូលរួមធ្វើការបង្ហាញនិងចរចាតំណាងឱ្យស្ត្រីនិងកុមារនៅក្នុងឃុំ-សង្កាត់។ ជានិច្ចជាកាល នៅក្នុងអង្គប្រជុំយើងប្រើប្រាស់ជំនាញក្នុងការទំនាក់ទំនងដូចជា : ការ ស្តាប់ សួរសំនួរ និងការសង្ខេប ដើម្បីទទួលបាននូវខ្លឹមសារនៃកិច្ចប្រជុំនិងងាយស្រួលក្នុងការធ្វើសេចក្តីសំរេច។*

៣. អ្នកសំរបសំរួលចែកឯកសារមេរៀនទី៦.៤.១ក និងពន្យល់ថា ការណែនាំពីការប្រស្រ័យទាក់ទងនៅក្នុងអង្គប្រជុំនេះមានប្រយោជន៍ណាស់សំរាប់ជួយដល់ស្មារតីដល់ពួកគាត់ ដូចនេះពួកគាត់ត្រូវព្យាយាមយកចិត្តទុកដាក់ស្តាប់និងសួរនូវអ្វីដែលពួកគេមានចម្ងល់។ សុំអោយអ្នកចូលរួមអានឯកសារដែលបានចែកជូន ហើយសួរអ្នកចូលរួមថា *តើពួកគេមានចម្ងល់អ្វីដែរឬទេ?* ឆ្លើយតបនឹងសំណួរទាំងនោះ។

ខ. ករណីសិក្សាស្តីពីការបង្ហាញនៅក្នុងកិច្ចប្រជុំឬក្នុងសិក្ខាសាលា

១. អ្នកសំរបសំរួលជំរាបអ្នកចូលរួមថា ក្នុងពេលនេះពួកគេនឹងធ្វើលំហាត់មួយស្តីពីការបង្ហាញនៅក្នុង

កិច្ចប្រជុំ ។

២. អ្នកសំរបសំរួលពន្យល់ថា *គោលបំណងនៃការបង្ហាញនេះ គឺដើម្បីទទួលការយល់ព្រមពីអភិបាលខេត្ត ដែលជាមនុស្សម្នាក់មានការមមាញឹកយ៉ាងខ្លាំង ដូច្នេះការបង្ហាញត្រូវតែខ្លី។ នៅក្នុងពេលជាមួយគ្នានេះដែរ អ្នកបង្ហាញគួរតែផ្តល់ព័ត៌មានអោយបានគ្រប់គ្រាន់ ដើម្បីងាយស្រួលដល់អភិបាលខេត្តធ្វើការសំរេច។*

៣. អ្នកសំរបសំរួលចែកករណីសិក្សាឯកសារមេរៀនទី៦.៤.១ខ ដល់អ្នកចូលរួម និងផ្តល់រយៈពេល ១៥នាទី សំរាប់ឱ្យពួកគេបានអាននូវករណីសិក្សានេះ។ បន្ទាប់មក សុំឱ្យអ្នកចូលរួមជ្រើសរើសសមាជិក១រូប សម្តែងតួជាអភិបាលខេត្ត សមាជិក ១រូបសម្តែងជាប្រធានមន្ទីរអប់រំ និងសមាជិក ៣រូបទៀតសម្តែងតួជាអ្នកតំណាងអង្គការមិនមែនរដ្ឋាភិបាល រីឯសមាជិកផ្សេងទៀតជាអ្នកសង្កេតការសម្តែង ដោយផ្តោតមើលជាពិសេសទៅលើអ្នកសម្តែងជាតំណាងសមាគមមនុស្សចម៏។ អ្នកសម្តែងម្នាក់ៗត្រូវព្យាយាមអនុវត្តទៅតាមគោលការណ៍ណែនាំនេះក្នុងឯកសារមេរៀនទី៦.៤.១ក។

៤. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមចាប់ផ្តើមអនុវត្តលំហាត់។ នៅពេលចប់លំហាត់លើកទីមួយត្រូវបន្តអនុវត្តលំហាត់នេះដដែលទៀត ដោយសុំសមាជិកដែលមិនទាន់បានសម្តែងឡើងសម្តែងម្តង។

៥. អ្នកសំរបសំរួលសួរទៅអ្នកសង្កេត តើការសម្តែងនេះដូចម្តេចដែរ? ស្របទៅតាមគោលការណ៍ណែនាំដែរឬទេ? សុំអោយអ្នកចូលរួមគិតគិតនិងបញ្ចេញយោបល់កែលំអនិងបន្ថែម។ សរសេរយោបល់លើក្រដាស់ផ្ទាំងធំ។ អ្នកសំរបសំរួលសង្ខេបនិងបន្ថែមយោបល់ទៅលើការបង្ហាញ។

៦. អ្នកសំរបសំរួលសួរអ្នកសម្តែងថា *តើអ្វីជាការងាយស្រួល និងអ្វីជាការលំបាកនៅក្នុងការបង្ហាញនេះ? តើការបង្ហាញនេះមានពត៌មាននិងហេតុផលគ្រប់គ្រាន់សំរាប់ឱ្យអភិបាលខេត្តធ្វើការសំរេចឬទេ?* សុំឱ្យអ្នកចូលរួមបន្ថែមគំនិតថ្មីៗ ដើម្បីធ្វើអោយការបង្ហាញកាន់តែមានប្រសិទ្ធភាព។ សរសេរយោបល់របស់អ្នកចូលរួមលើក្រដាស់ផ្ទាំងធំ។

៧. អ្នកសំរបសំរួលសង្ខេបចំណុចសំខាន់ៗ និងខ្លឹមសារមេរៀន។

**កំណត់សំគាល់របស់អ្នកសំរបសំរួល:**

មេរៀននេះពាក់ពន្ធ័ទៅនឹងការបង្ហាញពត៌មានដល់អ្នកណាដែលយើងគិតថា ចាំបាច់ត្រូវតែដឹងពីពត៌មានទាំងអស់នេះ។ ជារឿយៗអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារត្រូវធ្វើការបង្ហាញពត៌មានពាក់ពន្ធ័នឹងគំរោងដល់មន្ទីរកិច្ចការនិងអតីតយុទ្ធជន អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័ននានា ដូចនេះ អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារត្រូវតែយល់ដឹងនិងចេះនូវរបៀបនៃការបង្ហាញពត៌មានទាំងនេះ។

## ឯកសារមេរៀនទី៦.៤.១ក : ការណែនាំសំរាប់ការប្រស្រ័យទាក់ទងនៅក្នុងអង្គប្រជុំ

- **ចាប់ផ្តើម :** ណែនាំខ្លួនរបស់អ្នក។ អ្នកត្រូវតែត្រៀមចំណុចសំខាន់ៗជាមុន។ ចាប់ផ្តើមដោយនិយាយថា "ខ្ញុំមានចំណុចដែលត្រូវលើកយកមកបង្ហាញឬជំរាបចំនួន ............. ហើយខ្ញុំសូមចាប់ផ្តើមពីចំណុច ........" ។

- **ការស្នើសុំឱ្យអ្នកចូលរួមបញ្ចេញយោបល់ :** សុំឱ្យអ្នកដទៃបញ្ចេញទស្សនៈរបស់ពួកគេដោយនិយាយថា "តើអ្នកមានទស្សនៈយ៉ាងណាចំពោះ..........?"

- **ផ្តល់យោបល់របស់ខ្លួន** ស្តាប់ដោយប្រុងប្រយ័ត្ននូវអ្វីដែលអ្នកដទៃនិយាយ ។ បង្ហាញជំហររបស់អ្នកដោយនិយាយថា "នៅក្នុងទស្សនៈរបស់ខ្ញុំ ឬការយល់ឃើញរបស់ខ្ញុំ.........." ។

- **ត្រូវនាំអ្នកនិយាយផ្សេងទៀតទៅជាមួយ :** ដើម្បីទទួលបាននូវការគាំទ្រដល់ជំហរ ឬចំណុចសំខាន់ៗរបស់អ្នកជាគំនិតល្អ គឺត្រូវអញ្ជើញអ្នកណាម្នាក់ទៀតដែលអាចផ្តល់ពត៌មាននិងការយល់ឃើញដែលជួយបន្ថែមនិងគាំទ្រទៅនឹងគំនិតរបស់អ្នក។

- **ការយល់ព្រម :** ត្រូវនិយាយយល់ព្រម ប្រសិនបើអ្នកស្តាប់ឮអ្វីដែលអ្នកត្រូវយល់ព្រម ដោយនិយាយថា "ខ្ញុំយល់ស្របតាមអ្នកទាំងស្រុងទៅលើ......" ។ ចំណុចនេះសំខាន់ព្រោះនៅពេលដែលអ្នកយល់ព្រមជាមួយពួកគេ ពួកគេមានអារម្មណ៍ថាពួកគេបានទទួលការគាំទ្រនិងអាចផ្តល់នូវការគាំទ្រដល់អ្នកនៅពេលអនាគត ។

- **ការយល់ព្រមលើផ្នែកខ្លះៗ :** ដំបូងអ្នកត្រូវនិយាយយល់ព្រមសិន "ជាគោលការណ៍ខ្ញុំយល់ព្រម ឬយល់ព្រមទាំងស្រុងជាមួយអ្នក។ ប៉ុន្តែខ្ញុំចង់បញ្ជាក់ឡើងវិញថា ឬចង់បន្ថែមថា......ឬម្យ៉ាងទៀត..."។

- **ការមិនយល់ព្រមប្រកបដោយភាពឆ្លិនឆ្លាស់ :** ជាការល្អអ្នកមិនត្រូវនិយាយថាអ្នកមិនយល់ព្រមនោះទេ អ្នកត្រូវនិយាយថា "ខ្ញុំប្រហែលជាមានការយល់ឃើញផ្សេងដែលខ្ញុំចង់ផ្តល់អោយ ឬរបៀបថ្មីក្នុងការមើលទៅលើ.......គឺ.........." ហើយប្រសិនបើបុគ្គលផ្សេងទៀតនៅតែមិនឆ្លើយតប ពេលនោះអ្នកអាចនិយាយ "ខ្ញុំគារម្តថា យើងប្រហែលជាមិនមានការយល់ព្រមទៅលើចំណុចនេះទេ"។

- **ការសង្ខេប :** កត់ត្រាចំណុចសំខាន់ៗ ។ សង្ខេបនូវអ្វីដែលបាននិយាយរួចហើយ ។

- **ការកែតំរូវការយល់ច្រឡំ :** ពេលខ្លះនៅក្នុងអង្គប្រជុំ អាចមាននូវការប្រស្រ័យទាក់ទងគ្នាមិនបានត្រឹមត្រូវ ឬមានការយល់ច្រឡំ។ ដូចនេះ ជាការចាំបាច់ដែលអ្នកត្រូវកែតំរូវនូវការយល់ច្រឡំទាំង

នោះភ្លាមៗ ដោយនិយាយថា "ប្រហែលមានការយល់ច្រឡំ។ សូមអោយខ្ញុំនិយាយអោយបាន ច្បាស់ឡើងវិញនូវអ្វីដែលខ្ញុំចង់និយាយ គឺ................." ។

- ការសុំពត៌មានបន្ថែមឬការបញ្ជាក់ឡើងវិញ : ប្រសិនបើអ្នកមិនយល់នូវអ្វីមួយ អ្នកមិនត្រូវខ្មាសចំពោះការនិយាយថា អ្នកមិនយល់នោះទេ។ អ្នកត្រូវសុំពត៌មានបន្ថែម ដោយនិយាយថា "អ្នកអាចអោយជា ឧទាហរណ៍បានទេ ថាតើអ្នកចង់មានន័យថាម៉េច? ឬ តើអ្នកអាចនិយាយអោយជាក់លាក់ជាងនេះបានទេ? ឬតើអ្នកអាចពន្យល់អោយលំអិតជាងនេះបានទេ?
- ការផ្តល់អនុសាសន៍ សំណើរឬយោបល់ : ប្រសិនបើអាច ត្រូវរៀបចំអនុសាសន៍របស់អ្នកមុនពេលធ្វើការប្រជុំ។ បង្ហាញអនុសាសន៍ឱ្យច្បាស់និងខ្លី។ ចាប់ផ្តើមដោយនិយាយថា "ខ្ញុំសូមផ្តល់អនុសាសន៍ ដូចតទៅ ....."។
- ការសំដែងនូវការគាំទ្រ : ប្រសិនបើអ្នកស្តាប់ឮអនុសាសន៍ដែលអ្នកមានការយល់ព្រម អ្នកត្រូវនិយាយថា យល់ព្រម ។
- ការបង្ហាញការជំទាស់ : អ្នកមិនត្រូវមានអារម្មណ៍ខ្មាសចំពោះការសំដែងការជំទាស់ដោយភាពប៉ិនប្រសប់ទេ ។ គិតអោយបានហ្មត់ចត់ពីអ្វីដែលជាការបារម្ភរបស់អ្នក ហើយបង្ហាញក្តីបារម្ភនោះដល់អង្គប្រជុំ។ ត្រូវចាប់ផ្តើមដោយនិយាយ "ខ្ញុំសុំអោយក្រុមគិតគូរពីការបារម្ភរបស់ខ្ញុំ................ ដូចនេះបានផ្តល់ជាអនុសាសន៍ដូចតទៅ ................" ។
- ការបញ្ចុះបញ្ចូល : ការបញ្ចុះបញ្ចូលមានសារៈសំខាន់ដើម្បីឱ្យទទួលបាននូវការគាំទ្រលើអនុសាសន៍របស់អ្នក។ ត្រូវបញ្ជាក់គំនិតរបស់អ្នកហើយមើលទៅអ្នកចូលរួមទាំងអស់ដើម្បីស្វែងរកការគាំទ្រ។ សំដែងគំនិតជំទាស់របស់អ្នកអោយបានច្បាស់ៗ ។ បញ្ជាក់ពីផលប្រយោជន៍ចំពោះអ្នកស្តាប់ និងផលប្រយោជន៍រួមដល់សហគមន៍។
- ការផ្តល់នូវការសំរុះសំរួល : ប្រសិនបើភាគីទាំងសងខាងមិនអាចព្រមព្រៀងគ្នា ពួកគេអាចនឹងឈានទៅរកការសំរុះសំរួល ។ ស្វែងរកដំណោះស្រាយដែលភាគីទាំងអស់អាចយល់ព្រម ។ ចាប់ផ្តើមដោយនិយាយថា "ប្រហែលជាយើងអាចសំរុះសំរួលគ្នា ............." ។

***ជារួមអ្នកត្រូវស្តាប់ដោយយកចិត្តទុកដាក់ មិនត្រូវរំខានឬកាត់បន្ថយភាពនឹងនររបស់អ្នកឡើយ ហើយមិនត្រូវខ្មាសក្នុងការនិយាយទេ ។***

(ដកស្រង់ចេញពី Goodale, Malcolm : Meeting : Language Teaching Publications)

នៅតាមបណ្តាប្រទេសដែលកំពុងអភិវឌ្ឍន៍ ការអប់រំត្រូវបានគេចាត់ទុកជាមូលដ្ឋានគ្រឹះសំរាប់កសាងប្រទេស។ មនុស្សម្នាក់ៗត្រូវរិះរកគ្រប់មធ្យោបាយដើម្បីសិក្សារៀនសូត្រ ស្រាវជ្រាវ ស្វែងរកចំណេះដឹង ជំនាញ និងបច្ចេកវិជ្ជាថ្មីៗ សំរាប់យកទៅប្រើប្រាស់ក្នុងសង្គមគ្រួសារនិងសង្គមជាតិ។ ប្រទេសកម្ពុជា គឺជាប្រទេសមួយកំពុងអភិវឌ្ឍន៍ ហើយការបណ្តុះបណ្តាលធនធានមនុស្សគឺជាកត្តាមួយដ៏សំខាន់។

បុរស-ស្ត្រី ក្មេងប្រុស-ក្មេងស្រី មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ សិទ្ធិក្នុងការទទួលបាននូវការសិក្សាដោយមិនប្រកាន់ក្មេងប្រុសឬក្មេងស្រី ហើយអ្នកទាំងពីរអាចទទួលបានការងារដូចគ្នា ប្រាក់កំរៃស្មើគ្នា មានការទទួលខុសត្រូវក្នុងការងារផ្ទះដូចគ្នា ចូលរួមក្នុងការងារសង្គមជាតិនិងមានតួនាទី ឋានៈសមស្របប្រកបដោយសមធម៌។ ប្រសិនបើឪពុកម្តាយបានជំរុញទាំងកូនប្រុសកូនស្រីឱ្យបានរៀនខ្ពស់ដូចគ្នា គេទាំងពីរនាក់អាចជួយការងារគ្នា អាចរួមគ្នាដោះស្រាយបានរាល់បញ្ហាដែលគេជួបប្រទះក្នុងជីវិតរបស់គេ ធ្វើសេចក្តីសំរេចរួមមុននឹងធ្វើអ្វីមួយ ចេះគោរពសិទ្ធិគ្នាទៅវិញទៅមក និងជាដៃគូដ៏សំខាន់ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។

ប៉ុន្តែជាទូទៅ មនុស្សភាគច្រើនក្នុងសង្គមកម្ពុជា មិនសូវគិតគូរនិងឱ្យតម្លៃទៅលើការសិក្សាអប់រំរបស់ក្មេងស្រីនៅឡើយទេ។ ជាលទ្ធផលនៅប្រទេសកម្ពុជា ការអប់រំរបស់កុមារីនៅមានគំលាតឆ្ងាយពីកុមារា ដោយសារសង្គមគ្រួសារ មិនទាន់បានគិតគូរនិងយកចិត្តទុកដាក់ជំរុញក្មេងស្រីឱ្យរៀនបានខ្ពស់ដូចក្មេងប្រុស។ ឪពុកម្តាយមួយចំនួនធំបានបញ្ឈប់ការសិក្សារបស់ក្មេងស្រី ដើម្បីទុកឱ្យក្មេងស្រីជួយធ្វើការងារផ្ទះ និងរកប្រាក់ចំណូលសំរាប់ជួយផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ ដោយពួកគាត់យល់ថាកូនស្រីមិនចាំបាច់រៀនសូត្រខ្ពស់ពេកទេ ព្រោះទៅអនាគតនឹងក្លាយទៅជាភរិយា ជាមេផ្ទះ ជាម្តាយដ៏ល្អដែលត្រូវបំពេញភារៈកិច្ចចាំបាច់គឺការមើលថែទាំកូនចៅនិងផ្ទះសំបែង រីឯការងារដែលមានឋានៈតួនាទីធំៗ ដូចជាអ្នកនយោបាយ អ្នកដឹកនាំស្ថាប័ន គឺជាការងាររបស់បុរស។ មិនតែប៉ុណ្ណោះនៅមានពាក្យស្លោកជាច្រើនដែលបណ្តុះបង្ហាប់និងមិនឱ្យតម្លៃដល់ស្ត្រីដូចជា "ស្ត្រីវិលចង្ក្រានមិនជុំ ស្ត្រីមុជមិនជ្រៅទៅមិនឆ្ងាយ" ដោយសារកត្តាទាំងអស់នេះហើយដែលធ្វើឱ្យក្មេងស្រីមួយចំនួនធំមិនមានឱកាសរៀនសូត្របានខ្ពស់ដូចក្មេងប្រុស។

ការអប់រំជាបញ្ហាសំខាន់សំរាប់មនុស្សគ្រប់រូប ហេតុនេះឪពុកម្តាយ និងសង្គមត្រូវផ្តល់ឱកាសនិងទទួលស្គាល់ ហើយឱ្យតំលៃលើការសិក្សារបស់ក្មេងស្រី ដើម្បីពួកគេទទួលបានចំណេះដឹង ជំនាញនិងបច្ចេកវិទ្យាថ្មី និងអាចមានសមត្ថភាពក្នុងការចូលរួមការងារសង្គម និងអាចប្រកបមុខរបរសំរាប់

ផ្គត់ផ្គង់ជីវភាពគ្រួសារ មិនតែប៉ុណ្ណោះ ដើម្បីឱ្យពួកគេអាចមានលទ្ធភាពក្នុងការទទួលខុសត្រូវចំពោះការងារ ដោះស្រាយបញ្ហាដែលកើតមានឡើងក្នុងគ្រួសារ ហ៊ានធ្វើសេចក្តីសំរេចនៅក្នុងសហគមន៍ និងសង្គម។ សង្គមគ្រួសារនិងសង្គមជាតិទាំងមូលយល់ដឹងពីបញ្ហាយេនឌ័រនិងកែប្រែទស្សនៈឥរិយាបទមិនសមស្របដែលមានតាំងពីយូរលង់ណាស់មកហើយ។ បុរស-ក្មេងប្រុសត្រូវជួយរំលែកការងាររបស់ស្ត្រីក្មេងស្រី ជំរុញនិងលើកទឹកចិត្តក្មេងស្រីឱ្យរៀនបានខ្ពស់ដូចក្មេងប្រុស។ រដ្ឋាភិបាលត្រូវគិតគូរនិងដោះស្រាយបង្កើតអន្តេវាសិកដ្ឋានសំរាប់ក្មេងស្រីនិងសិស្សស្រីស្នាក់នៅ។

នៅក្នុងភូមិដីរស ស្រុកសំពៅលូន ក្នុងខេត្តបាត់ដំបង មានបញ្ហាចំបងក្នុងការអប់រំ ដោយសារតែបញ្ហាគ្មានសាលារៀន។ អង្គការមិនមែនរដ្ឋាភិបាលមួយធ្វើការដើម្បីលើកស្ទួយការអប់រំ មានគោលបំណងសាងសង់សាលាអនុវិទ្យាល័យចំនួន៣ខ្នង ក្នុងមួយខ្នងមាន៥បន្ទប់សំរាប់កុមារា-កុមារីរៀន និងសាងសង់កន្លែងស្នាក់នៅសំរាប់កុមារី ដើម្បីលើកទឹកចិត្តកុមារីអោយទៅសាលារៀន។

ដំបូងអង្គការមិនមែនរដ្ឋាភិបាលបានជួបជាមួយនឹងមន្ទីរអប់រំខេត្ត ដើម្បីពិភាក្សាទៅលើការសាងសង់សាលារៀននិងកន្លែងស្នាក់របស់កុមារី។ អង្គការនោះបានលើកហេតុផលខ្លះៗសំរាប់ជ្រើសរើសកន្លែងសាងសង់សាលារៀន។ នៅក្នុងនោះហេតុផលមួយក្នុងចំណោមហេតុផលទាំងអស់ គឺបញ្ហាគ្មានសាលារៀននៅជិត និងមូលហេតុផ្សេងទៀត គឺនៅសាលារៀនជិតភូមិគ្មានបន្ទប់គ្រប់គ្រាន់។ មន្ទីរអប់រំខេត្តមានការចាប់អារម្មណ៍សហការណ៍ជាមួយអង្គការមិនមែនរដ្ឋាភិបាលនោះក្នុងការសាងសង់សាលារៀន ប៉ុន្តែត្រូវមានការយល់ព្រមជាគោលការណ៍ពីអភិបាលខេត្ត ។

ដូច្នេះ ដើម្បីមានការយល់ព្រមពីអភិបាលខេត្ត លុះត្រាតែប្រធានមន្ទីរអប់រំនិងតំណាងអង្គការមិនមែនរដ្ឋាភិបាលទៅជួបផ្ទាល់ជាមួយអភិបាលខេត្តដើម្បីផ្តល់ពត៌មានពីគំរោងសាងសង់សាលារៀន។ តំណាងអង្គការមិនមែនរដ្ឋាភិបាល ត្រូវធ្វើការបកស្រាយបង្ហាញជូនដល់អភិបាលខេត្ត ក្នុងរយៈពេលប្រមាណ១៥នាទី ស្តីពីសំណើរគំរោង តម្រូវការរបស់សាលា ផលប្រយោជន៍ និងសារសំខាន់នៃគំរោងដល់សហគមន៍។

តំណាងអង្គការមិនមែនរដ្ឋាភិបាល ត្រូវពិនិត្យនិងដកស្រង់ពត៌មាននិងចំណុចសំខាន់ៗ ដែលមាននៅក្នុងករណីសិក្សាសំរាប់ធ្វើការបង្ហាញដល់អភិបាលខេត្តនិងអ្នកពាក់ពន្ធ័ផ្សេងទៀត ដើម្បីឱ្យពួកគេគាំទ្រលើការបង្ហាញរបស់យើង។

ពត៌មាននិងចំណុចសំខាន់ៗ :

- ផលប៉ះពាល់ជាអវិជ្ជមានដល់កុមារី សង្គមគ្រួសារ និងសហគមន៍ ប្រសិនបើកុមារីមិនបានចូលរៀន និងរៀនមិនបានច្រើន។

- ហេតុផលនិងផលប្រយោជន៍នៃការសិក្សារបស់កុមារីនិងស្ត្រី ដល់កុមារីនិងស្ត្រី ក្រុមគ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល។

## គំរោងមេរៀនទី៦.៤.២ : ការចរចានៅក្នុងកិច្ចប្រជុំ

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះអ្នកចូលរួមនឹងអាច :

* បង្កើនបាននូវជំនាញក្នុងការចរចាតាមរយៈការអនុវត្តន៍ដោយផ្ទាល់។

**រយៈពេល** : ប្រហែល១៨០ នាទី។

**វិធីសាស្រ្ត** : ការសម្តែងតួ និងសំនួរបំផុសគំនិត។

**សំភារៈ** : ក្រដាសផ្ទាំងធំ ហ្វឺត ។ល។

**ឯកសារមេរៀន** : ឯកសារមេរៀនទី៦.៤.២ក: គោលការណ៍ណែនាំសំរាប់ត្រៀមរៀបចំមុន ពេលប្រជុំនិងការចរចា។

ឯកសារមេរៀនទី៦.៤.២ខ: ករណីសិក្សា ស្តីពី អំពើហិង្សាក្នុងគ្រួសារ។

ឯកសារមេរៀនទី៦.៤.២គ: ការណែនាំសំរាប់អ្នកសម្តែងជាក្រុមប្រឹក្សាឃុំ-សង្កាត់។

ឯកសារមេរៀនទី៦.៤.២ឃ: ការណែនាំសំរាប់អ្នកសម្តែងជាអង្គការមិនមែនរដ្ឋាភិបាល។

ឯកសារមេរៀនទី៦.៤.២ង: គោលការណ៍នៃការចរចា។

របៀបសំរបសំរួល :

ក. **ការចរចានៅក្នុងអង្គប្រជុំ**

១. អ្នកសំរបសំរួលសុំអោយអ្នកចូលរួមគិតអំពីពេលដែលពួកគេបញ្ចុះបញ្ចូលអ្នកណាម្នាក់ឱ្យធ្វើអ្វីមួយ ឬការចរចាអំពីអ្វីមួយជាមួយនឹងនរណាម្នាក់ ។ ឧទាហរណ៍អាចមាននៅក្នុងគ្រួសារ នៅកន្លែងធ្វើការ ឬនៅក្នុងទីផ្សារ ។ សុំអោយអ្នកណាម្នាក់ផ្តល់បទពិសោធន៍របស់ខ្លួន។

២. អ្នកសំរបសំរួលសុំអោយអ្នកចូលរួមពិភាក្សាពីកត្តាដែលនាំអោយការចរចាទទួលបានជោគជ័យ និងផ្តល់ជាបទពិសោធន៍របស់ពួកគេ។

៣. អ្នកសំរបសំរួលពន្យល់ថា ការចរចាគឺជាជំនាញដ៏សំខាន់ដែលអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារត្រូវរៀន។ អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារអាចត្រូវធ្វើការចរចាជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ស្តីពី គំរោងជាអាទិភាពដែលផ្តល់ប្រយោជន៍ដល់ស្ត្រីនិងកុមារ។ នៅពេលធ្វើការចរចាត្រូវធ្វើទៅតាមជំហានដែលអាចនាំឱ្យភាគីទាំងសងខាងទទួលបានប្រយោជន៍ ។ ពេលខ្លះ អ្នកចរចាគិតក្នុងន័យយកឈ្នះយកចាញ់ ដែលធ្វើអោយមិនមានការព្រមព្រៀងកើតឡើងបាន។ ជារឿយៗ មានការ

ចរចាជាច្រើនកើតមាននៅក្នុងអង្គប្រជុំ។ ពេលខ្លះ អ្នកចរចាទៅចូលរួមក្នុងអង្គប្រជុំដោយមិនបានត្រៀមជាមុន។ ប៉ុន្តែជាការល្អ គេត្រូវគិតទុកជាមុនពីការប្រជុំ និងពីអ្វីដែលគេរំពឹងថានឹងទទួលបានពីអង្គប្រជុំ។

៤. អ្នកសំរបសំរួលចែកឯកសារមេរៀនទី៦.៤.២ក ស្តីពី គោលការណ៍ណែនាំសំរាប់ត្រៀមរៀបចំមុនពេលប្រជុំនិងការចរចាដល់អ្នកចូលរួម ហើយពន្យល់ថា ឯកសារមេរៀននេះផ្តល់នូវគោលការណ៍ណែនាំខ្លះៗ ស្តីពីការត្រៀមរៀបចំការប្រជុំដែលមានការចរចានៅក្នុងអង្គប្រជុំ។ គោលការណ៍ណែនាំនឹងជួយឱ្យភាគីទាំងសងខាងធ្វើវិភាគពីស្ថានភាពតាមការយល់ឃើញរបស់ខ្លួនផ្ទាល់ និងតាមការយល់ឃើញរបស់ភាគីម្ខាងទៀត។ គោលការណ៍ណែនាំជួយអោយមានការត្រៀម និងប្រើប្រាស់ពត៌មានលំអិត និងត្រឹមត្រូវដើម្បីគាំទ្រទៅលើគោលបំណងនៃការចរចា និងសំរាប់ធ្វើការបញ្ចុះបញ្ចូលមនុស្សដទៃទៀត។

៥. អ្នកសំរបសំរួលសួរបញ្ជាក់ថា តើពត៌មាននៅក្នុងឯកសារមេរៀនទី៦.៤.២ក មានភាពច្បាស់លាស់ដែរឬទេ? ហើយពន្យល់ថា នៅក្នុងជំហានបន្ទាប់អ្នកចូលរួមនឹងអនុវត្តការប្រើប្រាស់គោលការណ៍ណែនាំនេះ។

ខ. ការសំដែងតួស្តីពីការចរចា

១. អ្នកសំរបសំរួលចែកឯកសារមេរៀនទី៦.៤.២ខ ករណីសិក្សា ស្តីពីអំពើហិង្សាក្នុងគ្រួសារដល់អ្នកចូលរួមទាំងអស់។ ចែកអ្នកចូលរួមជាពីរក្រុម។ សុំអោយអ្នកចូលរួមអាននិងវិភាគពីបញ្ហា និងផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារ ដោយប្រើប្រាស់សំណួរទាំងបួនខាងក្រោម :

* ផលប៉ះពាល់ (អវិជ្ជមាននិងវិជ្ជមាន) អំពីអំពើហិង្សាក្នុងគ្រួសារទៅដល់សង្គមទៅក្នុងសហគមន៍ និងសង្គម។
* ផលប៉ះពាល់ (អវិជ្ជមាននិងវិជ្ជមាន) អំពីអំពើហិង្សាទៅដល់ស្ត្រីដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ។
* ផលប៉ះពាល់ (អវិជ្ជមាននិងវិជ្ជមាន) អំពីកម្មវិធីដោះស្រាយអំពើហិង្សាក្នុងគ្រួសារទៅដល់សង្គម។
* ផលប៉ះពាល់ (អវិជ្ជមាននិងវិជ្ជមាន) អំពីកម្មវិធីដោះស្រាយអំពើហិង្សាក្នុងគ្រួសារទៅលើក្រុមគ្រួសារ។

ក្រុមនីមួយៗត្រូវសរសេរលទ្ធផលនៃការវិភាគរបស់ខ្លួននៅលើក្រដាស់ផ្ទាំងធំ ។

២. អ្នកសំរបសំរួលប្រាប់ទៅអ្នកចូលរួមថា ពួកគេនឹងសម្តែងតួនៃការប្រជុំដែលមានវត្តមានភាគីពីរ។ ក្រុមទីមួយតំណាងឱ្យភាគី "ក" រួមមានតំណាងមកពីក្រុមប្រឹក្សាឃុំ-សង្កាត់ ក្រុមទីពីរតំណាងឱ្យ

ភាគី "ខ" ជាតំណាងមកពីអង្គការមិនមែនរដ្ឋាភិបាលធ្វើការផ្នែកសិទ្ធិស្ត្រី។ តំណាងមកពីអង្គការមិនមែនរដ្ឋាភិបាលបានស្នើសុំការប្រជុំជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីសុំការអនុញ្ញាតិអនុវត្តគំរោងប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារនៅក្នុងសហគមន៍។ គំរោងរួមមាន សកម្មភាពបង្កើនការយល់ដឹងដល់ក្រុមស្ត្រី និងជំរុញអោយក្រុមស្ត្រីប្តឹងពីប្តីរបស់ពួកគេ ប្រសិនបើពួកគេត្រូវបានប្តីរបស់ខ្លួនរំលោភបំពាន។ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវធ្វើសេចក្តីសំរេច តើគួរអនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាលនោះ អនុវត្តគំរោងបែបនេះនៅក្នុងសហគមន៍របស់ខ្លួនឬទេ?

៣. អ្នកសំរបសំរួលសុំអោយក្រុមនីមួយៗ ត្រៀមរៀបចំសំរាប់ការប្រជុំដោយប្រើប្រាស់គោលការណ៍ណែនាំពីការធ្វើផែនការសំរាប់ការចរចា ដែលមាននៅក្នុងឯកសារមេរៀនទី៦.៤.២.គ ស្តីពីការណែនាំសំរាប់អ្នកសម្តែងជាក្រុមប្រឹក្សាឃុំ-សង្កាត់ និងឯកសារមេរៀនទី៦.៤.២.គ ស្តីពីការណែនាំសំរាប់អ្នកសម្តែងជាអង្គការមិនមែនរដ្ឋាភិបាល។ សុំឱ្យពួកគេ ដឹកនាំការសំដែងតួរហូតដល់កិច្ចប្រជុំទទួលបាននូវការសំរេច។

៤. អ្នកសំរបសំរួលសួរពីបទពិសោធន៍របស់អ្នកចូលរួមដែលពួកគេទទួលបានពីការសំដែងតួនេះ : *តើអ្នកណាជាអ្នកចរចា? តើអ្នកណាជាអ្នកធ្វើសេចក្តីសំរេច? តើមានអ្វីខ្លះដែលងាយស្រួលនិងអ្វីខ្លះដែលលំបាកសំរាប់ការចរចានៅក្នុងការសំដែងតួ?* សរសេរចំលើយដាក់លើក្រដាសផ្ទាំងធំ។

៥. អ្នកសំរបសំរួលសួរអ្នកចូលរួមថា: *តើការសំរេចត្រូវបានធ្វើឡើងដោយរបៀបណានៅក្នុងកិច្ចប្រជុំនេះ? តើអ្នកធ្វើសេចក្តីសំរេចស្ថិតក្នុងស្ថានភាពបែបណាមុនពេលធ្វើការប្រជុំ? តើអ្នកធ្វើការចរចាមានអារម្មណ៍បែបណាមុនពេលប្រជុំ?* សរសេរចំលើយដាក់លើក្រដាសផ្ទាំងធំ។

៦. អ្នកសំរបសំរួលសុំអោយអ្នកចូលរួមគិតដល់ការសំរេចផ្សេងៗ ដែលបានធ្វើឡើងនៅក្នុងអង្គប្រជុំ។ *តើមានអ្វីខ្លះដែលជួយជំរុញឱ្យមានការសំរេចបាន?* សរសេរចំលើយដាក់លើក្រដាសផ្ទាំងធំ។

៧. អ្នកសំរបសំរួលធ្វើការសង្ខេបការពីការសម្តែងតួ។

គ. **លំហាត់ស្តីពីការរៀបចំកៅអី** (ចំពោះល្បែងនេះអាស្រ័យទៅលើពេលវេលានិងទីកន្លែង)

១. អ្នកសំរបសំរួលសុំឱ្យអ្នកចូលរួមរៀបចំបន្ទប់ឱ្យមានភាពទូលាយស្រួលអនុវត្តលំហាត់នេះ។ ចែកអ្នកចូលរួមជាពីរឬបីក្រុម។ អ្នកសំរបសំរួលសុំឱ្យក្រុមនីមួយៗ រៀបចំដឹកនាំលេងល្បែងដោយយកកៅអីទៅដាក់នៅទីកន្លែងណាមួយនៅក្នុងបន្ទប់ទៅតាមការគិតរបស់ក្រុមនីមួយៗ។ មិនត្រូវមានការជជែកពិភាក្សារវាងក្រុមនីមួយៗទេ។

២. នៅពេលបញ្ចប់លំហាត់ អ្នកសំរបសំរួលសួរដល់អ្នកចូលរួមថា *តើមានការលំបាកអ្វីខ្លះដែលមិនអាចអោយពួកគេបានសំរេចតាមគោលបំណងរបស់ខ្លួន។* សរសេរចំលើយដាក់លើក្រដាសផ្ទាំងធំ។

៣. អ្នកសំរបសំរួលសុំអោយក្រុមគិតពីរបៀបដោះស្រាយទំនាស់នៅក្នុងលំហាត់នេះ។ សរសេរចំលើយដាក់លើក្រដាស់ផ្ទាំងធំ ។

៤. សុំអោយក្រុមគិតពីការចរចាផ្សេងៗ មិនអាចសំរេចតាមគោលបំណង។ បន្ទាប់មក ឱ្យពួកគេគិតពីវិធីដោះស្រាយទំនាស់នោះអោយបានប្រសិទ្ធភាព។ សរសេរចំលើយដាក់លើក្រដាសផ្ទាំងធំ ។

៥. អ្នកសំរបសំរួលធ្វើសេចក្ដីសង្ខេបល្បែងរៀបចំកៅអី ដោយបញ្ជាក់ថា គោលបំណងនៃលំហាត់នេះ គឺធ្វើឡើងដើម្បីបង្ហាញពីលទ្ធផលនៃការធ្វើអ្វីមួយដោយគ្មានការចរចា គ្មានការព្រមព្រៀង គ្មានការពន្យល់ពីមូលហេតុនិងហេតុផលច្បាស់លាស់ ធ្វើឱ្យចំណាយពេលវេលាច្រើន ប៉ុន្តែពុំទទួលបានជោគជ័យ និងអាចធ្វើអោយមានទំនាស់នឹងគ្នាទៅវិញទៅមកទៀតផង។

**ឃ. ការពិភាក្សាក្រុមធំ**

១. អ្នកសំរបសំរួលចែកឯកសារមេរៀនទី ៥.៤.២ង ស្ដីពីគោលការណ៍នៃការចរចារ ហើយសុំអោយអ្នកចូលរួមអាននិងសួរសំនួរអំពី ការចរចា។ ត្រូវផ្ដល់ពេលវេលាគ្រប់គ្រាន់សំរាប់ពួកគេអាន សួរសំនួរនិងផ្ដល់យោបល់។ អ្នកសំរបសំរួលឆ្លើយតបទៅនឹងសំនួរ ។

២. អ្នកសំរបសំរួលសុំអោយអ្នកចូលរួមគិតអំពីការចរចា និងការដោះស្រាយទំនាស់នៅក្នុងស្ថានភាពការងាររបស់ពួកគេ ។ សួរពួកគេថា តើពួកគេបានរៀនអ្វីខ្លះពីមេរៀននេះដែលពួកគេអាចយកទៅអនុវត្តនៅក្នុងការងាររបស់ពួកគេ ។ សរសេរចំលើយដាក់លើក្រដាសផ្ទាំងធំ។

៦. អ្នកសំរបសំរួលសង្ខេបមេរៀន ។

**កំណត់សំគាល់របស់សំរបសំរួល :**

មេរៀននេះពាក់ពន្ធ័ទៅនឹងការចរចានៅក្នុងពេលប្រជុំ។ ជារឿយៗ ក្នុងនាមជាអ្នកទទួលបន្ទុកកិច្ចការនារីនិងអតីតយុទ្ធជន ពួកត្រូវធ្វើការចរចាជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ឬស្ថាប័ននិងអង្គភាពនានា ដើម្បីបញ្ចុះបញ្ចូលនិងស្វែងរកការគាំទ្រមតិសំរាប់គាំទ្រគំរោងឬតម្រូវការរបស់ស្ត្រីនិងកុមារ។ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារត្រូវតែយកចិត្តទុកដាក់អនុវត្តនូវជំនាញទាំងនេះឱ្យបានញឹកញាប់ ដើម្បីជួយពង្រឹងនូវការអនុវត្តន៍ភារកិច្ចនិងតួនាទីរបស់ពួកគេឱ្យកាន់តែមានប្រសិទ្ធភាព។

ᨐᨐᨐᨐ ☺☺☺ ᨐᨐᨐᨐ

ដើម្បីឱ្យកិច្ចប្រជុំយើងមានប្រសិទ្ធភាព យើងត្រូវត្រៀមការងារជាច្រើន។ ចូរឆ្លើយទៅនឹងសំនួរដូចតទៅនេះ ដើម្បីត្រួតពិនិត្យលើការត្រៀមខ្លួនមុនចូលរួមប្រជុំ ឬចរចា :

១. តើការប្រជុំរបស់យើងមានគោលបំណងអ្វីខ្លះ? តើយើងសង្ឃឹមថានឹងសំរេចបានអ្វីខ្លះនៅក្នុងអង្គប្រជុំ? តើយើងសង្ឃឹមថានឹងឈានដល់ការសំរេចចិត្តអ្វីខ្លះនៅក្នុងអង្គប្រជុំ?

២. តើអាចមានជំរើសអ្វីខ្លះសំរាប់ការធ្វើសេចក្តីសំរេច? តើជំរើសណាមួយដែលយើងគិតថា សមស្របបំផុតសំរាប់យើង?

៣. តើមានយោបល់ គំនិតណាខ្លះដែលស្របទៅនឹងសំណើររបស់យើង?

៤. តើយើងអាចផ្តល់ពត៌មានអ្វីខ្លះដើម្បីគាំទ្រដល់ការការពារយោបល់គំនិតរបស់យើង?

៥. តើគំនិតយើងខ្ចី និងសមហេតុផលដែរឬទេ?

៦. តើយើងគិតថា សំណើររបស់យើងមានផលប្រយោជន៍អ្វីខ្លះដល់អ្នកដទៃទៀត?

៧. នៅក្នុងអង្គប្រជុំ តើភាគីដទៃទៀតអាចនឹងមានគំនិតអ្វីខ្លះដែលសមស្របទៅនឹងសំណើររបស់យើង?

៨. នៅក្នុងអង្គប្រជុំ តើភាគីដទៃទៀតអាចនឹងមានគំនិតអ្វីខ្លះដែលអាចអះអាងថាសំណើររបស់យើងមិនសមស្រប?

៩. តើយើងអាចធ្វើដូចម្តេចខ្លះ ដើម្បីជំរុញអោយអ្នកដទៃទៀតបំពេញគោលបំណងរបស់យើង?

១០. តើយើងនឹងធ្វើដូចម្តេច ប្រសិនបើអ្នកដទៃទៀតមិនយល់ស្របទៅនឹងសំណើររបស់យើង?

☺☺☺

## ឯកសារមេរៀនទី៦.៤.២ខ : ករណីសិក្សាស្តីពី អំពើហិង្សាក្នុងគ្រួសារ

មានរបាយការណ៍មួយថ្លែងថា មានអំពើហិង្សាកើតមានជាទូទៅនៅក្នុងប្រទេសទាំងមូល។ ស្ត្រី ម្នាក់ក្នុងចំណោមស្ត្រីបួននាក់និយាយថា ពួកគេត្រូវប្តីវាយធ្វើបាបទាំងផ្លូវកាយនិងផ្លូវចិត្ត។ មានស្ត្រីខ្លះត្រូវបានវាយយ៉ាងខ្លាំងរហូតដល់បាក់ឆ្អឹង រហូតដល់មានការសង្គ្រោះបន្ទាន់។ ក្នុងករណីជាច្រើន បុរសកាន់តែប្រព្រឹត្តការរំលោភបំពាននៅពេលដែលពួកគេផឹកគ្រឿងស្រវឹង។ ជាក់ស្តែងការវាយប្រពន្ធ និងកូនគឺជាការបង្កអំពើហឹង្សាក្នុងគ្រួសារនិងជាអំពើប្រឆាំងនឹងច្បាប់។ មានករណីខ្លះ ស្ត្រីត្រូវបានប្តីរបស់ខ្លួនវាយធ្វើបាបជាញឹកញាប់និងយ៉ាងខ្លាំងរហូតធ្វើឱ្យពួកគេចង់ចាកចេញពីប្តីរបស់ខ្លួន។ នៅក្នុងករណីផ្សេងទៀត ស្ត្រីមានផ្ទៃពោះត្រូវបានវាយធ្វើបាបរហូតធ្វើអោយបាត់បង់ទារកនៅក្នុងផ្ទៃ។

ជាទូទៅស្ត្រីមិនចង់ប្តឹងទៅអាជ្ញាធរមូលដ្ឋានទេ ទោះបីត្រូវប្តីវាយធ្វើបាបក៏ដោយ។ ពួកគេមានអារម្មណ៍ខ្មាស់អៀនចំពោះការពិភាក្សារឿងគ្រួសារជាមួយអាជ្ញាធរមូលដ្ឋាន ជាពិសេសប្រសិនបើអ្នកទាំងនោះជាបុរស។ ជាទូទៅ អាជ្ញាធរមូលដ្ឋានមានអារម្មណ៍ស្ទាក់ស្ទើរក្នុងការលូកដៃចូលទៅក្នុងរឿងរ៉ាវផ្ទៃក្នុងរបស់គ្រួសារ។ ប្រសិនបើករណីធ្ងន់ធ្ងរ អាជ្ញាធរមូលដ្ឋានអាចនាំបុរសនិងស្ត្រីអោយជួបគ្នា លើកទឹកចិត្តឱ្យពួកគេព្យាយាមរស់នៅជាមួយគ្នា ហើយឱ្យបុរសជាប្តីសុំទោស និងចុះហត្ថលេខាព្រមព្រៀងថាលែងវាយធ្វើបាបប្រពន្ធរបស់ខ្លួនទៀតហើយ។ តែកិច្ចព្រមព្រៀងនេះមិនបានយូរទេ ពួកគេមានការឈ្លោះប្រកែកគ្នា ហើយស្ត្រីត្រូវទទួលការវាយដុំជាបន្តទៀត។ ស្ត្រីភាគច្រើនមានការភ័យខ្លាចថា ប្រសិនបើប្តីរបស់ខ្លួនត្រូវជាប់គុក ពួកគេនឹងបាត់បង់ប្រាក់ចំណូលពីប្តីរបស់ខ្លួន ហើយធ្វើឱ្យគ្រួសាររបស់ខ្លួនកាន់តែដុនដាប។ ដូចនេះនៅពេលប្តីរបស់ពួកគេបានត្រឡប់មកផ្ទះវិញ នៅតែបន្តការវាយធ្វើបាបគ្រួសារដដែល។ ស្ត្រីត្រូវបានសង្គមកំណត់ឱ្យគោរពនិងស្តាប់បង្គាប់បុរស ហើយបុរសអាចវាយប្រពន្ធរបស់ខ្លួនបាននៅពេលខ្លះ ប្រសិនបើប្រពន្ធមិនគោរពប្តី ។

ស្ត្រីនិងបុរសភាគច្រើនគិតថា ការវាយធ្វើបាបប្រពន្ធកូនគឺជារឿងធម្មតា និងជាទំនៀមទម្លាប់របស់សង្គម។ បុរសខ្លះគិតថា ជាការធម្មតាដែលពួកគេវាយប្រពន្ធកូនម្តងម្កាលដើម្បីអប់រំ។ បុរសៗមានអារម្មណ៍ផងដែរថា ពួកគេបាត់បង់ការគ្រប់គ្រងលើខ្លួនឯងនៅពេលដែលពួកគេផឹកគ្រឿងស្រវឹង ដូចនេះពួកគេមិនទទួលខុសត្រូវពីផលវិបាកដែលកើតឡើងពីការស្រវឹងនោះទេ ។

អង្គការនិងក្រសួងជាច្រើនដែលកំពុងធ្វើការអភិវឌ្ឍន៍បានលើកជាកង្វល់ថា អំពើហឹង្សាក្នុងគ្រួសារ គឺជាប្រការគ្រោះថ្នាក់ដល់សុវត្ថិភាពនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ជាទូទៅ ស្ត្រីដែលមិនទទួលការវាយធ្វើបាបតែងតែមានសុខភាពល្អ មានជំនឿជឿជាក់លើខ្លួនឯងនិងមានសេចក្តីសុខ។ ជា

លទ្ធផល ពួកគេបានរួមចំណែកក្នុងការលើកកំពស់ផ្នែកសុខភាព និងសុខុមាលភាពក្រុមគ្រួសាររបស់ពួកគេ ថែមទាំងរួមចំណែកដល់ការអភិវឌ្ឍន៍ទាំងខាងផ្នែកសង្គមនិងសេដ្ឋកិច្ចនៅក្នុងសហគមន៍។

អង្គការ និងក្រសួងទាំងនោះ ប្រឹងប្រែងស្វែងរកការគាំទ្រនានា ដើម្បីចាត់វិធានការ និងមានកម្មវិធីសំរាប់កាត់បន្ថយអំពើហិង្សានៅក្នុងគ្រួសារ ហើយពួកគេមានគំនិតថា បុរសដែលវាយធ្វើបាបប្រពន្ធត្រូវតែបានដាក់ទណ្ឌកម្មឱ្យធ្ងន់ធ្ងរ។ ស្ថាប័នខ្លះទៀតមានអារម្មណ៍ថា មិនគួរលូកដៃចូលទៅក្នុងរឿងគ្រួសារទេ។

កម្មវិធីខ្លះមានគោលបំណងកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ រួមមានការបង្កើនការយល់ដឹងដល់បុរសនិងស្ត្រីដើម្បីឱ្យពួកគេដឹងថា អំពើហិង្សាក្នុងគ្រួសារជាអំពើខុសច្បាប់ និងអោយស្ត្រី ហ៊ាននិយាយ ព្រមទាំងមានកម្មវិធីសំរាប់អប់រំដល់អាជ្ញាធរមូលដ្ឋានឱ្យទទួលស្គាល់ និងគាំទ្រជនរងគ្រោះ ហើយដាក់ទណ្ឌកម្មចំពោះបុរសឬជនណាដែលប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ។

## ឯកសារមេរៀនទី៦.៤.២គ: ការណែនាំសំរាប់អ្នកសម្តែងជាក្រុមប្រឹក្សាឃុំ-សង្កាត់

- ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវធ្វើសេចក្តីសំរេចថា តើត្រូវគាំទ្រឬមិនគាំទ្រដល់គំរោងប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសាររបស់អង្គការមិនមែនរដ្ឋាភិបាល។ អ្នកមានការបារម្ភថា គំរោងនេះនឹងមិនធ្វើអោយបុរសៗនៅក្នុងសហគមន៍ពេញចិត្តទេ ជាពិសេស អ្នកត្រូវការការគាំទ្រពីបុរសសំរាប់ការងារនយោបាយរបស់អ្នក។ អ្នកក៏បារម្ភណ៍ផងដែរថាគំរោង នេះអាចមិនសមស្របសំរាប់ឃុំ-សង្កាត់របស់អ្នកទេ។ តែអ្នកក៏បានដឹងដែរថា អាជ្ញាធរខេត្ត-ក្រុងកំពុងជំរុញឱ្យឃុំ-សង្កាត់គិតអំពីកម្មវិធីអភិវឌ្ឍន៍ថ្មីៗ ហើយអំពើហិង្សាក្នុងគ្រួសារត្រូវបានចាត់ជាបញ្ហាអាទិភាពរបស់ប្រទេស។
- មុននឹងអ្នកធ្វើការសំរេច អ្នកត្រូវគិតថា តើអំពើហិង្សាក្នុងគ្រួសារនេះផ្តល់ការលំបាក និងផលប៉ះពាល់អវិជ្ជមានអ្វីខ្លះដល់ឃុំ-សង្កាត់របស់អ្នក។ អ្នកត្រូវក៏គិតផងដែរថា តើគំរោងកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារនេះផ្តល់ប្រយោជន៍និងផលប៉ះពាល់ (អវិជ្ជមាន-វិជ្ជមាន) អ្វីខ្លះដល់ឃុំ-សង្កាត់របស់អ្នក។
- អ្នកត្រូវស្តាប់នូវការការពារគំនិតរបស់អង្គការមិនមែនរដ្ឋាភិបាលហើយត្រូវត្រៀមរៀបចំសំនួរនិងការផ្តល់យោបល់ផ្សេងៗផងដែរ។

☺☺☺

- អង្គការមិនមែនរដ្ឋាភិបាលត្រូវបញ្ចុះបញ្ចូលក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីគាំទ្រនិងឯកភាពលើការអនុវត្តន៍គំរោងកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ។
- អ្នកត្រូវបង្ហាញពីគោលបំណងច្បាស់លាស់របស់អង្គការអ្នកក្នុងការលើកស្ទួយផលប្រយោជន៍ និងសុខុមាលភាពទូទៅរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍។
- អ្នកត្រូវបង្ហាញពីការលំបាកនិងផលប៉ះពាល់ជាអវិជ្ជមាននៃអំពើហឹង្សាក្នុងគ្រួសារទៅលើស្ត្រី ក្រុមគ្រួសារ និងសហគមន៍។
- អ្នកត្រូវបង្ហាញពីផលប្រយោជន៍នៃការកាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារចំពោះស្ត្រី ក្រុមគ្រួសារ សហគមន៍និងប្រទេសជាតិទាំងមូល។
- អ្នកត្រូវព្យាយាមរកមធ្យោបាយនិងផ្តល់ហេតុផលដើម្បីជំរុញនិងបញ្ចុះបញ្ចូលឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់គាំទ្រគំនិតរបស់អ្នក។

៚៚៚ ☺☺☺ ៙៙

## ឯកសារមេរៀនទី៦.៤.២.៦ : គោលការណ៍នៃការចរចា

ខាងក្រោមនេះ គឺជាគោលការណ៍ទាំង១០សំរាប់ការចរចាដែលមានប្រសិទ្ធភាព។ គោលការណ៍ទាំងនេះអាចមានប្រយោជន៍សំរាប់អ្នកក្នុងការត្រៀមរៀបចំកិច្ចប្រជុំ និងនៅក្នុងកិច្ចប្រជុំដែលមានការចរចាលើបញ្ហាអ្វីមួយ។

១. ការត្រៀមរៀបចំជាមុន : នៅពេលដែលអ្នកដឹងថាអ្នកនឹងចូលរួមនៅក្នុងការចរចាណាមួយ អ្នកត្រូវតែរៀបចំឱ្យបានច្បាស់លាស់ជាមុននូវ :

- អ្នកត្រូវអានពត៌មានដែលពាក់ពន្ធ័នឹងបញ្ហាដែលត្រូវចរចា ។
- ពិនិត្យមើលថា តើមានបញ្ហាអ្វីទៀតប្រហាក់ប្រហែលនឹងបញ្ហានេះ?
- តើមានច្បាប់និងគោលនយោបាយពាក់ពន្ធ័នឹងបញ្ហានេះ?
- តើអ្នកណានឹងចូលរួមក្នុងកិច្ចប្រជុំនេះ?

២. បង្កើតគោលបំណងរបស់អ្នក : មុនកិច្ចប្រជុំ អ្នកត្រូវសួរខ្លួនឯងឱ្យបានច្បាស់ថា :

- តើអ្វីជាគោលបំណងរបស់អ្នក? សរសេរនូវអ្វីដែលអ្នកចង់បាន។
- គិតមើលថាតើអ្នកណាដែលអាចជំទាស់នូវយោបល់និងការចង់បានរបស់អ្នក? សរសេរនូវហេតុផលដែលពួកគេចង់ជំទាស់ជាមួយយើង។
- គិតហើយសរសេរនូវជំរើសនានា។

៣. ត្រូវយល់ដឹងនិងព្យាយមស្តាប់នៅក្នុងកិច្ចប្រជុំ : នៅក្នុងពេលប្រជុំ អ្នកត្រូវតែដឹងនូវគំនិត ជំនាញ ទំនាក់ទំនងនិងប្រតិកម្មរបស់អ្នកជំទាស់។ ដើម្បីជួយឱ្យអ្នកអាចឆ្លើយបានល្អអ្នកត្រូវ:

- កាត់ចោលនូវភាពលំអៀងរបស់អ្នកជាមួយនឹងអ្នកដែលត្រូវទំនាក់ទំនង។
- ស្តាប់និងកត់ត្រានូវអ្វីដែលអ្នកដ៏ទៃទៀតនិយាយគាំទ្រដល់ពួកគេនិងត្រូវយល់ច្បាស់ពីអ្វីដែលពួកគេលើកឡើង។
- គ្រប់គ្រងសតិអារម្មណ៍របស់អ្នក។
- ត្រូវដឹងថាអ្វីដែលអ្នកមិនគួរនិយាយ។

៤. ត្រូវដឹងពីចំណាប់អារម្មណ៍ សារៈប្រយោជន៍ និងមូលហេតុរបស់អ្នក និងរបស់អ្នកដ៏ទៃតើគេត្រូវការអ្វីពិតប្រាកដ។

៥. កំណត់និងបើកការពិភាក្សាលើការព្រមព្រៀងនិងសារៈប្រយោជន៍សំរាប់ភាគីទាំងអស់។

៦. នៅពេលដែលកិច្ចប្រជុំស្ថិតនៅក្នុងភាពមិនចុះសំរុង ត្រូវរួមគ្នាដោះស្រាយបញ្ហាទាំងនោះ។

៧. ប្រើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ដែលសមស្របសំរាប់អ្នកនិងអ្នកដទៃ ដើម្បីជួយឱ្យឈានទៅដល់កិច្ចព្រមព្រៀង។

៨. បង្កើតនូវការជឿទុកចិត្តទៅវិញទៅមក។

៩. យកថ្នាក់ដឹកនាំ ឬមនុស្សដែលគាំទ្រអ្នក ឱ្យជួយជំរុញលើចំណុចដែលអ្នកលើកឡើង។

១០. ចាំនស្វានលើចំណុចខ្លាំង ចំណុចខ្សោយលើប្រធានបទ ឬសាច់រឿងរបស់អ្នកមុនពេលប្រជុំ។

ႧႧႧႧ ☺☺☺ ႵႵႵ